ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុកម្ពុជា

## ឆ្នាំ២០២៤-២០៣៣

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០២៤

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹង
# ការប្រែប្រួលអាកាសធាតុកម្ពុជា
# ឆ្នាំ២០២៤-២០៣៣

រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០២៤

# សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា សូមប្រកាសប្រកបដោយមោទនភាពចំពោះការដាក់ឱ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា រយៈពេលដប់ឆ្នាំ ២០២៤-២០៣៣ ដែលជាសក្ខីភាពមួយចំពោះការប្តេជ្ញាចិត្តមិនងាករេរបស់កម្ពុជា ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ដ៏ធំធេងមកលើសេដ្ឋកិច្ច និងសង្គមរបស់យើង។ ក្នុងនាមជាប្រទេសហត្ថលេខីនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) និងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ ប្រទេសកម្ពុជានៅតែប្រកាន់ខ្ជាប់ការប្តេជ្ញាចិត្តជាអន្តរជាតិរបស់ខ្លួនក្នុងការជំរុញអនាគតប្រកបដោយចីរភាព។ ផែនការយុទ្ធសាស្ត្រជាតិនេះ គឺជាឯកសារដ៏មានសារៈសំខាន់មួយនៅក្នុងដំណើរសកម្មភាពអាកាសធាតុរបស់យើង ដោយផ្អែកលើមូលដ្ឋានផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣ ដែលបានដាក់ចេញនាពេលកន្លងមក។

ប្រទេសកម្ពុជាមានភាពងាយរងគ្រោះខ្លាំង នៅចំពោះមុខការប្រែប្រួលអាកាសធាតុ ដោយសារកំណើនសីតុណ្ហភាព ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរដែលកើតមានកាន់តែញឹកញាប់ និងការកើនឡើងកម្ពស់ទឹកសមុទ្រ ដែលបានគំរាមកំហែងដល់វិស័យកសិកម្ម នេសាទ និងឧស្សាហកម្មទេសចរណ៍។ ប្រទេសកម្ពុជាបានបង្ហាញពីសមត្ថភាពរបស់ខ្លួន ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ ដោយកំណត់របៀបវារៈជាតិប្រកបដោយមហិច្ឆតា សម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងការបង្កើតគោលនយោបាយសំខាន់ៗ ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់នានាដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ដូចជាផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ២០២០ យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតភាពកាបូននៅកម្ពុជា ឆ្នាំ២០២១ និងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ និងដំណើរការដែលពាក់ព័ន្ធរបស់ជាតិ។ សមិទ្ធផលទាំងនេះ អាចធ្វើទៅបានតាមរយៈកិច្ចសហការយូរអង្វែងដោយភាគីពាក់ព័ន្ធសំខាន់ៗរបស់រាជរដ្ឋាភិបាល និងការគាំទ្រដ៏មានតម្លៃពីដៃគូអភិវឌ្ឍន៍នានា។

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០២៤-២០៣៣ ត្រូវបានរៀបចំឡើងយ៉ាងយកចិត្តទុកដាក់ ដើម្បីផ្តល់ជាផែនទីបង្ហាញផ្លូវគោលនយោបាយជាតិតែមួយគត់ដោយគ្របដណ្តប់លើមហិច្ឆតាក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការលើកកម្ពស់អភិបាលកិច្ច។ ផែនការយុទ្ធសាស្ត្រនេះផ្តល់អាទិភាពដល់កិច្ចការពារសហគមន៍របស់យើងដែលងាយរងគ្រោះបំផុត ដោយផ្តោតជាពិសេសលើកុមារ និងស្ត្រី ដែលរងផលប៉ះពាល់បណ្តាលមកពីការប្រែប្រួលអាកាសធាតុក្នុងកម្រិតវិសមាមាត្រ។ ផែនការយុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងស្របតាមគោលនយោបាយជាតិសំខាន់ៗ ដូចជា យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ២០២៣-២០២៨ ផែនការ

យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨ ក៏ដូចជាយុទ្ធសាស្ត្រតាមវិស័យផងដែរ។ វិធីសាស្ត្រជារួមចំពោះអភិបាលកិច្ចបរិស្ថាន គូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់យើងដើម្បីដោះស្រាយបញ្ហាប្រឈមដែលទាក់ទងគ្នានៃការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍសេដ្ឋកិច្ច និងសមធម៌សង្គម។

យើងមានទំនុកចិត្តថា ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០២៤-២០៣៣ នឹងនាំមកនូវអត្ថប្រយោជន៍យ៉ាងច្រើនដល់ប្រជាជនកម្ពុជា និងរួមចំណែកយ៉ាងសំខាន់ដល់កិច្ចខិតខំប្រឹងប្រែងជាសាកល ដើម្បីកាត់បន្ថយផលប៉ះពាល់នានាដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងកសាងសង្គមប្រកបដោយភាពធន់។ យើងទទួលស្គាល់ថា សកម្មភាពអាកាសធាតុទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដែលមិនត្រឹមតែមានការចូលរួមពីស្ថាប័នរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានការចូលរួមដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល រាជបណ្ឌិតសភា និងសហគមន៍កម្ពុជាទាំងមូល ផងដែរ។

រួមជាមួយគ្នា យើងរំពឹងយ៉ាងមុតមាំ និងត្រៀមខ្លួនរួចជាស្រេច ដើម្បីដោះស្រាយបញ្ហាប្រឈម និងចាប់យកកាលានុវត្តភាពនានា ក្នុងកិច្ចប្រឹងប្រែងដើម្បីធ្វើឱ្យកម្ពុជាកាន់តែមានភាពធន់ និងចីរភាព។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែមីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# អារម្ភកថា

ឈរលើមូលដ្ឋាននៃសុខសន្តិភាព ឯកភាពជាតិ និងបូរណភាពទឹកដី ការប្តេជ្ញាចិត្តមិនងាករេ ទឹកចិត្តស្នេហាជាតិ និងពលិកម្មគ្រប់បែបយ៉ាង ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលកម្ពុជាបានជំរុញការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតភាពកាបូនឆ្នាំ២០៥០ និងយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថានឆ្នាំ២០២៣-២០២៨។ កិច្ចប្រឹងប្រែងរួមគ្នាទាំងនេះ បាននាំមកនូវសមិទ្ធផលសំខាន់ៗ និងការរីកចម្រើនគួរឱ្យកត់សម្គាល់ ទាំងផ្នែកនយោបាយ សេដ្ឋកិច្ច សង្គម និងបរិស្ថានដល់ការអភិវឌ្ឍប្រទេសកម្ពុជា។

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១របស់រាជរដ្ឋាភិបាលកម្ពុជា មានសារៈសំខាន់ចំពោះក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា ដោយបានផ្តល់ជាទិសដៅយុទ្ធសាស្ត្រឯកភាពគ្នា សម្រាប់ការពង្រឹងសមត្ថភាពស្ថាប័ន។ ប្រព័ន្ធអភិបាលកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា កំពុងឈានឆ្ពោះទៅកាន់ទំនើបកម្ម បង្កើនប្រសិទ្ធផល និងប្រសិទ្ធភាពនៃប្រព័ន្ធផ្តល់សេវា ដែលជួយសម្រួលដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចយ៉ាងឆាប់រហ័សក្នុងការទទួលបាននូវមុខមាត់ដោយស្មើភាពក្នុងតំបន់ និងលើសកលលោក។ ការផ្លាស់ប្តូរនេះបាននាំប្រទេសកម្ពុជាឆ្ពោះទៅរកលំនាំនៃការសម្រេចបាននូវស្ថានភាព ជាប្រទេសមានប្រាក់ចំណូលមធ្យម ដែលបានបង្ហាញតាមរយៈកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងសមាហរណកម្មក្នុងតំបន់និងអន្តរជាតិ។

ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ចាប់តាំងពីការបង្កើតស្ថាប័នបរិស្ថានក្នុងឆ្នាំ១៩៩៣ វិស័យបរិស្ថានទទួលបានការយកចិត្តទុកដាក់ឥតឈប់ឈរពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា។ ប្រការនេះស្តែងឱ្យឃើញតាមរយៈកិច្ចសហប្រតិបត្តិការពហុភាគីនិងពហុស្ថាប័ន ការចូលរួមយ៉ាងសកម្មពីដៃគូអភិវឌ្ឍន៍ ម្ចាស់ជំនួយ និងប្រជាជនកម្ពុជាក្នុងការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ។ ការដឹកនាំ និងការយកចិត្តទុកដាក់របស់មន្ត្រីគ្រប់លំដាប់ថ្នាក់នៃក្រសួងបរិស្ថាន បាននាំឱ្យការអនុវត្តគោលនយោបាយសំខាន់ៗ កំណែទម្រង់ច្បាប់ និងទំនើបកម្មស្ថាប័ន ដែលនាំមកនូវលទ្ធផលជាទីគាប់ចិត្ត។

ដោយបានបន្សីគ្នាជាមួយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងស្របតាមគោលនយោបាយនិងយុទ្ធសាស្ត្រជាតិ ព្រមទាំងក្របខ័ណ្ឌអន្តរជាតិដែលមានស្រាប់ ក្រសួងបរិស្ថានបានបង្កើត **«ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០២៤-២០៣៣»**។

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុថ្មីរបស់កម្ពុជាឆ្នាំ២០២៤-២០៣៣ (CCCSP 2024-2033) មានបំណងដោះស្រាយភាពខ្វះចន្លោះនៃការអនុវត្តឆ្ពោះទៅសម្រេចឱ្យបាននូវផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា (NDC 3.0) និងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន និងផ្តល់ការយកចិត្តទុកដាក់ជាក់លាក់ចំពោះប្រធានបទដែលលេចឡើងថ្មីៗអំពីអាកាសធាតុ និងចំពោះប្រជាពលរដ្ឋដែលងាយរងគ្រោះ និងអ្នកដែលប្រឈមហានិភ័យ ជាពិសេសកុមារនិងស្ត្រី។ ផែនការយុទ្ធសាស្ត្រនេះ ត្រូវបានបង្កើតឡើងស្របតាមគោលនយោបាយជាតិសំខាន់ៗ ដូចជា យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន២០២៣-២០២៨ និងយុទ្ធសាស្ត្រតាមវិស័យរបស់ស្ថាប័ននានា។

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០២៤-២០៣៣ ក៏បង្ហាញពីតម្រូវការហិរញ្ញវត្ថុ បច្ចេកវិទ្យា និងធនធាន ដែលនឹងត្រូវវិភាគឱ្យបានលម្អិតបន្ថែមទៀត ស្របតាមតម្រូវការនិងកាលៈទេសៈ

នៃការអភិវឌ្ឍជាតិ។ ក្នុងជំហានទៅមុខ យើងរំពឹងថា ស្ថាប័នពាក់ព័ន្ធនឹងរៀបចំផែនការ និងអនុវត្តសកម្មភាពរៀងៗខ្លួន ដើម្បីគាំទ្រដល់វឌ្ឍនភាពរបស់កម្ពុជា ឆ្ពោះទៅអព្យាក្រឹតកាបូន និងភាពធន់នឹងអាកាសធាតុ ប្រកបដោយបរិយាបន្ន និងការអភិវឌ្ឍជាតិប្រកបដោយចីរភាព។

ក្នុងនាមក្រសួងបរិស្ថាន ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដឹកនាំរៀបចំ និងគាំទ្រចំពោះផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (២០២៤-២០៣៣)។

ខ្ញុំមានទំនុកចិត្តថា អង្គភាពក្រោមឱវាទក្រសួងបរិស្ថាននឹងសហការប្រកបដោយប្រសិទ្ធភាពជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីប្រែក្លាយផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០២៤-២០៣៣ ឱ្យទៅជាសកម្មភាពជាក់ស្តែងនៅទីវាល និងផ្តល់នូវអត្ថប្រយោជន៍ដល់ប្រជាជនកម្ពុជាគ្រប់ជំនាន់ ព្រមទាំងលើកកម្ពស់កិត្តិយសជាតិនៃភាពជាអ្នកដឹកនាំសកម្មភាពអាកាសធាតុរបស់កម្ពុជា នៅលើឆាកអន្តរជាតិ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ មីនា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**អ៊ាង សុផល្លែត**

# សេចក្តីថ្លែងអំណរគុណ

ការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០២៤-២០៣៣ ត្រូវបានសម្របសម្រួលដោយអគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រនៃក្រសួងបរិស្ថាន និងគាំទ្រដោយកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដំណាក់កាលទី៣( CCCA 3 ) ដែលជាកម្មវិធីផ្តល់មូលនិធិដោយសហភាពអឺរ៉ុប(EU) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិនៅកម្ពុជា UNDP Cambodia និងប្រទេសស៊ុយអែត។ ការរៀបចំយុទ្ធសាស្ត្រនេះក៏ទទួលបានការគាំទ្រពី មូលនិធិកុមារនៃអង្គការសហប្រជាជាតិ( UNICEF ) និងនាយកដ្ឋានកិច្ចការបរទេស និងពាណិជ្ជកម្មនៃរដ្ឋាភិបាលអូស្ត្រាលី( DFAT )។

សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះ **ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព **ឯកឧត្តមបណ្ឌិត ជួប ប៉ារីស៍** រដ្ឋលេខាធិការក្រសួងបរិស្ថានទទួលបន្ទុកអគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ **ឯកឧត្តម ស៊ុំ ធី** អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ និងក្រុមការងារបច្ចេកទេសបរិស្ថាននិងការប្រែប្រួលអាកាសធាតុ ដែលបានណែនាំ តម្រង់ទិស និងផ្តល់ការគាំទ្រជាបន្តបន្ទាប់រហូតដល់ ការរៀបចំផែនការយុទ្ធសាស្ត្រជាតិនេះទទួលបានជោគជ័យ។

សូមថ្លែងអំណរគុណដោយស្មោះស្ម័គ្រជូនចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការនៃក្រសួងបរិស្ថាន និងក្រសួងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ដូចជាអុកស្វាមអន្តរជាតិ ដែលបានផ្តល់ព័ត៌មាន និងទស្សនាទាន ក្នុងកំឡុងពេលសម្ភាសជាលក្ខណៈបុគ្គល និងការពិគ្រោះយោបល់លើវិធានការកាត់បន្ថយបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាឆ្នាំ២០២៤-២០៣៣ គឺជាលទ្ធផលនៃការងារយ៉ាងសកម្មដែលនឹងត្រូវធ្វើសមាហរណកម្មយ៉ាងទូលំទូលាយ ស្របតាមកាលៈទេសៈនៃការអភិវឌ្ឍរបស់កម្ពុជា។

## មាតិកា

**អារម្ភកថា** ........ IV
**សេចក្តីថ្លែងអំណរគុណ** ........ VI
**មាតិកា** ........ VII
**បញ្ជីតារាង** ........ IX
**បញ្ជីរូប** ........ X
**ពាក្យបំព្រួញ** ........ XI
**សេចក្តីសង្ខេប** ........ XIV
**១- សេចក្តីផ្តើម** ........ ១
១.១- ទិដ្ឋភាពទូទៅ ........ ១
១.២- បរិបទនិងហេតុផល ........ ២
១.៣- បរិបទសង្គម ........ ៤
*១.៣.១- លក្ខណៈភូមិសាស្ត្រ* ........ ៤
*១.៣.២- អាកាសធាតុ* ........ ៤
*១.៣.៣- ផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ* ........ ៤
*១.៣.៤- ការអភិវឌ្ឍសេដ្ឋកិច្ច* ........ ៥
*១.៣.៥- បរិបទកូវីដ១៩នៅកម្ពុជា* ........ ៥
*១.៣.៦- យេនឌ័រនិងការប្រែប្រួលអាកាសធាតុ* ........ ៦
*១.៣.៧- សកម្មភាពអាកាសធាតុ* ........ ៦
១.៤- ទស្សនវិស័យអភិវឌ្ឍន៍កម្ពុជា ........ ៨
*១.៤.១- ការព្យាករអំពីការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា* ........ ៨
*១.៤.២- របៀបវារៈនៃការស្តារសេដ្ឋកិច្ចកម្ពុជា* ........ ៩
**២- ចក្ខុវិស័យ** ........ ៩
**៣- បេសកកម្ម** ........ ៩
**៤- គោលបំណងនិងគោលដៅ** ........ ១០
**៥- ក្របខ័ណ្ឌយុទ្ធសាស្ត្រ** ........ ១០

៥.១- គោលដៅយុទ្ធសាស្ត្រ១ : ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់............................. ១២

*៥.១.១- លទ្ធផលយុទ្ធសាស្ត្រ* ............................................................................. ១៣

៥.២- គោលដៅវិស័យយុទ្ធសាស្ត្រ២ : ពង្រឹងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ............... ១៣

*៥.២.១- លទ្ធផលយុទ្ធសាស្ត្រ*............................................................................. ១៣

៥.៣- គោលដៅយុទ្ធសាស្ត្រ៣ : លើកស្ទួយអភិបាលកិច្ចល្អនិងបរិវត្តកម្មឌីជីថល(កត្តាជំរុញ) ............ ១៤

*៥.៣.១- លទ្ធផលយុទ្ធសាស្ត្រ*............................................................................. ១៤

**៦- សកម្មភាពការងារ**................................................................................. ១៤

៦.១- គោលដៅ សកម្មភាព និងធនធានសំខាន់ៗ ................................................... ១៤

៦.២- សកម្មភាព............................................................................................ ១៥

៦.៣- ការកំណត់ពេលវេលានិងគោលដៅ ............................................................. ១៥

៦.៤- ផែនការអនុវត្ត CCCSP ឆ្នាំ២០២៤-២០៣៣.................................................... ១៥

*៦.៤.១- ដំណាក់កាលទី១ : ក្នុងរយៈពេលបន្ទាន់ចំពោះមុខ(ឆ្នាំ២០២៤-២០២៨)*......... ៤៥

*៦.៤.២- ដំណាក់កាលទី២ : ក្នុងរយៈពេលមធ្យម(ឆ្នាំ២០២៩-២០៣៣)*.....................៤៧

៦.៥- ការរៀបចំស្ថាប័ន.................................................................................... ៥១

៦.៦- តម្រូវការហិរញ្ញវត្ថុនិងបច្ចេកវិទ្យា............................................................. ៥៣

*៦.៦.១- ការកៀរគរធនធានហិរញ្ញវត្ថុ*................................................................ ៥៤

**៧- ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ**(M&E) ........................................ ៥៦

៧.១- ការវាយតម្លៃលទ្ធផលផែនការយុទ្ធសាស្ត្រ CCCSP ឆ្នាំ២០១៤-២០២៣.............................. ៥៦

៧.២- ក្របខ័ណ្ឌតាមដានវាយតម្លៃសម្រាប់ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ឆ្នាំ២០២៤-២០៣៣ ................................................................. ៥៨

៧.៣- ការអនុវត្ត M&E.................................................................................. ៥៩

**៨- សេចក្តីសន្និដ្ឋាន** ................................................................................. ៦០

**ឧបសម្ព័ន្ធ** ............................................................ ៦១
ការប៉ាន់ប្រមាណថវិកាសម្រាប់សកម្មភាពលទ្ធផលជាយុទ្ធសាស្ត្រ ............................ ៦១
*ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់* ............................ ៦១
*ពង្រឹងសមត្ថភាពបន្សាំ* ............................ ៦៨
*អភិបាលកិច្ច/បរិវត្តកម្មឌីជីថល(កត្តាជំរុញ)* ............................ ៧៦

## បញ្ជីតារាង

តារាងទី១ : គោលដៅយុទ្ធសាស្ត្រ១ : ការកាត់បន្ថយ : ចំណុចដៅ សកម្មភាព និងធនធានសំខាន់ៗ.........១៧
តារាងទី២ : គោលដៅយុទ្ធសាស្ត្រ២ : ការបន្សាំ : ចំណុចដៅ សកម្មភាព និងធនធានសំខាន់ៗ ..............២៥
តារាងទី៣ : គោលដៅយុទ្ធសាស្ត្រ៣ : អភិបាលកិច្ច : ចំណុចដៅ សកម្មភាព និងធនធានសំខាន់ៗ ......... ៣៦
តារាងទី៤ : ដំណាក់កាលទី១ : កម្មវិធីរយៈពេលបន្ទាន់(ឆ្នាំ២០២៤-២០២៨)..................................៤៥
តារាងទី៥ : ដំណាក់កាលទី២ : កម្មវិធីសម្រាប់រយៈពេលមធ្យម(ឆ្នាំ២០២៩-២០៣៣) .........................៤៨
តារាងទី៦ : ប្រភពថវិកាដែលអាចមានសម្រាប់សកម្មភាពអាកាសធាតុ...........................................៥៤
តារាងទី៧ : សកម្មភាពកាត់បន្ថយ ប្រភពនៃការប៉ាន់ប្រមាណថវិកា..................................................៦១
តារាងទី៨ : សកម្មភាពបន្សាំ ប្រភពនៃការប៉ាន់ប្រមាណថវិកា .........................................................៦៨
តារាងទី៩ : សកម្មភាពកត្តាអំណោយផល ប្រភពនៃការប៉ាន់ប្រមាណថវិកា........................................៧៦

# បញ្ជីរូប


រូបទី១ : សេចក្តីសង្ខេបផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០២៤-២០៣៣ ................ xviii

រូបទី២ : ផែនទីប្រទេសកម្ពុជា ....................................................................................................៤

រូបទី៣ : CCCSP ឆ្នាំ២០២៤-២០៣៣ : វិស័យនិងលទ្ធផលជាយុទ្ធសាស្ត្រ ......................................១២

រូបទី៤ : ការរៀបចំស្ថាប័ន.........................................................................................................៥២

# ពាក្យបំព្រួញ

| | | |
|---|---|---|
| BTR | Biennial Transparency Report | របាយការណ៍តម្លាភាពពីរឆ្នាំម្តងស្តីពីការប្រែប្រួលអាកាសធាតុ |
| CCCSP | Cambodia Climate Change Strategic Plan | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា |
| CE | Circular Economy | សេដ្ឋកិច្ចចក្រា |
| COP | Conference of Parties | សន្និសីទបណ្តាភាគី |
| CPER | Cambodia Climate Public Expenditure Review | ការពិនិត្យចំណាយសាធារណៈលើការងារអាកាសធាតុកម្ពុជា |
| CSDG | Cambodia Sustainable Development Goals | គោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា |
| CSO | Civil Society Organization | អង្គការសង្គមស៊ីវិល |
| DP | Development Partners | ដៃគូអភិវឌ្ឍ |
| DRF | Disaster Risk Financing | ហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយ |
| DRR | Disaster risk resilience | ភាពធន់នឹងហានិភ័យគ្រោះមហន្តរាយ |
| ECCTWG | Environment and Climate Change Technical Working Group | ក្រុមការងារបច្ចេកទេសបរិស្ថាននិងការប្រែប្រួលអាកាសធាតុ |
| EE | Energy efficiency | ប្រសិទ្ធភាពថាមពល |
| ETF | Enhanced Transparency Framework | ក្របខ័ណ្ឌពង្រឹងតម្លាភាព |
| EV | Electric vehicle | យានយន្តអគ្គិសនី |
| EW4ALL | Early Warning for All | ប្រព័ន្ធប្រកាសដំណឹងជាមុនសម្រាប់ទាំងអស់គ្នា |
| FAO | Food and Agriculture Organisation | អង្គការស្បៀងនិងកសិកម្មសហប្រជាជាតិ |
| FIF | Financial intermediary fund | មូលនិធិហិរញ្ញវត្ថុអន្តរការី |
| FOLU | Forestry and Other Land Use | ព្រៃឈើនិងការប្រើប្រាស់ដី |
| GCF | Green Climate Fund | មូលនិធិអាកាសធាតុបៃតង |
| GDP | gross domestic product | ផលិតផលក្នុងស្រុកសរុប(ផ.ស.ស) |
| GEDSI | Gender Equality Disability and Social Inclusion | ពិការភាព សមភាពយេនឌ័រ និងបរិយាបន្នសង្គម |
| GHG | Greenhouse gas | ឧស្ម័នផ្ទះកញ្ចក់ |
| GPP | Green Public Procurement | លទ្ធកម្មសាធារណៈបៃតង |
| IHL | Institution of Higher Learning | វិទ្យាស្ថានឧត្តមសិក្សា |
| LTS4CN | Long-term Strategy for Carbon Neutrality | យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន |
| M&E | Monitoring and Evaluation | ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ |
| MAFF | Ministry of Agriculture, Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |

| | | |
|---|---|---|
| MISTI | Ministry of Industry, Science, Technology and Innovation | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| MLMUPC | Ministry of Land Management, Urban Planning and Construction | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| MLVT | Ministry of Labour and Vocational Training | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MME | Ministry of Mine and Energy | ក្រសួងរ៉ែនិងថាមពល |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MoH | Ministry of Health | ក្រសួងសុខាភិបាល |
| MoINFO | Ministry of Information | ក្រសួងព័ត៌មាន |
| MoP | Ministry of Planning | ក្រសួងផែនការ |
| MoSVY | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MoT | Ministry of Tourism | ក្រសួងទេសចរណ៍ |
| MoWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| MoWRAM | Ministry of Water Resource and Meteorology | ក្រសួងធនធានទឹកនិងឧតុនិយម |
| MPWT | Ministry of Public Work and Transportation | ក្រសួងសាធារណការនិងដឹកជញ្ជូន |
| MRC | Mekong River Commission | គណៈកម្មការទន្លេមេគង្គ |
| MRD | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| MRV | Monitoring, reporting and verification | ពិនិត្យតាមដាន រាយការណ៍ និងផ្ទៀងផ្ទាត់ |
| MSME | Micro, small and medium enterprises | សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម |
| MTR | Mid-term Review | ការពិនិត្យពាក់កណ្តាលអាណត្តិ |
| NAP | National Adaptation Plan | ផែនការជាតិបន្ស៊ាំ |
| NC | National Communication | របាយការណ៍ជាតិ |
| NCAP | National Cooling Action Plan | ផែនការសកម្មភាពសីតកម្មជាតិ |
| NCDD | National Committee for Sub-National Democratic Development | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCDM | National Committee Disaster Management | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NCSD | National Council for Sustainable Development | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NDCs | Nationally Determined Contributions | ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |
| NGOs | Non-Government Organization | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | National Institution of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| NSAF | National Social Assistance Fund (NSAF) | មូលនិធិជាតិគាំពារសង្គម |

| | | |
|---|---|---|
| NSCCC | National Steering Committee on Climate Change | គណៈកម្មាធិការជាតិដឹកនាំការងារប្រែប្រួលអាកាសធាតុ |
| NSDP | The National Strategy Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| NSPC | National Social Protection Council | ក្រុមប្រឹក្សាជាតិគាំពារសង្គម |
| PFM | Public Finance Management | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PIP | Public Investment Programme | កម្មវិធីវិនិយោគសាធារណៈ |
| RDF | Refuse derived fuel | ឥន្ធនៈផលិតចេញពីសំណល់ |
| RE | Renewable energy | ថាមពលកកើតឡើងវិញ |
| REDD+ | Reducing emissions from deforestation and forest degradation | ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់និងការរេចរឹលព្រៃឈើ |
| RGC | Royal Cambodian Government | រាជរដ្ឋាភិបាលកម្ពុជា |
| SBCC | Social behaviour change communication | ការប្រាស្រ័យទាក់ទងអំពីការកែប្រែឥរិយាបថសង្គម |
| SCP | Sustainable Consumption and Production | ការប្រើប្រាស់និងផលិតដោយនិរន្តរភាព |
| SNAPDRR | Strategic National Action Plan for Disaster Risk Reduction | ផែនការសកម្មភាពយុទ្ធសាស្ត្រជាតិកាត់បន្ថយហានិភ័យ |
| SRSP | Strengthening shock-responsive social protection | ការពង្រឹងកិច្ចគាំពារសង្គមឆ្លើយតបនឹងការប៉ះទង្គិច |
| STEM | Science, Technology, Engineering, and Mathematic | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា |
| SUP | Single Use Plastics | ប្លាស្ទិកដែលប្រើម្តងបោះចោល |
| UNDP | United Nations Development Programme | កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ |
| UNEP | United Nations Environment Programme | កម្មវិធីបរិស្ថានសហប្រជាជាតិ |
| UNFCCC | United Nations Framework Convention for Climate Change | អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| WASH | Water Sanitation and Hygiene | អនាម័យទឹកនិងភាពស្អាត |
| WFE | Water, Food and Energy | ទឹក ស្បៀងអាហារ និងថាមពល |
| WTE | Waste to energy | សំណល់ទៅជាថាមពល |

# សេចក្តីសង្ខេប

ព្រះរាជាណាចក្រកម្ពុជាមានសេដ្ឋកិច្ចចម្រុះ ដោយក្នុងនោះវិស័យកសិកម្ម ទេសចរណ៍ និងផលិតកម្ម បានដើរតួយ៉ាងសំខាន់។ គិតត្រឹមឆ្នាំ២០២២ ប្រទេសកម្ពុជាមានប្រជាជនចំនួន១៦,៨លាននាក់ ហើយនាពេលថ្មីៗនេះ បានជួបបញ្ហាប្រឈមជាច្រើន ជាពិសេស ផលប៉ះពាល់សេដ្ឋកិច្ចពីការរាតត្បាតនៃជំងឺកូវីដ១៩។ ទោះជាយ៉ាងណាក៏ដោយ ការព្រួយបារម្ភជាបន្ទាន់ជាងនេះឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ។ ដោយសារការពឹងផ្អែកលើឧស្សាហកម្មដែលងាយរងគ្រោះដោយសារអាកាសធាតុ ប្រទេសកម្ពុជាងាយរងគ្រោះ ជាពិសេសបណ្តាលមកពីផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ។ កម្ពុជាប្រឈមនឹងហានិភ័យសំខាន់ៗជាច្រើន ដែលរួមទាំងកត្តាដែលបង្កឡើងដោយកំណើនសីតុណ្ហភាព ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ និងកំណើននីវ៉ូទឹកសមុទ្រ។ ទោះបីជាមានកិច្ចប្រឹងប្រែងក្នុងការបន្សាំក៏ដោយ គេព្យាករថា កម្ពុជានឹងបាត់បង់ផ.ស.ស ប្រមាណ ៩,៨% នៅឆ្នាំ២០៥០ ដោយសារតែផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាលកម្ពុជា(RGC) បានចូលរួមក្នុងកិច្ចព្រមព្រៀងអាកាសធាតុអន្តរជាតិ និងបានបង្កើតគោលនយោបាយអាកាសធាតុជាច្រើន ដែលរួមទាំងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា(CCCSP) ឆ្នាំ២០១៤-២០២៣ និងផែនការបច្ចុប្បន្នភាព CCCSP ឆ្នាំ២០២៤-២០៣៣។

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាCCCSP ឆ្នាំ២០២៤-២០៣៣ មានបំណងដោះស្រាយបញ្ហាប្រឈមដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ បង្កើនភាពធន់ និងជំរុញការអភិវឌ្ឍដោយចីរភាព។ ផែនការនេះព្យាយាមធ្វើសមាហរណកម្មគោលនយោបាយជាតិ ដូចជាគោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា(CSDGs) យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ យុទ្ធសាស្ត្ររយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន(LTS4CN) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDP) ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ(NDC) និងដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងរបស់កម្ពុជាក្នុងការកសាងភាពធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ការរៀបចំ CCCSP ឆ្នាំ២០២៤-២០៣៣ បានរួមបញ្ចូលធាតុចូលពីក្រសួង ស្ថាប័នពាក់ព័ន្ធ នៅក្នុងកំឡុងពេលកិច្ចប្រជុំពិគ្រោះយោបល់ និងការសម្ភាស ដើម្បីធានាថា ផែនការយុទ្ធសាស្ត្រនេះមានភាពប្រទាក់ក្រឡា និងអាចអនុវត្តបានដោយក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

ផែនការយុទ្ធសាស្ត្រជាតិនេះ បង្ហាញអំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចប្រឹងប្រែងជាសកល ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ និងរួមចំណែកធ្វើឱ្យប្រទេសជាតិនិងពិភពលោកកាន់តែមាននិរន្តរភាពទៅអនាគត។

ចក្ខុវិស័យ បេសកកម្ម និងលទ្ធផលជាផែនការយុទ្ធសាស្ត្រCCCSP បច្ចុប្បន្នបានផ្អែកលើការវិភាគសមត្ថភាពស្ថាប័ន ការសង្កេតផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការព្យាករអំពីការប្រែប្រួលអាកាសធាតុក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងដំណើរការវិវត្តថ្មីៗលើសកម្មភាពអាកាសធាតុនិងការប្តេជ្ញាចិត្តជាធរមានក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ។ សកម្មភាពនៅក្រោមCCCSP ផ្តោតលើការកៀរគរធនធានឱ្យបានគ្រប់គ្រាន់និងដោះស្រាយភាពខ្វះចន្លោះខាងទិន្នន័យ ដើម្បីឱ្យកម្ពុជាឈានទៅជាសង្គមមួយដែលមានភាពធន់និងបញ្ចេញកាបូនទាប។

**ចក្ខុវិស័យ** : ឈានឆ្ពោះទៅអព្យាក្រឹតភាពកាបូននិងភាពធន់នឹងអាកាសធាតុ សំដៅចូលរួមចំណែកអភិវឌ្ឍជាតិប្រកបដោយចីរភាព។

**បេសកកម្ម** : បង្កើតក្របខ័ណ្ឌនៅថ្នាក់ជាតិដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ បង្កើនភាពធន់ និងកែលម្អអភិបាលកិច្ចអាកាសធាតុ ដើម្បីធានាសុខុមាលភាពសង្គម បរិស្ថាន និងសេដ្ឋកិច្ច។ ចំណុចនេះ រាប់បញ្ចូលទាំងការជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការអនុវត្តសកម្មភាពអាកាសធាតុប្រកបដោយភាពឆ្លាតវៃ។

**គោលបំណង** : លើកស្ទួយការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាបញ្ចេញកាបូនទាប និងពង្រឹងសមត្ថភាពភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រ ត្រូវបានបង្កើតឡើង ដើម្បីសម្រេចបានចក្ខុវិស័យ បេសកកម្ម និងគោលបំណង របស់ផែនការយុទ្ធសាស្ត្រ CCCSP ឆ្នាំ២០២៤-២០៣៣។

វិស័យ និងលទ្ធផលជាយុទ្ធសាស្ត្រ : កម្ពុជាបានបង្កើតផែនការយុទ្ធសាស្ត្រមួយចំនួនដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលរួមមានយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ឆ្នាំ២០២៣-២០២៨ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្ររយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន និងផែនការយុទ្ធសាស្ត្រ CCCSP ឆ្នាំ២០២៤-២០៣៣ បានផ្អែកលើកិច្ចប្រឹងប្រែងទាំងនេះកន្លងមក ដោយផ្តោតជាពិសេសលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ បង្កើនភាពធន់ និងការកែលម្អអភិបាលកិច្ចនិងបរិវត្តកម្មឌីជីថល។ គោលដៅជាយុទ្ធសាស្ត្រចំនួនបី ត្រូវបានកំណត់៖

**ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់** : បង្កើនល្បឿនអភិវឌ្ឍន៍ថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល ឧស្សាហកម្មបៃតង កាត់បន្ថយការពឹងផ្អែកលើឥន្ធនៈផូស៊ីល អនុវត្តគោលការណ៍សេដ្ឋកិច្ចចក្រា ដើម្បីដោះស្រាយការបំពុល ការកសាងប្រព័ន្ធគ្រប់គ្រងទឹក និងសំណល់ដោយនិរន្តរភាព ពង្រីកលំហបៃតងក្នុងទីក្រុង បញ្ឈប់ការកាប់បំផ្លាញព្រៃឈើ និងលើកកម្ពស់ការដាំដើមឈើនិងព្រៃឈើឡើងវិញ ដើម្បីធានាចីរភាពបរិស្ថាន។

**ពង្រឹងការបន្សាំនិងភាពធន់នឹងការប្រែប្រួលអាកាសធាតុ** : ពង្រឹងគោលនយោបាយជាតិ ដែលទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ការអនុវត្តកសិកម្មឆ្លាតវៃខាងអាកាសធាតុ ការអភិរក្សប្រព័ន្ធអេកូឡូស៊ី និង GEDSI សំខាន់ៗ ដើម្បីពង្រឹងភាពធន់នៃក្រុមងាយរងគ្រោះ(ស្ត្រី មនុស្សចាស់ សហគមន៍មូលដ្ឋាន។ល។)។

**លើកស្ទួយអភិបាលកិច្ចល្អនិងបរិវត្តកម្មឌីជីថល** : ពង្រឹងស្ថាប័នជាតិនិងបង្កើនកិច្ចសហប្រតិបត្តិការជាមួយគ្រប់ក្រសួង ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការលើកកម្ពស់យន្តការហិរញ្ញវត្ថុ ការប្រាស្រ័យទាក់ទង ការយល់ដឹងនៅគ្រប់ស្ថាប័ន និងកម្រិតនៃសង្គម ការកសាងសមត្ថភាព ជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ និងភាពជាដៃគូក្នុងតំបន់ ការដោះស្រាយគម្លាតខាងព័ត៌មាន និងការពង្រឹងការងារពិនិត្យតាមដាននិងការវាយតម្លៃ។ ផែនការCCCSP ឆ្នាំ២០២៤-២០៣៣ មានគោលបំណងអនុវត្តយុទ្ធសាស្ត្រទាំងនេះជាពីរដំណាក់កាល៖

ដំណាក់កាលទី១ : រយៈពេលបន្ទាន់ចំពោះមុខ ឆ្នាំ២០២៤-២០២៨ ដោយផ្តោតលើការបង្កើនល្បឿននៃការអនុវត្តវិធានការអភិបាលកិច្ច ដែលទាក់ទងនឹងសមត្ថភាពមនុស្ស ការលើកកម្ពស់ GEDSI ការគ្រប់គ្រងធនធានធម្មជាតិឱ្យមាននិរន្តរភាព លើកកម្ពស់ការយល់ដឹង និងការដោះស្រាយគម្លាតខាងទិន្នន័យ។

ដំណាក់កាលទី២ : រយៈពេលមធ្យម ឆ្នាំ២០២៩-២០៣៣ ផ្តោតលើការពង្រឹងនិងបញ្ចូលកម្មវិធីសំខាន់ៗ ដែលមានបំណងលើកកម្ពស់កំណើនបៃតង ជំរុញ GEDSI ពង្រឹងសុខភាពសាធារណៈ និងពង្រីកកិច្ចផ្តួចផ្តើម ដែលធន់នឹងអាកាសធាតុនៅទូទាំងវិស័យសេដ្ឋកិច្ចសំខាន់ៗ។ កំឡុងពេលនេះ ក៏រួមបញ្ចូលផងដែរនូវការកៀរគរហិរញ្ញប្បទានអាកាសធាតុ ការពង្រីកវិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការពង្រីកការអនុវត្តការងារគ្រប់គ្រងសំណល់ប្រកបដោយនិរន្តរភាព។

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា( CCCSP) ឆ្នាំ២០២៤-២០៣៣ បង្ហាញវិធីសាស្ត្រទូលំទូលាយមួយក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ អង្គភាពដែលមានស្រាប់ ដូចជាក្រុមការងារបច្ចេកទេសបរិស្ថាននិងការប្រែប្រួលអាកាសធាតុ( ECCTWG )នៃក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព( NCSD )នឹងបន្តសម្របសម្រួលកិច្ចសហប្រតិបត្តិការ។ ផែនការនេះក៏អំពាវនាវឱ្យពង្រឹងយន្តការសម្របសម្រួលតាមក្រសួង ស្ថាប័នដែលមានស្រាប់ ដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងអាណត្តិរបស់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ។

ដើម្បីធានាឱ្យការអនុវត្តទទួលជោគជ័យ CCCSPនឹងផ្តល់អាទិភាពសម្រាប់ការផ្តល់ហិរញ្ញប្បទានចម្រុះតាមរយៈថវិការបស់រដ្ឋាភិបាល ជំនួយអន្តរជាតិ ភាពជាដៃគូទ្វេភាគី ការវិនិយោគនៃវិស័យឯកជន និងសញ្ញាបណ្ណបៃតងប្រកបដោយភាពច្នៃប្រឌិត។ ការកសាងភាពជាដៃគូរឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍកម្លាំងពលកម្មជំនាញក៏ជាកត្តាសំខាន់ផងដែរ។ ចំណុចនេះរួមបញ្ជ្រាបទាំងការផ្តោតលើការអប់រំSTEMនិងការពង្រឹងភាពអង់អាចរបស់ស្ត្រី ដើម្បីឱ្យចូលរួមក្នុងវិស័យទាំងនេះ ដែលកត្តាទាំងពីរនេះមានសារៈសំខាន់ក្នុងការបញ្ចេញកាបូនតិចនាពេលអនាគត។

ដោយទទួលស្គាល់ពីសារៈសំខាន់នៃការកែលម្អជាបន្តបន្ទាប់ CCCSPនឹងបង្កើតក្របខ័ណ្ឌពិនិត្យតាមដាននិងវាយតម្លៃដ៏រឹងមាំមួយ។ ក្របខ័ណ្ឌនេះនឹងតាមដានវឌ្ឍនភាព ធានាការទទួលខុសត្រូវ និងជូនដំណឹងអំពីយុទ្ធសាស្ត្រនាពេលអនាគត។ ក្របខ័ណ្ឌនេះនឹងធានាអនុលោមភាពជាមួយប្រព័ន្ធជាតិ និងការប្តេជ្ញាចិត្តជាអន្តរជាតិ ដូចជាកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់ការសិក្សាដោយមានការចូលរួម និងការបញ្ជ្រាបការពិចារណាអំពីយេនឌ័រ។ ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃជាទៀងទាត់ នឹងត្រូវធ្វើឡើង ដើម្បីវាយតម្លៃវឌ្ឍនភាពនិងអនុញ្ញាតឱ្យមានការកែតម្រូវតាមការចាំបាច់។ ជារួមយុទ្ធសាស្ត្រ CCCSP ឆ្នាំ២០២៤-២០៣៣ ផ្តល់កិច្ចប្រឹងប្រែងជាយុទ្ធសាស្ត្រនិងសម្របសម្រួល ក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ឈានឆ្ពោះទៅធ្វើឱ្យប្រទេសកម្ពុជាស្អាត បៃតង និងមានចីរភាព។

| គោលដៅយុទ្ធសាស្ត្រ | ១- ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ | ២- ពង្រឹងការបន្សាំនឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ | ៣- លើកស្ទួយអភិបាលកិច្ចល្អនិងបរិវត្តកម្មឌីជីថល |
|---|---|---|---|
| លទ្ធផលយុទ្ធសាស្ត្រ | ១.១- បង្កើនការរួមចំណែកនៃថាមពលកកើតឡើងវិញ(RE) នៅក្នុងល្បាយថាមពលជាតិ និងការប្រើប្រាស់RE នៅក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ(ដឹកជញ្ជូន កសិកម្ម ទេសចរណ៍ ផលិតកម្ម។ល។) ទន្ទឹមនឹងកាត់បន្ថយការពឹងផ្អែកលើឥន្ធនៈផូស៊ីល។ | ២.១- ពង្រឹងវិធានការបង្កើនភាពធន់នៅគ្រប់វិស័យសេដ្ឋកិច្ច និងសេវាសង្គមសំខាន់ៗ (សេវាកម្មទឹកស្អាត អគ្គិសនី អនាម័យ ការថែទាំសុខភាព អាហារូបត្ថម្ភ ការអប់រំ សង្គម និងកិច្ចគាំពារកុមារ ទេសចរណ៍ ប្រព័ន្ធស្បៀងអាហារដែលមាននិរន្តរភាព និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជាWASH ថាមពល ផ្លូវថ្នល់។ល។) ដោយផ្តោតជាពិសេស លើតម្រូវការរបស់កុមារ និងសហគមន៍ដែលងាយរងគ្រោះបំផុត។ | ៣.១- ពង្រឹងយន្តការហិរញ្ញវត្ថុអាកាសធាតុ។ |
| | ១.២- បង្កើនប្រសិទ្ធភាពថាមពល(EE) និងថាមពលកកើតឡើងវិញ(RE) នៅក្នុងការដំឡើង អគារ លំនៅឋាន និងការដឹកជញ្ជូន (ការដឹកជញ្ជូនសាធារណៈ រថយន្តអគ្គិសនី)។ | ២.២- បង្កើនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការត្រៀមបង្ការ និងការស្តារឡើងវិញនៅទូទាំងសហគមន៍(តំបន់ឆ្នេរ បឹងទន្លេសាប និងសហគមន៍តាមដងទន្លេមេគង្គ)។ | ៣.២- បង្កើនលទ្ធភាពប្រើប្រាស់និងការអប់រំព័ត៌មានដែលផ្តោតចំគោលដៅ ការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាលអំពីការប្រែប្រួលអាកាសធាតុ។ |
| | ១.៣- ពង្រឹងការអនុវត្តសេដ្ឋកិច្ចចក្រា(CE) និងទប់ស្កាត់ការបំពុល ក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ(ទេសចរណ៍ កសិកម្ម សំណង់ ការផលិត ការដឹកជញ្ជូន។ល។)។ | ២.៣- ពង្រឹងការអភិរក្សប្រព័ន្ធអេកូឡូស៊ី និងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព (រួមទាំងទន្លេមេគង្គ បឹងទន្លេសាប ព្រៃឈើ ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ីទីក្រុង និងបញ្ជ្រាបដំណោះស្រាយ និងការបន្សាំដោយផ្អែកតាមធម្មជាតិ)។ | ៣.៣- ពង្រឹងកម្លាំងពលកម្មបច្ចុប្បន្ននិងអនាគត ដើម្បីឈានឆ្ពោះទៅអន្តរកាលកាបូនតិចនិងដែលធន់។ |
| | ១.៤- ពង្រឹងធនធានទឹកនិងការផ្គត់ផ្គង់ដែលធន់និងមាននិរន្តរភាព ប្រព័ន្ធនិងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំណល់រឹង និងសំណល់រាវ (ឈានទៅស្ថានភាពគ្មានសំណល់ បញ្ឈប់ការប្រើប្រាស់ប្លាស្ទិកតែមួយលើកហើយបោះចោល(SUP)) បង្កើនជម្រើសជំនួស SUP ប្រែក្លាយសំណល់ទៅជាថាមពល(WTE) សំណល់ក្នុងវិស័យកាត់ដេរ ទឹកក្រោមដី និងធនធានទឹកលើដី។ល។)។ | ២.៤- ពង្រឹងភាពធន់នៃក្រុមជនដែលងាយរងគ្រោះ(ដូចជាកុមារនិងសហគមន៍មូលដ្ឋាន) និងបញ្ជ្រាប GEDSI ទៅក្នុងសកម្មភាពដោះស្រាយបញ្ហាអាកាសធាតុនិងភាពធន់។ | ៣.៤- ពង្រឹងការចូលរួមពីភាគីពាក់ព័ន្ធនានា និងការចូលរួមក្នុងការអនុវត្តយុទ្ធសាស្ត្រ។ |

| | | | |
|---|---|---|---|
| | ១.៥- បង្កើនទំហំនៃលំហបៃតងក្នុងទីក្រុង និងទីក្រុងបៃតង ដោយលើកកម្ពស់ការប្រើប្រាស់ដំណោះស្រាយផ្អែកលើធម្មជាតិ។ | ២.៥- ពង្រឹងវិធានការនិរន្តរភាពនិងភាពធន់ (រួមទាំង បច្ចេកវិទ្យាឆ្លាតវៃខាងអាកាសធាតុ កសិកម្មដែលស្តារគុណភាពដីឡើងវិញ)។ | ៣.៥- ពង្រឹងលទ្ធភាពទទួលបានជំនួយបច្ចេកទេសសម្រាប់ការកសាងសមត្ថភាពពហុភាគី។ |
| | ១.៦- បង្កើនគម្របព្រៃឈើនិងបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ(រួមទាំងបង្កើនការវិនិយោគនៃវិស័យឯកជននិងការចូលរួមក្នុងFOLU ការបង្កើតស្តង់ដាពាក់ព័ន្ធ និងគោលការណ៍ណែនាំ។ល។)។ | ២.៦- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធនិងការកសាងភាពធន់ និងចីរភាពបរិស្ថាន (រួមទាំងពង្រីកការអនុវត្តស្តង់ដាអគារបៃតង ការរចនាអគារដែលរក្សាភាពត្រជាក់ លេខកូដអគារ ហេដ្ឋារចនាសម្ព័ន្ធបៃតងនិងប្រផេះ។ល។)។ | ៣.៦- ដោះស្រាយគម្លាតទិន្នន័យនិងព័ត៌មានសម្រាប់ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃប្រកបដោយប្រសិទ្ធភាព។ |
| | | | ៣.៧- ពង្រឹងកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូក្នុងតំបន់ និងអន្តរជាតិ(រួមទាំង អាស៊ាន គណៈកម្មការទន្លេមេគង្គ កិច្ចផ្តួចផ្តើមសហប្រតិបត្តិការមេគង្គ ទីភ្នាក់ងារនៃអង្គការសហប្រជាជាតិ មូលនិធិហិរញ្ញវត្ថុអាកាសធាតុ ធនាគារអភិវឌ្ឍន៍ និងទីភ្នាក់ងារអភិវឌ្ឍន៍)។ |
| | | | ៣.៨- រៀបចំផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តបរិវត្តកម្មឌីជីថលក្នុងការងារបរិស្ថាន និងប្រែប្រួលអាកាសធាតុ |

*រូបទី១ : សេចក្តីសង្ខេបផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០២៤-២០៣៣*

# ១- សេចក្តីផ្តើម

## ១.១- ទិដ្ឋភាពទូទៅ

ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុតនៅក្នុងតំបន់ ដោយសារតែការប្រែប្រួលអាកាសធាតុនិងការប្រឈមជាខ្លាំងចំពោះបញ្ហានានាបណ្តាលពីការប្រែប្រួលអាកាសធាតុ។ ទន្ទឹមនឹងកំណើនសេដ្ឋកិច្ចគួរឱ្យចាប់អារម្មណ៍ កម្ពុជាកំពុងប្រឈមមុខនឹងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់កាន់តែច្រើនឡើងៗ ដែលកើតចេញពីសកម្មភាពអភិវឌ្ឍន៍យ៉ាងឆាប់រហ័ស។ មានការព្យាករណ៍ថា ទោះបីជាកំណើនសីតុណ្ហភាពពិភពលោកនៅក្រោមកម្រិត២អង្សាសែលស៊ុស ហើយរាជរដ្ឋាភិបាលរក្សាកម្រិតបច្ចុប្បន្ននៃការវិនិយោគលើការបន្សាំនឹងអាកាសធាតុក៏ដោយ នៅឆ្នាំ២០៥០ ប្រទេសកម្ពុជានឹងបាត់បង់ផ.ស.ស ប្រមាណ៩,៨%(MEF, 2019)។ ទោះជាមានវិធានការនិងកម្មវិធីបន្សាំនឹងអាកាសធាតុក៏ដោយ សហគមន៍ដែលងាយរងគ្រោះនិងតំបន់ងាយរងគ្រោះក្នុងប្រទេសកម្ពុជាមានហានិភ័យនៃការប្រឈមនឹងផលវិបាកនៃការប្រែប្រួលអាកាសធាតុ ហួសពីអ្វីដែលមនុស្សអាចបន្សាំបាន ឧទាហរណ៍ ការបាត់បង់មុខរបរចិញ្ចឹមជីវិតនិងផ្ទះសំបែង ក្នុងកំឡុងពេលទឹកជំនន់ខ្លាំង។[1]

រាជរដ្ឋាភិបាលកម្ពុជា(RGC) បានអនុវត្តវិធានការបន្សាំនិងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាច្រើនតាមរយៈការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រសំខាន់ៗស្តីពីការប្រែប្រួលអាកាសធាតុ។ កម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីប្រែប្រួលអាកាសធាតុ និងបំពេញការប្តេជ្ញាចិត្តស្របតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ។

យោងតាមផែនការជាតិអភិវឌ្ឍន៍ដោយចីរភាព(NSDP) ការអភិវឌ្ឍនៅថ្នាក់ជាតិរបស់កម្ពុជា ផ្តោតលើការកាត់បន្ថយភាពក្រីក្រ និងការសម្រេចបាននូវស្ថានភាពចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ រាជរដ្ឋាភិបាលបានរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាដំណាក់កាលទី១ ឆ្នាំ២០១៤-២០២៣ និងផែនការសកម្មភាពពាក់ព័ន្ធ ដែលជាក្របខ័ណ្ឌអន្តរវិស័យឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ។ ផែនការយុទ្ធសាស្ត្រនេះមានបំណងបង្កើតភាពស៊ីចង្វាក់គ្នាជាមួយឯកសារគោលនយោបាយរបស់រដ្ឋាភិបាលដែលមានស្រាប់ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDP) យុទ្ធសាស្ត្រចតុកោណ គោលនយោបាយជាតិអភិវឌ្ឍន៍បៃតង និងផែនការអភិវឌ្ឍន៍តាមវិស័យ។

កិច្ចខិតខំប្រឹងប្រែងនាពេលថ្មីៗនេះ ដូចជាផែនការបច្ចុប្បន្នភាពជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ(Updated NDC) យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ឆ្នាំ២០២៣-២០២៨ យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន(LTS4CN) តម្រូវឱ្យធ្វើបច្ចុប្បន្នភាព CCCSP ជាដើម។ គេរំពឹងថា CCCSP ឆ្នាំ២០២៤-២០៣៣ នឹងបង្កើនល្បឿន និងជួយបំពេញបន្ថែមដល់ការអនុវត្តយុទ្ធសាស្ត្រដែលបានរៀបរាប់ខាងលើពោលគឺផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា(CSDGs) និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១។

---

[1] ក្នុងករណីដែលឥទ្ធិពលអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុនៅតែកើតឡើង ទោះបីជាមានការកាត់បន្ថយនិងកិច្ចប្រឹងប្រែងបន្សាំក៏ដោយ ស្ថានភាពនេះត្រូវបានគេឱ្យឈ្មោះថា ការបាត់បង់និងការខូចខាត(ដែលទាក់ទងនឹងផលប៉ះពាល់ដែលមិនអាចជៀសវាងបាននិងមិនអាចត្រឡប់វិញបាននៃវិបត្តិអាកាសធាតុ) About Loss and damage | UNEP - UN Environment Programme

## ១.២- បរិបទនិងហេតុផល

សេដ្ឋកិច្ចនិងការរីកចម្រើនរបស់កម្ពុជា ត្រូវបានជំរុញដោយវិស័យសេដ្ឋកិច្ចសំខាន់ៗ ដូចជាកសិកម្ម ទេសចរណ៍ ព្រៃឈើ នេសាទ ធនធានទឹកជាដើម ដែលជាវិស័យពឹងផ្អែកលើលក្ខខណ្ឌអាកាសធាតុ។ ទន្ទឹមនឹងភាពងាយរងគ្រោះរបស់ប្រជាជន ហេដ្ឋារចនាសម្ព័ន្ធក៏រួមចំណែកធ្វើឱ្យប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលរងផលប៉ះពាល់យ៉ាងខ្លាំងបណ្តាលមកពីការប្រែប្រួលអាកាសធាតុផងដែរ។

ផែនការ ដូចជា LTS4CN NDC គោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ឆ្នាំ២០២៣-២០២៨ជាដើម គឺជាភស្តុតាងនៃមហិច្ឆតារបស់រាជរដ្ឋាភិបាលកម្ពុជា ឆ្ពោះទៅអនុវត្តសកម្មភាពអាកាសធាតុ។ ការពង្រឹងទំនាក់ទំនងរវាងគ្នាកាន់តែខ្លាំងក្លា និងក្របខ័ណ្ឌស្តីពីការប្រែប្រួលអាកាសធាតុ អាចបង្កើនប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយទាំងនេះ និងការកៀរគរធនធានឱ្យបានទាន់ពេលវេលានិងគ្រប់គ្រាន់ និងសមត្ថភាពបច្ចេកវិទ្យា។

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា(CCCSP) ឆ្នាំ២០២៤-២០៣៣ មានគោលដៅដោះស្រាយបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ បង្កើនល្បឿននៃសកម្មភាពដោះស្រាយបញ្ហាអាកាសធាតុ លើកកម្ពស់ការសម្របសម្រួលអន្តរស្ថាប័ននិងបរិយាបន្នកាន់តែច្រើនជាងមុន ពង្រីកការកៀរគរធនធានប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលសម្រាប់ការបង្កើនភាពធន់ និងសមត្ថភាពបន្សុាំ ទន្ទឹមនឹងលើកកម្ពស់ការអភិវឌ្ឍដោយចីរភាពនៅក្នុងប្រទេស។

ការបង្កើត CCCSP ឆ្នាំ២០២៤-២០៣៣ ផ្អែកលើការវាយតម្លៃទិន្នន័យអាកាសធាតុ កំណត់បញ្ហាប្រឈមសំខាន់ៗដែលទាក់ទងនឹងអាកាសធាតុនិងការយល់ដឹងពីផលប៉ះពាល់សេដ្ឋកិច្ចសង្គមនៃការប្រែប្រួលអាកាសធាតុមកលើប្រជាជនកម្ពុជា។ ការបង្កើតយុទ្ធសាស្ត្រនេះបានឆ្លងកាត់ការពិគ្រោះជាមួយភាគីពាក់ព័ន្ធយ៉ាងទូលំទូលាយ និងបានផ្អែកលើការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រជាតិសំខាន់ៗ ដូចជា៖

១- យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ឆ្នាំ២០២៣។
២- យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ឆ្នាំ២០២៣-២០២៨។
៣- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣។
៤- យុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន(LTS4CN) ឆ្នាំ២០២១។
៥- ផែនការបច្ចុប្បន្នភាពជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ(Updated NDC) ឆ្នាំ២០២០។

សមិទ្ធផលយុទ្ធសាស្ត្រពឹងផ្អែកលើការបញ្ជូលគោលនយោបាយនិងយុទ្ធសាស្ត្រជាតិដែលបានរៀបរាប់ខាងលើ និងយុទ្ធសាស្ត្រតាមវិស័យផ្សេងទៀត។ យុទ្ធសាស្ត្រជាតិដែលមានស្រាប់នៃប្រទេសជិតខាងជាសមាជិកអាស៊ាន (ដូចជាប្រទេសថៃ សិង្ហបុរី វៀតណាមជាដើម) ឧបករណ៍និងសកម្មភាពអន្តររដ្ឋាភិបាលអន្តរជាតិ(ដូចជា របាយការណ៍ការវាយតម្លៃការអនុវត្តNDCជាសកល របាយការណ៍តម្លាភាពពីរឆ្នាំម្តង មូលនិធិការបាត់បង់និងការខូចខាតជាដើម) ក៏ត្រូវបានយកមកប្រើប្រាស់ផងដែរ ដើម្បីធានាថាCCCSP ឆ្នាំ២០២៤-២០៣៣ ឆ្លើយតបនឹងនិន្នាការក្នុងតំបន់និងអន្តរជាតិ និងសកម្មភាពដោះស្រាយបញ្ហាអាកាសធាតុ។ វិធីសាស្ត្រទូលំទូលាយនេះជួយធានាឱ្យមានការឆ្លើយតបយ៉ាងជិតស្និទ្ធ ប្រកបដោយប្រសិទ្ធភាពនិងយ៉ាងរលូនទៅនឹងការប្រែប្រួលអាកាសធាតុ ទន្ទឹមនឹងជំរុញឱ្យមានកំណើនសេដ្ឋកិច្ចដោយនិរន្តរភាព និងកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិ។

ផែនការយុទ្ធសាស្ត្រនេះ ផ្តោតអាទិភាពលើវិធានការបន្សាំ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាអាទិភាព ដូចជាការកែលម្អការគ្រប់គ្រងទឹក ការលើកកម្ពស់ការអភិរក្សព្រៃឈើ ការលើកកម្ពស់កសិកម្មដែលមាននិរន្តរភាព ការវិនិយោគលើប្រភពថាមពលកកើតឡើងវិញជាដើម។ ការគំរាមកំហែងដោយសារព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរបណ្តាលពីការប្រែប្រួលអាកាសធាតុអាចនឹងកើនឡើង ហេតុនេះការរៀបចំប្រព័ន្ធប្រកាសឱ្យដឹងជាមុន អាចការពារអាយុជីវិតមនុស្សនិងទ្រព្យសម្បត្តិពីគ្រោះមហន្តរាយដែលកើតមានឡើង។ ការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធរួមជាមួយសហគមន៍ដែលមានហានិភ័យឬងាយរងគ្រោះ នឹងជួយបង្កើនភាពធន់ទៅនឹងព្រឹត្តិការណ៍ធ្ងន់ធ្ងរទាំងនេះ។[2] លើសពីនេះ យុទ្ធសាស្ត្រនេះសង្កត់ធ្ងន់លើការកសាងសមត្ថភាពនិងការចែករំលែកចំណេះដឹងក្នុងចំណោមស្ថាប័នពាក់ព័ន្ធ សហគមន៍មូលដ្ឋាន អ្នករៀបចំគោលនយោបាយ និងអ្នកពាក់ព័ន្ធ ដើម្បីធានានូវការអនុវត្តសកម្មភាពដែលបានស្នើឡើងប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាពយូរអង្វែង។

កិច្ចសហប្រតិបត្តិការជាមួយដៃគូអន្តរជាតិនិងការកៀរគរហិរញ្ញប្បទានអាកាសធាតុ មានសារៈសំខាន់ណាស់ក្នុងការគាំទ្រដល់កិច្ចប្រឹងប្រែងរបស់កម្ពុជា ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ ផែនការយុទ្ធសាស្ត្រ CCCSP ឆ្នាំ២០២៤-២០៣៣ ផ្អែកលើសមិទ្ធផលនិងបទពិសោធដែលទទួលបានពីការអនុវត្តយុទ្ធសាស្ត្រកាលពីទសវត្សមុន ដោយធានានូវការឆ្លើយតបប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផលជាងមុន នៅចំពោះមុខបញ្ហាប្រឈមដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ CCCSP ឆ្នាំ២០២៤-២០៣៣ នឹងជួយកម្ពុជាធ្វើការបន្សាំទៅនឹងការគំរាមកំហែង និងកាលានុវត្តភាពដែលកំពុងកើតមានដោយសារការវិវត្តនៃស្ថានភាពប្រែប្រួលអាកាសធាតុពិភពលោក ដូចជាកំណើនកម្ពស់ទឹកសមុទ្រ ការកើនឡើងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ ការផ្លាស់ប្តូរទម្លាប់នៃការអនុវត្តកសិកម្ម ការទទួលបានបច្ចេកវិទ្យាទំនើបចុងក្រោយបំផុត ហិរញ្ញប្បទានអាកាសធាតុជាដើម។

ផែនការ CCCSP ឆ្នាំ២០២៤-២០៣៣ ផ្តល់យុទ្ធសាស្ត្រច្បាស់លាស់និងបច្ចុប្បន្នភាព ដែលអាចឱ្យកម្ពុជារៀបចំផែនការនិងកៀរគរធនធានគ្រប់គ្រាន់ និងពង្រឹងសមត្ថភាពបច្ចេកទេស ឆ្ពោះទៅអនុវត្តសកម្មភាពដោះស្រាយបញ្ហាអាកាសធាតុ ប្រកបដោយប្រសិទ្ធភាព។ ផែនការនេះក៏នឹងបន្តកៀរគរការគាំទ្រនិងការវិនិយោគអន្តរជាតិ លើសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលនឹងមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍប្រទេសដោយចីរភាព។

ផែនការយុទ្ធសាស្ត្រនេះបង្ហាញទិសដៅលើកកម្ពស់ការសម្របសម្រួលអន្តរស្ថាប័នឱ្យមានភាពរលូន បង្កើនល្បឿននៃការគ្រប់គ្រងការវិនិយោគសាធារណៈដែលកាន់តែឆ្លើយតបនឹងបញ្ហាអាកាសធាតុ និងផ្តល់ការណែនាំសម្រាប់សកម្មភាពដោះស្រាយបញ្ហាអាកាសធាតុ នៅក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ ទន្ទឹមនឹងការបញ្ជ្រាប GEDSI ផ្អែកលើគោលការណ៍ ដោយមិនទុកនរណាម្នាក់ចោលឡើយ។

[2] ត្រូវគេស្គាល់ផងដែរថា ជាសកម្មភាពដែលគ្រោងទុកជាមុនឬសកម្មភាពផ្អែកលើការព្យាករណ៍ មានន័យថា ការចាត់វិធានការដើម្បីការពារមនុស្ស មុនគ្រោះមហន្តរាយកើតឡើង ដោយផ្អែកលើការព្រមានឬការព្យាករជាមុន។ (សហព័ន្ធកាកបាទក្រហមអន្តរជាតិ-IFRC)

## ១.៣- បរិបទសង្គម

### ១.៣.១- លក្ខណៈភូមិសាស្ត្រ




*រូបទី២ : ផែនទីប្រទេសកម្ពុជា*

ប្រទេសកម្ពុជាមានលក្ខណៈភូមិសាស្ត្រជាដីទំនាប អាកាសធាតុខ្យល់មូសុងត្រូពិក ដោយមានទន្លេ មេគង្គនិងតំបន់ឆ្នេរដ៏ធំទូលាយ។ ប្រហែល ៨០% នៃផ្ទៃប្រទេសស្ថិតក្នុងអាងទន្លេមេគង្គ(MRB) ដែលមានការជន់លិចប្រចាំឆ្នាំនិងដីល្បាប់ដែលមានសារៈសំខាន់សម្រាប់ការធ្វើកសិកម្មនិងនេសាទ។ កម្ពុជានៅតែជាប្រទេសមួយដែលមានគម្របព្រៃឈើច្រើនជាងគេក្នុងតំបន់(MoE, 2022)។

### ១.៣.២- អាកាសធាតុ

អាកាសធាតុនៅកម្ពុជាទទួលឥទ្ធិពលពីរបបខ្យល់មូសុងត្រូពិក ដែលបង្កើតឱ្យមានរដូវពីរខុសគ្នា គឺរដូវវស្សា និងរដូវប្រាំង និងឥទ្ធិពលពីទីតាំងដែលស្ថិតនៅជិតខ្សែអេក្វាទ័រ និងសណ្ឋានដី។ ជារៀងរាល់ឆ្នាំ សីតុណ្ហភាព និងសំណើមអាកាស មានកម្រិតខ្ពស់ចាប់ពី២៣°C ដល់៣៥°C (៧៣°F ដល់ ៩៥°F)។ រដូវវស្សាចាប់ផ្តើមពីខែឧសភាដល់ខែតុលា នាំមកនូវទឹកធ្លាក់យ៉ាងច្រើន និងការជន់លិចម្តងម្កាល ដោយសារខ្យល់មូសុងនិរតី ចំណែក រដូវប្រាំងចាប់ពីខែវិច្ឆិកា ដល់ខែមេសា មានសីតុណ្ហភាពត្រជាក់ជាងនិងមានភ្លៀងធ្លាក់តិចតួចជាងរដូវវស្សា។ យោងតាមសន្ទស្សន៍ហានិភ័យ INFORM ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ជាប្រទេសដែលរងគ្រោះដោយទឹកជំនន់ខ្លាំងបំផុតទីបួនលើពិភពលោក។ តំបន់ទំនាបទន្លេមេគង្គនិងបឹងទន្លេសាប[3] ប្រឈមនឹងកម្រិតខ្ពស់នៃជំនន់ទឹកទន្លេ (World Bank, 2023)។ ប្រទេសកម្ពុជាក៏ប្រឈមនឹងគ្រោះទឹកជំនន់គំហុកផងដែរ បន្ទាប់ពីមានភ្លៀងធ្លាក់ខ្លាំង ជាពិសេសក្នុងកំឡុងពេលមានព្យុះស៊ីក្លូនត្រូពិក នៅរដូវវស្សា។

### ១.៣.៣- ផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ

ក្រៅពីស្ថិតក្នុងចំណោមប្រទេសដែលប្រឈមបំផុតដោយសារគ្រោះទឹកជំនន់ កម្ពុជាក៏ជួបប្រទះកំណើនសីតុណ្ហភាពមធ្យមខ្ពស់បំផុតលើពិភពលោកផងដែរ ដែលជាមធ្យមមានប្រមាណ៦៤ថ្ងៃ ក្នុងមួយឆ្នាំ នៅពេលដែលសីតុណ្ហភាពអតិបរមាមានលើស៣៥°C។ ស្ថានភាពនេះធ្វើឱ្យកម្ពុជាស្ថិតក្នុងចំណោមប្រទេសកំពូលទាំង២៣ ដែលប្រឈមបំផុត ដោយសារកំណើនកម្តៅខ្លាំង។ ឥទ្ធិពលនៃភាពតានតឹងដោយសារកម្តៅនិងកម្តៅតំបន់ទីក្រុង (UHI) បង្កឱ្យមានការព្រួយបារម្ភកាន់តែខ្លាំងឡើងនៅក្នុងវិស័យកសិកម្ម និងការរស់នៅក្នុងទីក្រុង។ ការកើនឡើងនៃសីតុណ្ហភាពជាមធ្យម ធ្វើឱ្យមានការកើនឡើងនៃសត្វល្អិតនិងជំងឺលើដំណាំនិងបសុសត្វ។ ភាពតានតឹងដោយសារកម្តៅបង្កការប៉ះពាល់ដល់សុខភាពនិងសេដ្ឋកិច្ច ដោយសារការថយចុះនៃផលិតភាពនិងការកើនឡើងនៃថ្លៃចំណាយលើការថែទាំសុខភាព ដែលប៉ះពាល់ដល់មុខរបរនៅទីវាល ផលិតកម្មឧស្សាហកម្ម និងជនក្រីក្រ។

[3] World Bank Document

ការប្រែប្រួលលក្ខខណ្ឌជលសាស្ត្រ-ឧតុនិយម បណ្ដាលមកពីការប្រែប្រួលអាកាសធាតុ ធ្វើឱ្យប៉ះពាល់ដល់របបទឹកភ្លៀង និងលំនាំនៃលំហូរទឹកទន្លេ។ ការកើនឡើងនៃនីវ៉ូទឹកសមុទ្រ ការហូរច្រោះកាន់តែខ្លាំងនៅតំបន់ឆ្នេរ ប៉ះពាល់ដល់ការរស់នៅ និងជីវភាពរបស់សហគមន៍នៅតំបន់ឆ្នេរ។ ទន្លេមេគង្គដែលមានតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់ទឹក កសិកម្ម និងជលផលសម្រាប់ប្រទេសកម្ពុជា ក៏រងការប៉ះពាល់ដោយសារការប្រែប្រួលអាកាសធាតុផងដែរ បណ្ដាលពីការប្រែប្រួលនៃរបបទឹកហូរ និងដីល្បាប់នៅក្នុងទន្លេនេះ។

អាងបឹងទន្លេសាបនៅភាគខាងជើងនៃផ្ទៃប្រទេស គឺជាតំបន់កសិកម្មដ៏សំខាន់បំផុតមួយរបស់កម្ពុជា ដែលផ្ដល់ធនធានចាំបាច់សម្រាប់ផ្គត់ផ្គង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាង៣លាននាក់។ តំបន់នេះក៏ស្ថិតក្នុងចំណោមតំបន់ដែលងាយរងគ្រោះបំផុតក្នុងប្រទេសកម្ពុជា ដែលងាយប្រឈមនឹងទឹកជំនន់និងគ្រោះរាំងស្ងួត ដែលត្រូវបានព្យាករថា នឹងកើតមានឡើងកាន់តែញឹកញាប់និងកាន់តែខ្លាំង ដោយសារការប្រែប្រួលអាកាសធាតុ ដែលធ្វើឱ្យភាពងាយរងគ្រោះផ្នែកសង្គមនិងសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរ(GCF, 2023)។

## ១.៣.៤- ការអភិវឌ្ឍសេដ្ឋកិច្ច

ក្នុងរយៈពេលប៉ុន្មានទសវត្សកន្លងមកនេះ សេដ្ឋកិច្ចកម្ពុជាបានរីកចម្រើនយ៉ាងឆាប់រហ័សដោយសារវិស័យសំខាន់ៗ រួមមានកសិកម្ម កាត់ដេរនិងផលិតស្បែកជើង សំណង់ និងទេសចរណ៍។ ប្រទេសកម្ពុជាក៏បានឃើញការកើនឡើងគួរឱ្យកត់សម្គាល់នៃផលិតផលក្នុងស្រុកសរុប ទន្ទឹមនឹងអត្រាកំណើនប្រចាំឆ្នាំជាមធ្យមប្រមាណ៧% ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០២៣ ផងដែរ។ កម្ពុជាមានបំណងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ កម្ពុជាប្រកាន់របបសេដ្ឋកិច្ចបើកចំហ ដែលពឹងផ្អែកលើពាណិជ្ជកម្ម និងការវិនិយោគផ្ទាល់ពីបរទេស។ គោលដៅអភិវឌ្ឍន៍របស់កម្ពុជាបានបង្ហាញយ៉ាងច្បាស់នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

ការប្រែប្រួលអាកាសធាតុបង្កការគំរាមកំហែងយ៉ាងខ្លាំងដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស ដោយធ្វើឱ្យភាពងាយរងគ្រោះដែលមានស្រាប់ នៅក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗដែលបានរៀបរាប់ខាងលើ កាន់តែមានសភាពធ្ងន់ធ្ងរ។ ការពឹងផ្អែកជាខ្លាំងរបស់ប្រទេសលើកសិកម្មដែលពឹងផ្អែកលើទឹកភ្លៀង ធ្វើឱ្យកម្ពុជាងាយប្រឈមនឹងគ្រោះរាំងស្ងួតនិងទឹកជំនន់ ដែលអាចនាំឱ្យខូចខាតផលដំណាំនិងកាត់បន្ថយសន្តិសុខស្បៀង។ លើសពីនេះ កំណើន កម្ពស់ទឹកសមុទ្រនិងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរជាញឹកញាប់ អាចបណ្ដាលឱ្យហេដ្ឋារចនាសម្ព័ន្ធខូចខាត និងបង្កការរំខានដល់ការដឹកជញ្ជូននិងពាណិជ្ជកម្ម។

ដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនេះ កម្ពុជាបានបង្កើនការវិនិយោគនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្របន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដូចជាលើកកម្ពស់ការអនុវត្តកសិកម្មដែលមាននិរន្តរភាព វិនិយោគលើថាមពលកកើតឡើងវិញ និងកែលម្អការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនិងហេដ្ឋារចនាសម្ព័ន្ធដែលធន់។

## ១.៣.៥- បរិបទកូវីដ១៩នៅកម្ពុជា

កម្ពុជារងការប៉ះពាល់ខ្លាំងពីជំងឺកូវីដ១៩។ ជំងឺរាតត្បាតកូវីដ១៩ បាននាំឱ្យសេដ្ឋកិច្ចធ្លាក់ចុះ បាត់បង់ការងារ និងការរំខានដល់ខ្សែចង្វាក់ផ្គត់ផ្គង់ ដែលប៉ះពាល់ដល់វិស័យទេសចរណ៍ កាត់ដេរ និងឧស្សាហកម្ម របស់ប្រទេស។ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តការបិទប្រទេសនិងការរឹតបន្តឹងនានា ដែលធ្វើឱ្យសេដ្ឋកិច្ចកាន់តែតានតឹង។ ផលប៉ះពាល់រួមគ្នានៃជំងឺកូវីដ១៩និងការប្រែប្រួលអាកាសធាតុ បានធ្វើឱ្យភាពងាយរងគ្រោះដែលមានស្រាប់នៅក្នុង

ប្រទេសកម្ពុជាកាន់តែធ្ងន់ធ្ងរ ដោយតម្រូវឱ្យរដ្ឋាភិបាលនិងសហគមន៍អន្តរជាតិ បង្កើតនិងអនុវត្តដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ដើម្បីដោះស្រាយវិបត្តិដែលមានទំនាក់ទំនងគ្នាទៅវិញទៅមកទាំងនេះ។

### ១.៣.៦- យេនឌ័រនិងការប្រែប្រួលអាកាសធាតុ

នៅឆ្នាំ២០១៩ ចំនួនស្ត្រីនៅកម្ពុជាមានអត្រា៥១,១៩%នៃចំនួនប្រជាជនសរុប និងតំណាងឱ្យប្រមាណ ៦៤%នៃកម្លាំងពលកម្មក្នុងវិស័យកសិកម្ម។ តួលេខនេះត្រូវជាប្រមាណ៨០%នៃកម្លាំងពលកម្មក្នុងវិស័យកាត់ដេរ និងស្បែកជើងផងដែរ។ ស្ត្រីរងផលប៉ះពាល់ក្នុងកម្រិតវិសមាមាត្រ ដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ព្រោះថា ពួកគេមានតួនាទីសំខាន់ក្នុងវិស័យកសិកម្ម ផលិតកម្ម និងសេវាកម្ម ព្រមទាំងការទទួលខុសត្រូវលើការងារក្នុងផ្ទះសំបែង ការផ្តល់ចំណីអាហារ និងថែទាំសមាជិកគ្រួសារ។ រាជរដ្ឋាភិបាលបានបង្កើតផែនការយុទ្ធសាស្ត្រយេនឌ័រ និងការប្រែប្រួលអាកាសធាតុ(GCCSP) ឆ្នាំ២០១៣-២០២៣ និងផែនការមេស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៨-២០៣០ ដើម្បីដោះស្រាយទិដ្ឋភាពយេនឌ័រ នៅក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងចីរភាពបរិស្ថាន។ ផែនការមេស្តីពីយេនឌ័រនិងការប្រែប្រួលអាកាសធាតុ ឆ្នាំ២០១៨-២០៣០ ផ្តោតជាសំខាន់ទៅលើភាពងាយរងគ្រោះរបស់ស្ត្រី នៅចំពោះមុខការប្រែប្រួលអាកាសធាតុ។ ផែនការនេះបង្ហាញពីផលប៉ះពាល់អវិជ្ជមានជាច្រើន ដែលរួមទាំងភាពងាយរងគ្រោះកាន់តែខ្លាំងឡើងនៃស្ត្រី ចំពោះបញ្ហាសុខភាព ការកើនឡើងនៃហានិភ័យអំពើហិង្សានៅកន្លែងធ្វើការ ការពឹងផ្អែកកាន់តែខ្លាំងលើធនធានធម្មជាតិសម្រាប់ការចិញ្ចឹមជីវិត និងផលវិបាកនៃកង្វះធនធាន។ ស្ត្រីទទួលព័ត៌មានអំពីការប្រែប្រួលអាកាសធាតុក្នុងកម្រិតតិចតួច ដែលជារឿយៗដោយសារតែការសិក្សាមានកម្រិតទាបធៀបនឹងបុរសនិងតួនាទីបន្ថែម ក្នុងនាមជាអ្នកថែទាំចម្បងក្នុងគ្រួសារ។ ធៀបនឹងបុរស ស្ត្រីមានប្រាក់សន្សំនិងសំណាញ់សុវត្ថិភាពក្នុងកម្រិតកំណត់ ដូច្នេះពួកគាត់ប្រឈមមុខនឹងផលប៉ះពាល់ក្នុងកម្រិតវិសមាមាត្របណ្តាលមកពីគ្រោះមហន្តរាយដែលបង្កឡើងដោយអាកាសធាតុ។ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការដើម្បីបញ្ជ្រាបយេនឌ័រនៅក្នុងឯកសារគោលនយោបាយសំខាន់ៗ ដូចជា NDC, LTS4CN, NSDP, ការពិនិត្យចំណាយសាធារណៈលើការងារអាកាសធាតុកម្ពុជា(CPER) កម្មវិធីវិនិយោគសាធារណៈ(PIP) គោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា(SDGs) និងក្នុងកិច្ចប្រឹងប្រែងកំណែទម្រង់រដ្ឋាភិបាលដែលកំពុងបន្ត។ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលអន្តរស្ថាប័ននៅកម្រិតផ្សេងៗនៃការគ្រប់គ្រងការអនុវត្តគោលនយោបាយសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម(GEDSI) អាចត្រូវពង្រីកជាបន្ថែមផងដែរ។

### ១.៣.៧- សកម្មភាពអាកាសធាតុ

ប្រទេសកម្ពុជាបាននិងកំពុងធ្វើសកម្មភាពយ៉ាងខ្លាំងក្លាក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ តាមរយៈយុទ្ធសាស្ត្រ និងគោលនយោបាយផ្សេងៗ ដូចជាយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន(LTS4CN) ផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ(NDC) គោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជា(CSDGs) ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០១៤-២០២៣ និងយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ឆ្នាំ២០២៣-២០២៨។ សកម្មភាពដោះស្រាយបញ្ហាអាកាសធាតុក៏ត្រូវបានបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDP) និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។ LTS4CN គូសបញ្ជាក់ពីសកម្មភាពកាត់បន្ថយជាអាទិភាព ដើម្បីសម្រេចបានគោលដៅរបស់ប្រទេស

កម្ពុជានូវសេដ្ឋកិច្ចអព្យាក្រឹតកាបូននៅឆ្នាំ២០៥០ ដោយផ្តោតលើការកាត់បន្ថយប្រភពនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដូចជាការដុតឥន្ធនៈផូស៊ីល និងការបង្កើនសមត្ថភាពផ្ទុកកាបូន តាមរយៈការដាំដើមឈើនិងស្តារព្រៃឈើឡើងវិញ ការកាត់បន្ថយការកាប់បំផ្លាញព្រៃឈើជាដើម។

NDC ផ្តោតលើការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ទាំងលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ អភិបាលកិច្ចការប្រែប្រួលអាកាសធាតុ តម្លាភាព និងប្រព័ន្ធតាមដាន។ SDGs ផ្តល់ក្របខ័ណ្ឌមួយសម្រាប់ប្រទេសកម្ពុជា ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ដោយចីរភាពនៅទូទាំងវិស័យផ្សេងៗ រួមទាំងសកម្មភាពអាកាសធាតុ( SDG 13 )។ ម្យ៉ាងវិញទៀត NSDP រួមបញ្ចូល ការពិចារណាអំពីការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការរៀបចំផែនការនិងថវិកាជាតិ។ កម្ពុជាក៏បានចូលរួមក្នុងកិច្ចប្រឹងប្រែងជាសាកលតាមរយៈការសន្យាកម្រិតពិភពលោកលើការរៀបចំប្រព័ន្ធត្រជាក់( សីតកម្ម )នៅCOP28 ក្នុងទីក្រុងឌូបៃ ដែលត្រូវបានលើកឡើងដោយប្រធាន COP28 និងសម្ព័ន្ធប្រព័ន្ធត្រជាក់នៃអង្គការ UNEP ដើម្បីដោះស្រាយការបញ្ចេញឧស្ម័នដែលទាក់ទងនឹងប្រព័ន្ធត្រជាក់។

ការត្រួតពិនិត្យការចំណាយសាធារណៈលើការងារអាកាសធាតុរបស់កម្ពុជាឆ្នាំ២០២២( CPER 2022 )[4] បានគូសបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះសកម្មភាពអាកាសធាតុនិងសុខុមាលភាពសង្គម ទោះបីជាមានផលប៉ះពាល់ពីជំងឺរាតត្បាតកូវីដ១៩ក៏ដោយ។ របាយការណ៍ត្រួតពិនិត្យការចំណាយនេះគូសបញ្ជាក់ពីការផ្លាស់ប្តូរឆ្ពោះទៅរកការវិនិយោគដោយនិរន្តរភាព និងការកសាងភាពធន់ ជាពិសេស សម្រាប់ទឹកជំនន់ គ្រោះរាំងស្ងួត និងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធជនបទ។ ទន្ទឹមនឹងការធ្លាក់ចុះនៃប្រភពមូលនិធិក្នុងស្រុក សម្រាប់ចំណាយលើការប្រែប្រួលអាកាសធាតុនៅក្នុងឆ្នាំ២០២២ ការផ្តល់ប្រាក់កម្ចីពីការប្រែប្រួលអាកាសធាតុបានកើនឡើង១៧%។ នេះបង្ហាញថាការវិនិយោគលើការបន្ស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ នឹងនៅតែមានជាបន្ត ទោះបីធនធានក្នុងស្រុកបានធ្លាក់ចុះក៏ដោយ។ កិច្ចគាំពារសង្គមសម្រាប់ក្រុមងាយរងគ្រោះនៅតែជាអាទិភាពមួយ ជាមួយនឹងការផ្ទេរសាច់ប្រាក់រហូតដល់៣៧៩,៤លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០២២ ដែលជាកំណើនយ៉ាងច្រើនពី២៩៤លានដុល្លារអាម៉េរិកក្នុងឆ្នាំ២០២១។

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ មានសសរស្តម្ភចំនួន៥ : ( ១ )ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ( ២ )ការអភិវឌ្ឍសង្គម ( ៣ )ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ( ៤ )ការអភិវឌ្ឍធនធានមនុស្ស និង( ៥ )អភិបាលកិច្ចល្អ និងការប្រឆាំងអំពើពុករលួយ។ យុទ្ធសាស្ត្រនេះមានគោលបំណងលើកកម្ពស់កំណើនដោយនិរន្តរភាពនិងបរិយាបន្ន ទន្ទឹមនឹងដោះស្រាយបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ។ លើសពីនេះ យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន ឆ្នាំ២០២៣-២០២៨ បានផ្អែកលើសសរស្តម្ភទាំងបី ស្អាត បៃតង និងចីរភាព ហើយយុទ្ធសាស្ត្រនេះផ្តោតលើការលើកកម្ពស់សេដ្ឋកិច្ចចក្រា កាត់បន្ថយសំណល់ និងការលើកកម្ពស់ប្រសិទ្ធភាពធនធាន ដែលរួមចំណែកដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងកិច្ចប្រឹងប្រែងបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ។

កម្ពុជាក៏បានអនុវត្តសកម្មភាពបន្ថែមទៀត ដូចជាយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍បៃតងឆ្នាំ២០១៣-២០៣០ ( NCCG )[5] និងផែនការសកម្មភាពសីតកម្មកម្ពុជា។ គោលការណ៍ NCGG ផ្តោតលើសសរស្តម្ភចំនួនបួន គឺ សេដ្ឋកិច្ច

[4] Cambodia Climate Public Expenditure Review 2022
[5] National Strategic Plan on Green Growth

បរិស្ថាន សង្គម និងវប្បធម៌។ យុទ្ធសាស្ត្រនេះមានបំណងជំរុញសេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅរកសេដ្ឋកិច្ចបៃតង ដោយផ្តោតលើការប្រើប្រាស់ធនធានធម្មជាតិដោយប្រសិទ្ធភាព ចីរភាពបរិស្ថាន ការបង្កើតការងារបៃតង ការលើកកម្ពស់បច្ចេកវិទ្យាបៃតង និងកំណែទម្រង់សេដ្ឋកិច្ច។ ផែនការសកម្មភាពសីតកម្មកម្ពុជា ផ្តល់ក្របខ័ណ្ឌទូលំទូលាយមួយសម្រាប់សកម្មភាពកាត់បន្ថយតម្រូវការថាមពល និងការបញ្ចេញឧស្ម័នដែលទាក់ទងនឹងប្រព័ន្ធត្រជាក់ រួមជាមួយវិធានការបន្សាំ ដើម្បីបង្កើនភាពធន់នឹងការប្រឈមបណ្តាលពីកំណើនសីតុណ្ហភាព។ ប្រទេសកម្ពុជាបានបង្កើនកិច្ចប្រឹងប្រែងដើម្បីពង្រីកការអភិវឌ្ឍដោយមិនទុកអ្នកណាម្នាក់ចោលឡើយ (LNOB) ដោយគាំទ្រដល់ការចូលរួមរបស់«សង្គមទាំងមូល» ក្នុងការអភិវឌ្ឍគោលនយោបាយ ការអនុវត្ត ការត្រួតពិនិត្យ និងរាយការណ៍។

រាជរដ្ឋាភិបាលនឹងបន្សុីការអនុវត្តយុទ្ធសាស្ត្រជាតិដែលពាក់ព័ន្ធ ជាមួយនឹងការវិវឌ្ឍនានាក្នុងពេលបច្ចុប្បន្ននៅក្នុងការប្តេជ្ញាចិត្តគោលនយោបាយសកម្មភាពអាកាសធាតុអន្តរជាតិ ដូចជារបាយការណ៍តម្លាភាពពីរឆ្នាំម្តងការបំពេញតាមលក្ខខណ្ឌតម្រូវនៃយន្តការមូលនិធិការបាត់បង់និងការខូចខាត ដំណើរការផែនការជាតិបន្សាំ និងដំណើរការនៃការវាយតម្លៃរបស់ប្រទេសជាមួយភាគីពាក់ព័ន្ធ។

កិច្ចផ្តួចផ្តើមទាំងនេះគាំទ្រដល់កិច្ចប្រឹងប្រែងរបស់កម្ពុជា ក្នុងការកសាងភាពធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ជាពិសេសក្នុងវិស័យដែលងាយរងគ្រោះ : កសិកម្ម ធនធានទឹក ព្រៃឈើ សុខភាព បរិស្ថានសិប្បនិម្មិតនៅទីក្រុងនិងតំបន់ឆ្នេរ។ ដោយមើលឃើញពីភូមិសាស្ត្រ ការអភិវឌ្ឍសេដ្ឋកិច្ច និងភាពងាយរងគ្រោះនៃអាកាសធាតុដូចដែលបានរាយការណ៍នៅក្នុង NDC និងរបាយការណ៍ជាតិ (NC) ដែលបានធ្វើបច្ចុប្បន្នភាពរបស់ខ្លួន និងទោះបីមានផែនការនិងសកម្មភាពប្រកបដោយមហិច្ឆតារបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការបន្សាំនឹងអាកាសធាតុក៏ដោយផលប៉ះពាល់មួយចំនួននៃការប្រែប្រួលអាកាសធាតុនឹងកើតឡើងដោយជៀសមិនរួច ដូចជាព្រឹត្តិការណ៍ធ្ងន់ធ្ងរ និងកំណើននីវ៉ូទឹកសមុទ្រ។ ក្នុងកម្រិតសកល កម្ពុជាអាចទទួលបានមូលនិធិការបាត់បង់និងការខូចខាត ដើម្បីជួយដោះស្រាយការខាតបង់សេដ្ឋកិច្ច (ដូចជាការខូចខាតហេដ្ឋារចនាសម្ព័ន្ធ) និងការខាតបង់មិនមែនសេដ្ឋកិច្ច (ដូចជាការខូចខាតនិងការបាត់បង់បេតិកភណ្ឌវប្បធម៌) បណ្តាលពីព្រឹត្តិការណ៍ធ្ងន់ធ្ងរ។ ប្រទេសកម្ពុជាដែលជាភាគីនៃ UNFCCC ត្រូវពង្រឹងសមត្ថភាពដើម្បីអនុវត្តតាមវិធីសាស្ត្រថ្មី សម្រាប់ការត្រួតពិនិត្យនិងរាយការណ៍ទៅ UNFCCC។ រាជរដ្ឋាភិបាលកម្ពុជានិងដៃគូរបស់ខ្លួន បានអនុវត្តកិច្ចប្រឹងប្រែង ដូចជាការកសាងសមត្ថភាពបច្ចេកទេស ដើម្បីអនុលោមតាមយន្តការផ្តល់មូលនិធិការបាត់បង់និងការខូចខាត និងលក្ខខណ្ឌរាយការណ៍ថ្មីៗរបស់ UNFCCC។

## ១.៤- ទស្សនវិស័យអភិវឌ្ឍន៍កម្ពុជា

### ១.៤.១- ការព្យាករអំពីការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា

ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាដែលបានព្យាករសម្រាប់ចន្លោះឆ្នាំ២០២៤ និងឆ្នាំ២០៣៣ បង្ហាញទស្សនវិស័យវិជ្ជមាន ជាមួយកំណើនជាបន្តបន្ទាប់។ យើងរំពឹងថា កម្ពុជានឹងរក្សាបានអត្រាកំណើនជាមធ្យមប្រចាំឆ្នាំយ៉ាងរឹងមាំប្រមាណ៧% ដែលជំរុញដោយកត្តានានា ដូចជាកំណើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ កំណើនឧស្សាហកម្មកាត់ដេរ និងវាយនភណ្ឌ ការរីកចម្រើននៃវិស័យទេសចរណ៍ជាដើម។ ការយកចិត្តទុកដាក់របស់រដ្ឋាភិបាលលើការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងការពង្រឹងបរិយាកាសអំណោយផលសម្រាប់អាជីវកម្ម នឹងរួមចំណែកដល់កំណើននេះ។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាប្រឈម ដូចជាវិសមភាពប្រាក់ចំណូល ការកែលម្អការអភិវឌ្ឍមូលធនមនុស្ស

និងការធានានូវវឌ្ឍនភាពសេដ្ឋកិច្ចដោយចីរភាព នៅតែមានសារៈសំខាន់សម្រាប់កម្ពុជា ក្នុងការសម្រេចបានគោលដៅសេដ្ឋកិច្ចរយៈពេលវែងរបស់ខ្លួនក្នុងកំឡុងពេលនេះ។

### ១.៤.២- របៀបវារៈនៃការស្តារសេដ្ឋកិច្ចកម្ពុជា

របៀបវារៈនៃការស្តារសេដ្ឋកិច្ចរបស់កម្ពុជាក្រោយជំងឺកូវីដ១៩ ផ្តោតលើវិធីសាស្ត្រពហុភាគីក្នុងការស្តារនិងពង្រឹងសេដ្ឋកិច្ចរបស់ប្រទេសជាតិ ដល់ឆ្នាំ២០៣៣។ យុទ្ធសាស្ត្រនេះចែងពីអាទិភាពសំខាន់ៗចំនួនប្រាំ៖

១- ការបង្កើនភាពប្រកួតប្រជែងនិងផលិតភាព។

២- ការលើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ច។

៣- ការជំរុញការអភិវឌ្ឍធនធានមនុស្ស។

៤- ការពង្រឹងកិច្ចគាំពារសង្គមនិងភាពធន់ និង

៥- ការអនុវត្តគោលនយោបាយកំណើនដែលមានចីរភាពនិងបៃតង។

ដើម្បីសម្រេចគោលដៅទាំងនេះ រដ្ឋាភិបាលបានគូសបញ្ជាក់ពីកិច្ចផ្តួចផ្តើមមួយចំនួន។ ទីមួយ កិច្ចផ្តួចផ្តើមកែលម្អហេដ្ឋារចនាសម្ព័ន្ធ ការតភ្ជាប់ឌីជីថលនិងភស្តុភារ ដើម្បីទាក់ទាញការវិនិយោគពីបរទេស និងគាំទ្រដល់អាជីវកម្មក្នុងស្រុក។ ទីពីរ ការធ្វើពិពិធកម្មសេដ្ឋកិច្ចនឹងត្រូវជំរុញដោយការពង្រឹងកំណើនក្នុងវិស័យនានា ដូចជាកសិកម្ម ទេសចរណ៍ ផលិតកម្ម និងសេវាកម្ម។ ទី៣ រដ្ឋាភិបាលគ្រោងវិនិយោគលើវិស័យអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីបំពាក់កម្លាំងពលករនូវជំនាញចាំបាច់សម្រាប់ទីផ្សារការងារដែលកំពុងវិវត្ត។ ទី៤ វិធានការគាំពារសង្គមនឹងត្រូវបានពង្រឹង ដើម្បីធានាឱ្យពលរដ្ឋដែលងាយរងគ្រោះ មានលទ្ធភាពទទួលបានសេវាសំខាន់ៗ និងការគាំទ្រក្នុងកំឡុងពេលនៃសេដ្ឋកិច្ចអន្តរកាល។ ទី៥ រដ្ឋាភិបាលប្តេជ្ញាទទួលយកការអនុវត្តដែលធានាចីរភាពបរិស្ថាននិងបច្ចេកវិទ្យាបៃតង ដើម្បីកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងជំរុញកំណើនសេដ្ឋកិច្ចរយៈពេលវែង។

តាមរយៈការអនុវត្តយុទ្ធសាស្ត្រទាំងនេះ រហូតដល់ឆ្នាំ២០៣៣ កម្ពុជាមានបំណងសម្រេចបានសេដ្ឋកិច្ចដែលធន់និងបរិយាបន្ន មានសមត្ថភាពទប់ទល់នឹងការប៉ះទង្គិចនាពេលអនាគត និងផ្តល់ឱកាសដល់ប្រជាពលរដ្ឋរបស់ខ្លួន។

## ២- ចក្ខុវិស័យ

ប្រទេសកម្ពុជាឈានឆ្ពោះទៅអព្យាក្រឹតភាពកាបូននិងភាពធន់នឹងអាកាសធាតុ ចូលរួមចំណែកអភិវឌ្ឍជាតិប្រកបដោយចីរភាព។ ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០២៤-២០៣៣ ជាផែនទីបង្ហាញផ្លូវ ដើម្បីកៀរគរការចូលរួមពីក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងវិស័យឯកជននានា ក្នុងការសម្រេចមហិច្ឆតាអព្យាក្រឹត្យកាបូន និងភាពធន់នឹងអាកាសធាតុ។

## ៣- បេសកកម្ម

បេសកកម្មនៃ CCCSP ឆ្នាំ២០២៤-២០៣៣ គឺការផ្តល់ក្របខ័ណ្ឌជាតិ តាមរយៈដំណើរការបរិយាបន្ន ដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័ន ពង្រឹងភាពធន់ និងកែលម្អយន្តការអភិបាលកិច្ច ដើម្បីសុខុមាលភាពសង្គម បរិស្ថាន និងសេដ្ឋកិច្ច។ ផែនការទូលំទូលាយនេះពាក់ព័ន្ធនឹងការផ្តួចផ្តើមជាច្រើន ដែលរួមទាំងការលើកកម្ពស់ថាមពល

កកើតឡើងវិញ ការកែលម្អប្រសិទ្ធភាពថាមពល ការគ្រប់គ្រងការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព សំណង់អគារមេត្រីភាពបរិស្ថានបៃតង ការដាំដើមឈើឡើងវិញនិងការដាំព្រៃឈើ និងការទទួលយកនូវការអនុវត្តឆ្លាតវៃនិងធន់ទៅនឹងអាកាសធាតុនៅទូទាំងវិស័យសេដ្ឋកិច្ច។ លើសពីនេះ កម្ពុជាសង្កត់ធ្ងន់លើសារៈសំខាន់នៃការចូលរួមរបស់សហគមន៍ ការកសាងសមត្ថភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីធានាឱ្យមានការកែប្រែប្រកបដោយជោគជ័យ ឆ្ពោះទៅអនាគតដែលបញ្ចេញកាបូនតិច។ តាមរយៈការអនុវត្តចក្ខុវិស័យនេះ កម្ពុជាប្រាថ្នាមិនត្រឹមតែការពារបរិស្ថានរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋទាំងមូល ដោយមិនទុកអ្នកណាម្នាក់ចោលឡើយ នៅក្នុងដំណើរឆ្ពោះទៅស្ថានភាពជាប្រទេសរីកចម្រើន ប្រកបដោយភាពធន់។

## ៤- គោលបំណងនិងគោលដៅ

លើកស្ទួយការអភិវឌ្ឍប្រកបដោយចីរភាព តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាបញ្ចេញកាបូនតិច និងពង្រឹងសមត្ថភាពភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

ដើម្បីសម្រេចនូវគោលបំណងនេះ ត្រូវមានគោលដៅយុទ្ធសាស្ត្រ ចំនួន៣ : (១)ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ស្របនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូនរហូតដល់ឆ្នាំ២០៥០ (២)ពង្រឹងសមត្ថភាពបន្សុាំនឹងការប្រែប្រួលអាកាសធាតុ និង(៣)លើកស្ទួយអភិបាលកិច្ចល្អនិងបរិវត្តកម្មឌីជីថល។

## ៥- ក្របខ័ណ្ឌយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា(CCCSP) គឺជាក្របខ័ណ្ឌថ្នាក់ជាតិ ដែលត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុនិងលើកកម្ពស់ការអភិវឌ្ឍដោយចីរភាពនៅក្នុងប្រទេស។ CCCSP ឆ្នាំ២០២៤-២០៣៣ គូសបញ្ជាក់ពីអាទិភាព សកម្មភាព និងគោលដៅដែលត្រូវសម្រេចឱ្យបាននៅឆ្នាំ២០៣៣។ ផែនការនេះមានផ្នែកយុទ្ធសាស្ត្រចំនួន៣ គឺការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ច និងលទ្ធផលយុទ្ធសាស្ត្រចំនួន២០។

| គោលដៅយុទ្ធសាស្ត្រ | ១- ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ | ២- ពង្រឹងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ | ៣- លើកស្ទួយអភិបាលកិច្ចល្អនិងបរិវត្តកម្មឌីជីថល |
|---|---|---|---|
| លទ្ធផលរំពឹងទុក | ១.១- បង្កើនការរួមចំណែកនៃថាមពលកកើតឡើងវិញ(RE) នៅក្នុងល្បាយថាមពលជាតិ និងការប្រើប្រាស់ RE នៅក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ(ដឹកជញ្ជូន កសិកម្ម ទេសចរណ៍ ផលិតកម្ម។ល។) ទន្ទឹមនឹងកាត់បន្ថយការពឹងផ្អែកលើឥន្ធនៈផូស៊ីល។ | ២.១- ពង្រឹងវិធានការបង្កើនភាពធន់នៅគ្រប់វិស័យសេដ្ឋកិច្ច និងសេវាសង្គមសំខាន់ៗ (សេវាកម្មទឹកស្អាត អគ្គិសនី អនាម័យ ការថែទាំសុខភាព អាហារូបត្ថម្ភ ការអប់រំ សង្គម និងកិច្ចគាំពារកុមារ ទេសចរណ៍ ប្រព័ន្ធស្បៀងអាហារដែលមាននិរន្តរភាព និងហេដ្ឋារចនា សម្ព័ន្ធសំខាន់ៗ ដូចជា WASH ថាមពល ផ្លូវថ្នល់ជាដើម។) ដោយផ្តោតជាពិសេស លើតម្រូវការរបស់កុមារ និងសហគមន៍ដែលងាយរងគ្រោះបំផុត។ | ៣.១- ពង្រឹងយន្តការហិរញ្ញវត្ថុអាកាសធាតុ |
| | ១.២- បង្កើនប្រសិទ្ធភាពថាមពល(EE) និងថាមពលកកើតឡើងវិញ(RE) នៅក្នុងការដំឡើង អគារ លំនៅឋាន និងការដឹកជញ្ជូន (ការដឹកជញ្ជូនសាធារណៈ រថយន្តអគ្គិសនី)។ | ២.២- បង្កើនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការត្រៀមបង្ការ និងការស្តារឡើងវិញនៅទូទាំងសហគមន៍(តំបន់ឆ្នេរ បឹងទន្លេសាប និងសហគមន៍តាមដងទន្លេមេគង្គ)។ | ៣.២- បង្កើនលទ្ធភាពប្រើប្រាស់និងការអប់រំព័ត៌មានដែលផ្តោតចំគោលដៅ ការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាលអំពីការប្រែប្រួលអាកាសធាតុ។ |
| | ១.៣- ពង្រឹងការអនុវត្តសេដ្ឋកិច្ចចក្រា(CE) និងទប់ស្កាត់ការបំពុល ក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ (ទេសចរណ៍ កសិកម្ម សំណង់ ការផលិត ការដឹកជញ្ជូន។ល។)។ | ២.៣- ពង្រឹងការអភិរក្សប្រព័ន្ធអេកូឡូស៊ីនិងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព (រួមទាំងទន្លេមេគង្គ បឹងទន្លេសាប ព្រៃឈើ ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ីទីក្រុង និងបញ្ជ្រាបដំណោះស្រាយ និងការបន្សាំដោយផ្អែកតាមធម្មជាតិ)។ | ៣.៣- ពង្រឹងកម្លាំងពលកម្មបច្ចុប្បន្ន និងអនាគត ដើម្បីឈានឆ្ពោះទៅអន្តរកាលកាបូនទាប និងដែលធន់។ |

| | | | |
|---|---|---|---|
| | ១.៤- ពង្រឹងធនធានទឹកនិងការផ្គត់ផ្គង់ដែលធន់និងមាននិរន្តរភាព ប្រព័ន្ធនិងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងសំណល់រឹងនិងសំណល់រាវ (ឈានទៅស្ថានភាពគ្មានសំណល់ បញ្ឈប់ការប្រើប្រាស់ប្លាស្ទិកតែមួយលើកហើយបោះចោល(SUP)) បង្កើនជម្រើសជំនួស SUP ប្រែក្លាយសំណល់ទៅជាថាមពល(WTE) សំណល់ក្នុងវិស័យកាត់ដេរ ទឹកក្រោមដី និងធនធានទឹកលើដី ។ល។)។ | ២.៤- ពង្រឹងភាពធន់នៃក្រុមជនដែលងាយរងគ្រោះ(ដូចជាកុមារនិងសហគមន៍មូលដ្ឋាន) និងបញ្ជ្រាប GEDSI ទៅក្នុងសកម្មភាពដោះស្រាយបញ្ហាអាកាសធាតុនិងភាពធន់។ | ៣.៤- ពង្រឹងការចូលរួមពីភាគីពាក់ព័ន្ធនានានិងការចូលរួមក្នុងការអនុវត្តយុទ្ធសាស្ត្រ។ |
| | ១.៥- បង្កើនទំហំនៃលំហបៃតងក្នុងទីក្រុង និងទីក្រុងបៃតង ដោយលើកកម្ពស់ការប្រើប្រាស់ដំណោះស្រាយផ្អែកតាមធម្មជាតិ។ | ២.៥- ពង្រឹងវិធានការនិរន្តរភាពនិងភាពធន់ (រួមទាំងបច្ចេកវិទ្យាឆ្លាតវៃចំពោះអាកាសធាតុ កសិកម្មដែលស្តារគុណភាពដីឡើងវិញ។ | ៣.៥- ពង្រឹងលទ្ធភាពទទួលបានជំនួយបច្ចេកទេសសម្រាប់ការកសាងសមត្ថភាពពហុភាគី។ |
| | ១.៦- បង្កើនគម្របព្រៃឈើនិងបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ (រួមទាំងបង្កើនការវិនិយោគនៃវិស័យឯកជន និងការចូលរួមក្នុង FOLU ការបង្កើតស្តង់ដាពាក់ព័ន្ធ និងគោលការណ៍ណែនាំ។ល។)។ | ២.៦- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធនិងការកសាងភាពធន់ និងចីរភាពបរិស្ថាន(រួមទាំងពង្រីកការអនុវត្តស្តង់ដាអគារបៃតង ការរចនាអគារដែលរក្សាភាពត្រជាក់ លេខកូដអគារ និងហេដ្ឋារចនាសម្ព័ន្ធបៃតងនិងប្រផេះ។)។ | ៣.៦- ដោះស្រាយគម្លាតទិន្នន័យនិងព័ត៌មានសម្រាប់ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃប្រកបដោយប្រសិទ្ធភាព។<br><br>៣.៧- ពង្រឹងកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូក្នុងតំបន់និងអន្តរជាតិ(រួមទាំង អាស៊ាន គណៈកម្មការទន្លេមេគង្គ កិច្ចផ្តួចផ្តើមសហប្រតិបត្តិការមេគង្គ ទីភ្នាក់ងារនៃអង្គការសហប្រជាជាតិ មូលនិធិហិរញ្ញវត្ថុអាកាសធាតុ ធនាគារអភិវឌ្ឍន៍ និងទីភ្នាក់ងារអភិវឌ្ឍន៍)។<br><br>៣.៨- រៀបចំផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តបរិវត្តកម្មឌីជីថលក្នុងការងារប្រែប្រួលអាកាសធាតុនិងបរិស្ថាន។ |

*រូបទី៣ : CCCSP ឆ្នាំ២០២៤-២០៣៣ : វិស័យនិងលទ្ធផលជាយុទ្ធសាស្ត្រ*

## ៥.១- គោលដៅយុទ្ធសាស្ត្រ១ : ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ដែលបានអនុវត្តក្នុងវិស័យសំខាន់ៗនៃសេដ្ឋកិច្ច (កសិកម្ម ព្រៃឈើនិងការប្រើប្រាស់ដី(FOLU) ការដឹកជញ្ជូន ការគ្រប់គ្រងសំណល់ សកម្មភាពឧស្សាហកម្ម និងថាមពល)

ដូចបានកំណត់ក្នុង NDC LTS4CN គោលការណ៍ការប្រើប្រាស់និងផលិតកម្មដែលមាននិរន្តរភាព(SCP) ផែនទីបង្ហាញផ្លូវយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន គោលនយោបាយប្រសិទ្ធភាពថាមពល(EE) និងផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍបណ្តាញស្ថានីយបញ្ចូលថាមពលយានយន្តអគ្គិសនី(EV)នៅកម្ពុជា។ល។ ស្របតាមយុទ្ធសាស្ត្ររយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន(LTS4CN)

## ៥.១.១- លទ្ធផលយុទ្ធសាស្ត្រ

១- បង្កើនសមាមាត្រនៃថាមពលកកើតឡើងវិញ(RE)នៅក្នុងល្បាយថាមពលជាតិ និងការប្រើប្រាស់នៅក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ(ដឹកជញ្ជូន កសិកម្ម ទេសចរណ៍ ផលិតកម្ម។ល។) ទន្ទឹមនឹងកាត់បន្ថយការពឹងផ្អែកលើឥន្ធនៈផូស៊ីល។

២- បង្កើនប្រសិទ្ធភាពថាមពល(EE) និងថាមពលកកើតឡើងវិញ(RE) នៅក្នុងឧស្សាហកម្មធំឡើង អគារលំនៅឋាន និងការដឹកជញ្ជូន(ការដឹកជញ្ជូនសាធារណៈ រថយន្តអគ្គិសនី)។

៣- ពង្រឹងការអនុវត្តសេដ្ឋកិច្ចចក្រា(CE) និងការទប់ស្កាត់ការបំពុលក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ (ទេសចរណ៍ កសិកម្ម សំណង់ ការផលិត ការដឹកជញ្ជូន។ល។)។

៤- ពង្រឹងធនធានទឹកនិងការផ្គត់ផ្គង់ដែលមាននិរន្តរភាពនិងរឹងមាំ ប្រព័ន្ធគ្រប់គ្រងសំណល់រឹង និងសំណល់រាវ និងហេដ្ឋារចនាសម្ព័ន្ធ(កំណត់គោលដៅគ្មានសំណល់ បញ្ឈប់ការប្រើប្រាស់ប្លាស្ទិកតែម្តងបោះចោល (SUP)) បង្កើនជម្រើសជំនួសSUP ការប្រែក្លាយសំណល់ទៅជាថាមពល(WTE) សំណល់ក្នុងវិស័យកាត់ដេរ ទឹកក្រោមដី និងធនធានទឹកលើដី។ល។)។

៥- បង្កើនលំហបៃតងក្នុងទីក្រុងនិងទីក្រុងបៃតង លើកកម្ពស់ការប្រើប្រាស់ដំណោះស្រាយផ្អែកលើធម្មជាតិ។

៦- បង្កើនគម្របព្រៃឈើនិងបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ(រួមទាំងបង្កើនការវិនិយោគនៃវិស័យឯកជន និងការចូលរួមក្នុង FOLU ការបង្កើតស្តង់ដាពាក់ព័ន្ធ និងគោលការណ៍ណែនាំ។ល។)។

## ៥.២- គោលដៅវិស័យយុទ្ធសាស្ត្រ២ : ពង្រឹងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ

ពង្រឹងការបន្សាំនិងភាពធន់នឹងការប្រែប្រួលអាកាសធាតុ តាមរយៈការបញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម(GEDSI) ទៅក្នុងគោលនយោបាយពាក់ព័ន្ធនិងយុទ្ធសាស្ត្រតាមវិស័យ ពង្រឹងដំណោះស្រាយផ្អែកលើធម្មជាតិ ពង្រីកហិរញ្ញប្បទានឆ្លើយតបនឹងអាកាសធាតុ ការប្រាស្រ័យទាក់ទងកាន់តែទូលំទូលាយ ការបណ្តុះបណ្តាលនិងការយល់ដឹង និងពង្រឹងប្រព័ន្ធប្រកាសអាសន្ន និងភាពធន់នឹងហានិភ័យគ្រោះមហន្តរាយ។

## ៥.២.១- លទ្ធផលយុទ្ធសាស្ត្រ

១- ពង្រឹងវិធានការធន់ នៅគ្រប់វិស័យសេដ្ឋកិច្ចនិងសេវាសង្គមសំខាន់ៗ (ឧបករណ៍ប្រើប្រាស់ អនាម័យ ការថែទាំសុខភាព អាហារូបត្ថម្ភ ការអប់រំ សង្គម និងកិច្ចគាំពារកុមារ ទេសចរណ៍ ប្រព័ន្ធស្បៀងអាហារដែលមាននិរន្តរភាព និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជាWASH ថាមពល ផ្លូវថ្នល់ជាដើម) និងផ្តោតជាពិសេសលើតម្រូវការរបស់កុមារនិងសហគមន៍ដែលងាយរងគ្រោះបំផុត។

២- ពង្រឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការរៀបចំ និងការស្តារឡើងវិញនៅទូទាំងសហគមន៍ (សហគមន៍តំបន់ឆ្នេរ បឹងទន្លេសាប និងសហគមន៍ទន្លេមេគង្គ)។

៣- ពង្រឹងការអភិរក្សប្រព័ន្ធអេកូឡូស៊ីនិងការគ្រប់គ្រងធនធានធម្មជាតិឱ្យមាននិរន្តរភាព(រួមទាំង ទន្លេមេគង្គ បឹងទន្លេសាប ព្រៃឈើ ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ីទីក្រុង និងការបញ្ជ្រាបដំណោះស្រាយ និងការបន្សាំតាមធម្មជាតិ)។

៤- ពង្រឹងភាពធន់នៃក្រុមដែលងាយរងគ្រោះ(ដូចជាកុមារ សហគមន៍មូលដ្ឋានជាដើម) និងបញ្ជ្រាប GEDSI ទៅក្នុងសកម្មភាពដោះស្រាយបញ្ហាអាកាសធាតុនិងភាពធន់។

៥- ពង្រឹងវិធានការនិរន្តរភាពនិងភាពធន់(រួមទាំងបច្ចេកវិទ្យាឆ្លាតវៃចំពោះអាកាសធាតុ កសិកម្មដែលស្តារគុណភាពដី)។

៦- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ ការកសាងភាពធន់ និងនិរន្តរភាពបរិស្ថាន(រួមទាំងការពង្រីកការអនុវត្តស្តង់ដាអគារបៃតង ការរចនាប្រព័ន្ធត្រជាក់ កូដអគារ ហេដ្ឋារចនាសម្ព័ន្ធបៃតងនិងប្រផេះ។ល។)

### ៥.៣- គោលដៅយុទ្ធសាស្ត្រ៣ : លើកស្ទួយអភិបាលកិច្ចល្អនិងបរិវត្តកម្មឌីជីថល (កត្តាជំរុញ)

ការពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្ស ការសម្របសម្រួលរវាងអង្គភាពស្នូល ក្រសួង ស្ថាប័ន នាយកដ្ឋាន និងផ្នែកនានាក្នុងកម្រិតជាតិ និងថ្នាក់ក្រោមជាតិ ការអភិវឌ្ឍនិងការអនុវត្តគោលនយោបាយរួម និងផ្នែកលើកស្ទុយតាងនិងយន្តការហិរញ្ញវត្ថុ។

### ៥.៣.១- លទ្ធផលយុទ្ធសាស្ត្រ

១- ពង្រឹងយន្តការហិរញ្ញវត្ថុអាកាសធាតុ។

២- បង្កើនលទ្ធភាពប្រើប្រាស់និងការអប់រំព័ត៌មានដែលផ្តោតឱ្យចំគោលដៅ ការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាលអំពីការប្រែប្រួលអាកាសធាតុ។

៣- ពង្រឹងកម្លាំងពលករបច្ចុប្បន្ននិងអនាគត ដើម្បីឈានឆ្ពោះទៅអនាគតមួយដែលបញ្ចេញកាបូនតិចនិងធន់។

៤- ពង្រឹងការចូលរួមនៃភាគីពាក់ព័ន្ធជាច្រើននិងការចូលរួមក្នុងការអនុវត្តយុទ្ធសាស្ត្រ។

៥- ពង្រឹងលទ្ធភាពទទួលបានជំនួយបច្ចេកទេសសម្រាប់ការកសាងសមត្ថភាពពហុភាគី។

៦- ដោះស្រាយគម្លាតទិន្នន័យនិងព័ត៌មានសម្រាប់ការត្រួតពិនិត្យ និងការវាយតម្លៃប្រកបដោយប្រសិទ្ធភាព។

៧- ពង្រឹងកិច្ចសហប្រតិបត្តិការនិងភាពជាដៃគូក្នុងតំបន់និងអន្តរជាតិ(រួមទាំងអាស៊ាន គណៈកម្មការទន្លេមេគង្គ (MRC) កិច្ចផ្តួចផ្តើមកិច្ចសហប្រតិបត្តិការទន្លេមេគង្គ ទីភ្នាក់ងារអង្គការសហប្រជាជាតិ មូលនិធិហិរញ្ញវត្ថុអាកាសធាតុ ធនាគារអភិវឌ្ឍន៍ និងទីភ្នាក់ងារអភិវឌ្ឍន៍)។

៨- រៀបចំផែនទីបង្ហាញផ្លូវសម្រាប់បញ្ជ្រាបបរិវត្តកម្មឌីជីថលក្នុងការងារបរិស្ថាននិងការប្រែប្រួលអាកាសធាតុ។

## ៦- សកម្មភាពការងារ

### ៦.១- គោលដៅ សកម្មភាព និងធនធានសំខាន់ៗ

ផ្អែកលើវឌ្ឍនភាពដែលប្រទេសកម្ពុជាសម្រេចបានរួចមកហើយ ក្នុងសកម្មភាពអាកាសធាតុ ផែនការយុទ្ធសាស្ត្រ CCCSP ឆ្នាំ២០២៤-២០៣៣ ផ្តោតលើការបង្កើនសកម្មភាព ដើម្បីដោះស្រាយបញ្ហាកំណើនការបញ្ចេញឧស្ម័ន និងភាពងាយរងគ្រោះចំពោះអាកាសធាតុ។ ផែនការយុទ្ធសាស្ត្រ CCCSP ឆ្នាំ២០២៤-២០៣៣ មានគោលដៅកាត់បន្ថយបរិមាណលើសពីតម្រូវការ ពង្រឹងភាពច្បាស់លាស់នៃតួនាទីអន្តរស្ថាប័ន និងបង្កើនប្រសិទ្ធភាព

និងបរិយាបន្ន នៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំ និងអភិបាលកិច្ច។ ផែនការយុទ្ធសាស្ត្រនេះក៏អំពាវនាវឱ្យមានការចូលរួមកាន់តែច្រើនពីវិស័យឯកជន សហជីព និងសហគមន៍មូលដ្ឋានផងដែរ។

តារាងខាងក្រោមនេះ បង្ហាញលទ្ធផលយុទ្ធសាស្ត្រ គោលដៅសកម្មភាពសំខាន់ៗស្ថាប័នអនុវត្ត និងតម្រូវការធនធានមនុស្សនិងបច្ចេកវិទ្យាសម្រាប់ការអនុវត្ត CCCSP ឆ្នាំ២០២៤-២០៣៣។ ការប៉ាន់ប្រមាណថវិកាបានផ្អែកលើការអនុវត្តយុទ្ធសាស្ត្រផ្សេងៗ ដូចជាLTS4CN យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ NDCជាដើម។

## ៦.២- សកម្មភាព

ផែនការយុទ្ធសាស្ត្រ CCCSP ឆ្នាំ២០២៤-២០៣៣ ចែងអំពីសកម្មភាពនានា ដែលផ្តោតលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំ អភិបាលកិច្ច និងលើកកម្ពស់ការយល់ដឹង។ សកម្មភាពកាត់បន្ថយនានាមានគោលដៅកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ តាមរយៈថាមពលកកើតឡើងវិញ ការកែលម្អប្រសិទ្ធភាពថាមពល ការស្តារនិងដាំដើមឈើឡើងវិញ លើកកម្ពស់ការដឹកជញ្ជូនដែលជានានិរន្តរភាព និងការគ្រប់គ្រងសំណល់។ សកម្មភាពបន្សាំមានគោលដៅពង្រឹងសមត្ថភាពបន្សាំរបស់អ្នកពាក់ព័ន្ធនានា វិស័យសេដ្ឋកិច្ចនិងធនធានធម្មជាតិ។ វិធានការអភិបាលកិច្ចមានបំណងផ្តល់លក្ខណៈងាយស្រួល ដើម្បីឱ្យការអនុវត្តយុទ្ធសាស្ត្រនេះប្រព្រឹត្តទៅដោយរលូន។ វិធានការទាំងនេះ រួមមានការដោះស្រាយភាពខ្វះចន្លោះខាងទិន្នន័យនិងបច្ចេកវិទ្យា ហិរញ្ញប្បទាន ការអភិវឌ្ឍធនធានមនុស្ស គោលនយោបាយ និងបទប្បញ្ញត្តិ និងការសម្របសម្រួលអន្តរស្ថាប័ន។ លើសពីនេះ ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំ ការផ្សព្វផ្សាយសហគមន៍ និងការតស៊ូមតិខាងគោលនយោបាយ នឹងលើកទឹកចិត្តឱ្យមានការចូលរួមកាន់តែទូលំទូលាយ និងភាពម្ចាស់ការលើសកម្មភាពអាកាសធាតុ។

## ៦.៣- ការកំណត់ពេលវេលានិងគោលដៅ

វិធីសាស្ត្រអនុវត្តចែកចេញជាពីរដំណាក់កាល ដើម្បីដោះស្រាយផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព។ ដំណាក់កាលទី១(ឆ្នាំ២០២៤-២០២៨) នឹងផ្តោតលើការពង្រឹងគោលនយោបាយនិងដោះស្រាយគម្លាតទិន្នន័យ សម្រាប់ជួយដល់ការត្រួតពិនិត្យ លើកកម្ពស់ការសម្របសម្រួលអន្តរស្ថាប័ន រាយការណ៍ និងផ្ទៀងផ្ទាត់(MRV) និងពង្រឹងក្របខ័ណ្ឌពង្រឹងតម្លាភាព(ETF)។ ដំណាក់កាលនេះមានបំណងបង្កើនល្បឿននៃសកម្មភាពដែលទាក់ទងនឹងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការកៀរគរហិរញ្ញប្បទានអាកាសធាតុ ការបន្សុីគោលនយោបាយ និងបទប្បញ្ញត្តិតាមវិស័យ ការកសាងសមត្ថភាពនិងលទ្ធភាពទទួលបានបច្ចេកវិទ្យា ដើម្បីពង្រឹងភាពធន់នៅទូទាំងវិស័យសំខាន់ៗនៃសេដ្ឋកិច្ច និងតំបន់ និងសហគមន៍ងាយរងគ្រោះ។

ដំណាក់កាលទីពីរ(ឆ្នាំ២០២៩-២០៣៣) នឹងផ្តោតលើការពង្រីកការអនុវត្តយុទ្ធសាស្ត្រ តាមដានវឌ្ឍនភាព និងកែសម្រួលផែនការទៅតាមការចាំបាច់ ដើម្បីសម្រេចឱ្យបាននូវឥទ្ធិពលដែលចង់បានក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សុាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលគាំទ្រដោយយន្តការអភិបាលកិច្ចដ៏រឹងមាំ។

## ៦.៤- ផែនការអនុវត្ត CCCSP ឆ្នាំ២០២៤-២០៣៣

ក្រុមការងារបច្ចេកទេសបរិស្ថាននិងការប្រែប្រួលអាកាសធាតុ(ECCTWG) មាននាទីជាលេខាធិការដ្ឋានដើម្បីសម្របសម្រួលការបង្កើតនិងការអនុវត្តក្របខ័ណ្ឌនេះ។ លេខាធិការដ្ឋាននេះមានភារៈទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍វឌ្ឍនភាពនៃ CCCSP និងM&Eផងដែរ។ សូចនាករ នីតិវិធី និងការទទួលខុសត្រូវក្នុងការប្រមូល

ទិន្នន័យ គឺជាកម្មវត្ថុនៃការឯកភាពគ្នាជាមួយក្រសួងពាក់ព័ន្ធ មូលនិធិហិរញ្ញប្បទានអាកាសធាតុ វិទ្យាស្ថានជាតិស្ថិតិ និងភាគីផ្សេងទៀត ដែលចាប់អារម្មណ៍ក្នុងការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនេះ។ ក្រុមអ្នកវិភាគ ស្ថាប័នស្រាវជ្រាវ និងវិទ្យាស្ថានឧត្តមសិក្សា( IHL ) អាចនឹងត្រូវអញ្ជើញឱ្យចូលរួម ដើម្បីផ្តល់ការគាំទ្រក្នុងការជំរុញសកម្មភាពផ្សេងៗ និងM&Eសម្រាប់ CCCSP ឆ្នាំ២០២៤-២០៣៣។ ស្របតាមគោលបំណងរបស់ CCCSP ក្នុងការធ្វើឱ្យមានបរិយាបន្ន ស្ថាប័នអនុវត្តនឹងប្រឹងប្រែងដើម្បីបង្កើនការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន ដែលរួមទាំងក្រុមស្ត្រីនិងយុវជនដែលជាតំណាងសហជីព និងសមាគមកម្មករក្រៅប្រព័ន្ធ ដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន។

## តារាងទី១- គោលដៅយុទ្ធសាស្ត្រ១ : ចំណុចដៅ សកម្មភាព និងធនធានសំខាន់ៗ សម្រាប់ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់

**គោលដៅយុទ្ធសាស្ត្រ១ :** ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ : អនុវត្តក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗដែលណែនាំដោយ LTS4CN រួមមាន ថាមពល ឧស្សាហកម្ម កសិកម្ម ព្រៃឈើ និងសំណល់ និង ផែនទីបង្ហាញផ្លូវ SCP NDCs គោលនយោបាយជាតិ EE យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន គោលនយោបាយជាតិប្រសិទ្ធភាពថាមពល ផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍបណ្តាញស្ថានីយ៍សាកថ្មថយន្តអគ្គិសនីនៅកម្ពុជា

| លទ្ធផលយុទ្ធសាស្ត្រ | គោលដៅ | ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI | ថវិកាប៉ាន់ស្មាន[6] | សកម្មភាព | ស្ថាប័នសំខាន់ៗដែលជាអ្នកអនុវត្ត |
|---|---|---|---|---|---|
| ១.១- បង្កើនសមាមាត្រថាមពលកកើតឡើងវិញ (RE) នៅក្នុងល្បាយថាមពលជាតិ និងការប្រើប្រាស់ក្នុងវិស័យសំខាន់ៗនៃសេដ្ឋកិច្ច (ដឹកជញ្ជូន កសិកម្ម ទេសចរណ៍ ផលិតកម្ម ។ល។) ទន្ទឹមនឹងកាត់បន្ថយការពឹងផ្អែកលើឥន្ទនៈផូស៊ីល | • អភិវឌ្ឍថាមពលកកើតឡើងវិញដូចជាវារីអគ្គិសនី ព្រះអាទិត្យ និងខ្យល់<br>• កាត់បន្ថយការប្រើប្រាស់ថាមពល<br>• កាត់បន្ថយការពឹងផ្អែកលើប្រភពថាមពលពីឥន្ទនៈផូស៊ីល<br>• កាត់បន្ថយការបញ្ចេញឧស្ម័នពីឥន្ទនៈផូស៊ីល | • វត្តមាននិងលទ្ធភាពជាវថាមពលសម្រាប់ក្រុម/សហគមន៍ដែលងាយរងគ្រោះ ដែលរួមទាំងកិច្ចផ្តួចផ្តើមថាមពលកកើតឡើងវិញ ដែលគ្រប់គ្រងដោយសហគមន៍<br>• លទ្ធភាពទទួលបានលំនៅឋានដែលមានតម្លៃសមរម្យ និងនិរន្តរភាព ការដឹកជញ្ជូនដែលផ្តល់ផាសុកភាព និងភាព | ផែនទីបង្ហាញផ្លូវNCAP[7] ៥០លានដុល្លារអាមេរិក (i)<br>ក្នុងអគារនិងការអនុវត្ត ២៥លានដុល្លារអាមេរិក (ii)<br>បង្កើនការថែទាំយានយន្តការបំភាយ ៦០០០០០ ដុល្លារអាមេរិក (ii)<br>ការបញ្ចូលភ្លើង/ថែទាំ EV ៣លានដុល្លារអាមេរិក | i- ពង្រីកការអនុវត្ត/ត្រួតពិនិត្យ និងកែលម្អកូដអគារបៃតង រួមបញ្ចូល គោលការណ៍ណែនាំអំពី EE ប្រសិទ្ធភាពទឹក និងការដំឡើងRE នៅក្នុងអគារដែលមានស្រាប់និងថ្មីៗ បញ្ចូលទៅក្នុងផែនការអភិវឌ្ឍលំនៅឋានដែលមាននិរន្តរភាពនិងតម្លៃសមរម្យ ដំណោះស្រាយផ្អែកលើធម្មជាតិ អគារសាធារណៈថ្មីៗ និងដែលមានស្រាប់ដូចជា មណ្ឌលថែទាំសុខភាព សាលារៀន និងអគាររដ្ឋបាល (ឧទាហរណ៍ តាមរយៈផែនការវិនិយោគឃុំ ការចូលរួមពីក្រុមនានាក្នុងប្រទេស និងដោយបង្កើតបរិយាកាស និងគោលនយោបាយអំណោយផល)។<br>ii- អនុវត្ត និងពង្រឹងការអនុវត្តបទប្បញ្ញត្តិស្របតាម EE ប្រសិទ្ធភាពទឹក និងគោលនយោបាយRE។<br>iii- ជំរុញការអនុវត្តផែនការសកម្មភាពប្រព័ន្ធសីតកម្មជាតិ (NCAP) និងគោលនយោបាយប្រសិទ្ធភាពថាមពល។<br>iv- បង្កើតនិងអនុវត្តស្តង់ដានៃការសាកអាគុយ និងការថែទាំ និងបទប្បញ្ញត្តិសុវត្ថិភាព។<br>v- បង្កើតនិងអនុវត្តផែនការសកម្មភាពនិងចំណុចដៅ ដែលផ្តោតលើការដំឡើង RE ដែលសមស្រប ជាក់ស្តែង និងមានតម្លៃសមរម្យ ក្នុងវិស័យសំខាន់ៗនៃសេដ្ឋកិច្ច (កសិកម្ម ទេសចរណ៍ ផលិតកម្ម អគារនិងសំណង់)។<br>vi- កាត់បន្ថយថ្លៃចំណាយលើការស្វែងរក ការផលិត ការថែទាំ និងសេវាកម្មសម្រាប់ការដំឡើង និងបរិក្ខារដែលមានប្រសិទ្ធភាពថាមពល និងទឹក (ឧ. ការលើកទឹកចិត្តខាងផ្នែកពន្ធ)។ | • MME<br>• MoE<br>• MAFF<br>• MISTI<br>• MoH<br>• MLMUPC<br>• MRD<br>• MoWA<br>• MAFF<br>• MPWT<br>• MLVT<br>• NIS |

[6] ក្នុងករណីគ្មានសន្ទស្សន៍ថវិកា គួរធ្វើការសិក្សាលទ្ធភាព ឬ ការវិភាគអត្ថប្រយោជន៍ធៀបនឹងថ្លៃចំណាយ។

[7] NCAP – ផែនការសកម្មភាពសីតកម្មជាតិ ឆ្នាំ២០២៣។

| | | | | | |
|---|---|---|---|---|---|
| | • បង្កើនទីលានចាក់សំរាមដែលគោរពគោលការណ៍វិស្វកម្ម/អនាម័យ(កាត់បន្ថយការបញ្ចេញឧស្ម័ន និងការបំពុលពីការគ្រប់គ្រងសំណល់)<br>• កំណើនជីវម៉ាសនៅក្នុងល្បាយថាមពល (ពីសំណល់កសិកម្ម)។ | ងាយស្រួលដល់ក្រុមដែលមានចំណូលទាប<br>• លទ្ធភាពចូលប្រើប្រាស់ និង/ឬការលើកទឹកចិត្តឱ្យស្ត្រីចុះឈ្មោះចូលរៀនបន្ថែមទៀតនៅក្នុងការសិក្សាទាក់ទងនឹងថាមពល(វិស្វកម្ម ហិរញ្ញវត្ថុ និងសេវាកម្ម) នៅ IHL | (ផ្លូវល្បឿនលឿន ៤) (iii) [8]<br>ការសិក្សាអំពីការបញ្ចូលប្រភពថាមពលកកើតឡើងវិញ<br>៣00000ដុល្លារអាម៉េរិក<br>(iv)<br>ការសាងសង់និងស្តង់ដានៃការថែទាំ<br>៦00000ដុល្លារអាម៉េរិក<br>(vi)<br>៥00 – ១៣ន់លានដុល្លារអាម៉េរិក (មិនគិតបញ្ចូលការវិនិយោគលើប្រព័ន្ធដឹកជញ្ជូនខ្នាតធំ)។ | vii- រួមបញ្ចូលEE និងRE ទៅក្នុងលក្ខខណ្ឌតម្រូវ សម្រាប់ការដឹកជញ្ជូនខ្នាតធំ នៅក្នុងការអនុវត្ត"ផែនទីបង្ហាញផ្លូវសម្រាប់ផែនការមេទូលំទូលាយ ស្តីពីប្រព័ន្ធដឹកជញ្ជូន និងដឹកជញ្ជូនកម្ពុជា ឆ្នាំ២០២៣-៣៣"<br>vii- បង្កើនការប្រើប្រាស់សារធាតុត្រជាក់ដែលមានGWPទាប ដើម្បីបង្កើនល្បឿននៃការឈប់ប្រើប្រាស់ HFCs។ | • MoINFO |
| ១.២- បង្កើនប្រសិទ្ធភាពថាមពល (EE) និងថាមពលកកើតឡើងវិញ (RE) នៅក្នុងការដំឡើងអគារ លំនៅឋាន និងការដឹកជញ្ជូន (ការដឹកជញ្ជូនសាធារណៈ រថយន្តអគ្គិសនី)។ | | | | **តម្រូវការបច្ចេកវិទ្យានិងសមត្ថភាពមនុស្ស[9]**<br>• រចនាការដំឡើងRE និង EEការសាងសង់ ការថែទាំ និងការអនុវត្តNCAP<br>• ស្ថាបត្យកម្ម ការធ្វើផែនការទីក្រុង និងវិស្វកម្មសម្រាប់ការរចនា និងការបង្កើតលំហបៃតង(តំបន់ទីក្រុង) និងអគារ (រួមទាំង ផ្ទះដែលមានតម្លៃសមរម្យ និងការរចនាអគារដែលរក្សាភាពត្រជាក់បានយូរ)<br>• មធ្យោបាយដើម្បីលើកទឹកចិត្តដល់វិស័យឯកជន(អ្នកអភិវឌ្ឍ ក្រុមហ៊ុនសំណង់ ស្ថាបត្យករ។ល។)ឱ្យវិនិយោគលើគម្រោងសកម្មភាពអាកាសធាតុ<br>• ការចល័តអគ្គិសនី (ការដឹកជញ្ជូនតាមមធ្យោបាយឯកជននិងតាមមធ្យោបាយខ្នាតធំ) ប្រភពថាមពល (សូឡា អ៊ីដ្រូសែន។ល។) រួមទាំងការថែទាំ សេវាកម្ម ហិរញ្ញប្បទាន និងហេដ្ឋារចនាសម្ព័ន្ធ ការកែច្នៃអាគុយឡើងវិញ<br>• សារពើភណ្ឌនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ថ្នាក់ជាតិ សម្រាប់វិធានការកាត់បន្ថយទាំងអស់ ដែលស្របតាមក្របខ័ណ្ឌតម្លាភាពដែលបានពង្រឹង(ETF)<br>• វាយតម្លៃជម្រើសនៃការទិញថាមពលពន្លឺព្រះអាទិត្យមកពីគ្រួសារឯកជនដែលផលិតលើសពីតម្រូវការ។ | |

[8] World Bank (2024) អនុសាសន៍របស់កម្ពុជាចំពោះផែនទីបង្ហាញផ្លូវរបស់ជាតិសម្រាប់អន្តរកាលអគ្គិសនីក្នុងការដឹកជញ្ជូន https://documents1.worldbank.org/curated/en/099031924073537111/pdf/P17690614457da0e71a4501e8dcdea2d59d.pdf

[9] *ការទទួលបានបច្ចេកវិទ្យា កម្មវិធីសិក្សា IHL និងការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈជាបន្តបន្ទាប់។*

| គោលដៅយុទ្ធសាស្ត្រ១ : ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ : អនុវត្តក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗដែលណែនាំដោយ LTS4CN រួមមាន ថាមពល ឧស្សាហកម្ម កសិកម្ម ព្រៃឈើ និងសំណល់ និង ផែនទីបង្ហាញផ្លូវ SCP NDCs គោលនយោបាយជាតិ EE យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន គោលនយោបាយជាតិប្រសិទ្ធភាពថាមពល ផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍបណ្តាញស្ថានីយ៍សាកថ្មយានយន្តអគ្គិសនីនៅកម្ពុជា | | | | | |
|---|---|---|---|---|---|
| **លទ្ធផលយុទ្ធសាស្ត្រ** | **គោលដៅ** | **ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI** | **ថវិកាប៉ាន់ស្មាន** | **សកម្មភាព** | **ស្ថាប័នសំខាន់ៗដែលជាអ្នកអនុវត្ត** |
| ១.៣- ពង្រឹងការអនុវត្តសេដ្ឋកិច្ចចក្រា CE និងទប់ស្កាត់ការបំពុល ក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ (ទេសចរណ៍ កសិកម្ម សំណង់ ការផលិត ការដឹកជញ្ជូន។ល។)។ | • កាត់បន្ថយការប្រើប្រាស់ប្លាស្ទិកតែម្តងចោល(SUP)<br>• បង្កើនការប្រើប្រាស់ជម្រើសដែលមាននិរន្តរភាពជំនួសឱ្យការប្រើប្លាស្ទិកតែម្តងចោល/ការប្រើច្រើនដង។<br>• ការយល់ដឹងជាសាធារណៈ: កាន់តែទូលំទូលាយតាមរយៈការអប់រំអំពីរបៀបរស់នៅដោយនិរន្តរភាពនិងព័ត៌មានសម្រាប់អ្នកប្រើប្រាស់<br>• កាត់បន្ថយការបាត់បង់ក្រោយការប្រមូលផល និង | •បញ្ចូល GEDSI ទៅក្នុងការយល់ដឹងអំពីការអប់រំអំពីរបៀបរស់នៅដោយនិរន្តរភាព និងព័ត៌មានសម្រាប់អ្នកប្រើប្រាស់ ការកាត់បន្ថយការបាត់បង់ក្រោយប្រមូលផល និងការអនុវត្តផែនទីបង្ហាញផ្លូវ SCP។ | ១៣៤លានដុល្លារអាមេរិក[10] គម្រោងគ្រប់គ្រងប្លាស្ទិក(i)<br>ការវាយតម្លៃផ្នែកបដិសណ្ឋារកិច្ច –២,៥លានដុល្លារអាមេរិក (ii)<br>ពង្រីកផលិតកម្មកសិកម្មដែលធន់នឹងអាកាសធាតុ តាមរយៈការបង្កើនលទ្ធភាពទទួលបានប្រព័ន្ធស្រោចស្រពដើរដោយថាមពលព្រះអាទិត្យ និងការអនុវត្តផ្សេងទៀតដែលធន់នឹងអាកាសធាតុ-ការវិនិយោគលើខ្សែចង្វាក់ត្រជាក់ ១០លានដុល្លារអាមេរិក (iii)[11] | i- បង្កើតនិងអនុវត្តផែនទីបង្ហាញផ្លូវកាត់បន្ថយប្លាស្ទិក(ឬផែនការមេ)<br>ii- បង្កើនល្បឿននៃការអនុវត្តបដិសណ្ឋារកិច្ច(សណ្ឋាគារ/កន្លែងស្នាក់នៅ) ការវាយតម្លៃនិរន្តរភាព វិញ្ញាបនបត្រស្លាកសញ្ញាបៃតងឬតំបន់និរន្តរភាពទេសចរណ៍។<br>iii- បង្កើតនិងអនុវត្តកម្មវិធីកាត់បន្ថយការខាតបង់ក្រោយប្រមូលផល និងសំណល់អាហារក្នុងខ្សែចង្វាក់តម្លៃកសិកម្ម។<br>iv- បង្កើនល្បឿននៃការអនុវត្តស្តង់ដាស្លាកសញ្ញាបៃតង/និរន្តរភាពសម្រាប់សម្ភារៈវេចខ្ចប់ សម្ភារៈសំណង់ ប្រសិទ្ធភាពថាមពល ប្រសិទ្ធភាពទឹក ជាដើម។<br>v- បង្កើតនិងអនុវត្តកម្មវិធីកាត់បន្ថយការបាត់បង់ក្រោយការប្រមូលផល និងសំណល់អាហារនៅក្នុងខ្សែចង្វាក់តម្លៃកសិកម្ម រួមទាំង ផលិតផលដែលងាយរលួយបាន ផលិតផលទឹកដោះ និងសាច់។<br>**តម្រូវការបច្ចេកវិទ្យានិងសមត្ថភាពមនុស្ស**<br>• ការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងការផលិតក្នុងស្រុកនូវវត្ថុធាតុដើមផ្សេង/ដែលមាននិរន្តរភាព សម្រាប់សម្ភារៈវេចខ្ចប់ (វត្ថុជំនួសប្លាស្ទិកប្រើម្តងចោល/ប្លាស្ទិកដែលប្រើច្រើនដង | • MoE<br>• MAFF<br>• MoH<br>• MLMUPC<br>• MRD<br>• MoWA<br>• MAFF<br>• MPWT<br>• MLVT<br>• NIS.<br>• MoINFO |

[10] កម្ពុជា : គម្រោងកែលម្អការគ្រប់គ្រងសំណល់រឹងនិងប្លាស្ទិក(គម្រោង៥ឆ្នាំ ២០២៤-២០២៩; ៦៧លានដុល្លារអាមេរិក = ប្រមាណ១៣៤លានដុល្លារអាមេរិក សម្រាប់១០ឆ្នាំ) https://projects.worldbank.org/en/projects-operations/project-detail/P170976

[11] NDC លេខ១៦ ស្តីពីការអនុវត្តកាពធន់នឹងអាកាសធាតុ រួមទាំងខ្សែចង្វាក់ប្រព័ន្ធត្រជាក់និងការស្តុកទុកអាហារ ដើម្បីបង្កើនសន្តិសុខស្បៀងនិងកាត់បន្ថយការបាត់បង់ក្រោយប្រមូលផល។

| | | | | | |
|---|---|---|---|---|---|
| | សំណល់អាហារនៅក្នុងខ្សែចង្វាក់តម្លៃអាហារ<br>• ជំរុញសកម្មភាពអាទិភាពក្រោមផែនទីបង្ហាញផ្លូវ SCP ឆ្នាំ២០២២-២០៣៥។ | | កូដអគារជាមួយការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរចនាអគារ និងជំរុញការប្រើសម្ភារៈថ្លៃទាបសម្រាប់លំនៅឋាន- ៦,៦ លានដុល្លារអាមេរិក (iv)។ | • ស្រាវជ្រាវនិងអភិវឌ្ឍន៍លើបច្ចេកវិទ្យា ឧបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធកាត់បន្ថយការបាត់បង់ក្រោយប្រមូលផល<br>• ហេដ្ឋារចនាសម្ព័ន្ធនិងបច្ចេកវិទ្យាប្រព័ន្ធត្រជាក់ដែលមាននិរន្តរភាព សម្រាប់វិស័យកសិកម្មនិងអាហារ<br>• ការស្រាវជ្រាវនិងការអភិវឌ្ឍក្នុងការវិភាគវដ្តជីវិត<br>• បង្កើតនិងចែកចាយកម្មវិធីសិក្សាលើអគារបៃតងនៅក្នុងសាកលវិទ្យាល័យស្ថាបត្យកម្ម និងវិស្វកម្ម<br>• គម្រោងសាកល្បង/អនុវត្តបង្ហាញ (រួមទាំងនៅថ្នាក់ខេត្ត/ស្រុក) អំពីអត្ថប្រយោជន៍សរុបដែលបានពីដំណោះស្រាយផ្អែកតាមធម្មជាតិ NbS ក្នុងទីក្រុង។ | |

| **គោលដៅយុទ្ធសាស្ត្រ១** - ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ : អនុវត្តក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗដែលណែនាំដោយ LTS4CN រួមមាន ថាមពល ឧស្សាហកម្ម កសិកម្ម ព្រៃឈើ និងសំណល់ និង ផែនទីបង្ហាញផ្លូវ SCP NDCs គោលនយោបាយជាតិ EE យុទ្ធសាស្ត្រចក្រវិស័យបរិស្ថាន គោលនយោបាយជាតិប្រសិទ្ធភាពថាមពល ផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍបណ្ដាញស្ថានីយ៍សាកថ្មរថយន្តអគ្គិសនីនៅកម្ពុជា | | | | | |
|---|---|---|---|---|---|
| **លទ្ធផលយុទ្ធសាស្ត្រ** | **គោលដៅ** | **ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI** | **ថវិកាប៉ាន់ស្មាន** | **សកម្មភាព** | **ស្ថាប័នសំខាន់ៗដែលជាអ្នកអនុវត្ត** |
| ១.៤- ពង្រឹងធនធានទឹកនិងការផ្គត់ផ្គង់ដែលធន់និងមាននិរន្តរភាព ប្រព័ន្ធនិងហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រង | • អនុវត្តកាន់តែទូលំទូលាយនូវការញែកសំណល់ និងការញែកពីគ្នានៅតាមប្រភព | • GEDSI និងការពិចារណាលើវិស័យក្រៅប្រព័ន្ធក្នុងសកម្មភាពគ្រប់គ្រងសំណល់ដោយនិរន្តរភាព រួមទាំងការអប់រំនិងអនុវត្ត | ការអនុវត្តយុទ្ធសាស្ត្រជាតិ3R។ ថ្លៃកែច្នៃប្លាស្ទិក ៤000ដុល្លារអាមេរិក/តោន (i, ii) | i- ជំរុញយុទ្ធនាការ "ថ្ងៃនេះខ្ញុំមិនប្រើថង់ប្លាស្ទិក" និង "កម្ពុជាស្អាត! ខ្មែរអាចធ្វើបាន!"។<br>ii- អនុវត្តវិធីញែកសំណល់នៅតាមប្រភព។<br>iii- បង្កើតនិងអនុវត្តយុទ្ធសាស្ត្រ/ផែនការមេសំណល់រឹងថ្នាក់ជាតិ (រួមទាំងកន្លែងកែច្នៃឡើងវិញប្លាស្ទិក អាលុយមីញ៉ូម កញ្ចក់ ក្រដាសជាដើម និងការបញ្ចូលភ្នាក់ងារក្នុងវិស័យ[illegible]ក្រៅប្រព័ន្ធទៅជារចនាសម្ព័ន្ធផ្លូវការ)។ | • MoE<br>• MoH<br>• MAFF<br>• MLMUPC<br>• MRD |

| | | | | | |
|---|---|---|---|---|---|
| សំណល់រឹង និងរាវ (ឈានទៅស្ថានភាពគ្មានសំណល់ បញ្ឈប់ការប្រើប្រាស់ប្លាស្ទិកតែម្តងហើយចោល (SUP) )បង្កើនជម្រើសជំនួស SUP ប្រែក្លាយសំណល់ទៅជាថាមពល (WTE) សំណល់ក្នុងវិស័យកាត់ដេរ ទឹកក្រោមដី និងធនធានទឹកលើដី ។ល។) | • រៀបចំកម្មវិធីកែច្នៃកាន់តែទូលំទូលាយ និងការអនុវត្តអនុក្រឹត្យស្តីពីសំណល់និងកែច្នៃឡើងវិញ<br>• អនុលោមភាពកាន់តែច្រើនតាមលក្ខខណ្ឌតម្រូវ និងបទប្បញ្ញត្តិអំពីប្រព្រឹត្តកម្មសំណល់<br>• បង្កើតកម្មវិធីសំណល់សូន្យ<br>• ឈប់ប្រើប្លាស្ទិកតែម្តងចោល<br>• បង្កើនជម្រើសជំនួសការប្រើប្លាស្ទិកតែម្តងចោល | • ការពិចារណានិងការបញ្ជ្រាប GEDSI ទៅក្នុងការស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D) និងការអនុវត្តការងារគ្រប់គ្រងនិងប្រព្រឹត្តកម្មសំណល់រឹង និងរាវ<br>• បង្កើនការចុះឈ្មោះស្ត្រីក្នុងការងារគ្រប់គ្រងសំណល់រឹង/រាវ និងការសិក្សាវិស្វកម្ម និងបច្ចេកវិទ្យា | ទីលានចាក់សំរាមអនាម័យថ្មីៗ ៧៨៨លានដុល្លារអាម៉េរិក និងRDF ១៦,៩ លានដុល្លារអាម៉េរិក (iv)<br>ប្រព្រឹត្តកម្មសំណល់រាវ – ៣-៥លានដុល្លារអាម៉េរិក *(សហហិរញ្ញប្បទាន និងការអនុវត្តស្តង់ដាប្រព្រឹត្តកម្មចាំបាច់)*[12] (v និង vi)។ | iv- ពង្រឹងការគ្រប់គ្រងគ្រប់ជ្រុងជ្រោយដែលមាននិរន្តរភាពសម្រាប់សំណល់វាយនភណ្ឌ ដោយអនុវត្តគោលការណ៍សេដ្ឋកិច្ចចក្រា។<br>v- សាងសង់ទីលានចាក់សំរាមអនាម័យនិងបរិក្ខារRDF/WTE។<br>vi- អនុវត្តឱ្យបានទូលំទូលាយនូវស្តង់ដាសំណល់រាវសម្រាប់វិស័យសេដ្ឋកិច្ចសំខាន់ៗ (កាត់ដេរ និងស្បែកជើង កែច្នៃម្ហូបអាហារ កសិកម្ម-បសុសត្វ។ល។)។<br>vii- អនុវត្តស្តង់ដាសំណល់រាវជាកាតព្វកិច្ចសម្រាប់វិស័យកាត់ដេរ កន្លែងប្រព្រឹត្តកម្មសំណល់ (និងសំណល់រាវ) រួមទាំងកន្លែងប្រព្រឹត្តកម្មសំណល់រាវតូចៗសម្រាប់ទីក្រុងតូចៗ។<br>**តម្រូវការបច្ចេកវិទ្យានិងសមត្ថភាពមនុស្ស**<br>• បច្ចេកវិទ្យានិងការបណ្តុះបណ្តាលអំពី WTE/RDF<br>• គំរូអាជីវកម្មដែលមាននិរន្តរភាពសម្រាប់ប្រព័ន្ធគ្រប់គ្រងសំណល់<br>• វិស្វកម្មនិងបច្ចេកវិជ្ជាកែច្នៃសំណល់រាវ<br>• កម្មវិធីអភិវឌ្ឍន៍សមត្ថភាពលើការរចនានិងប្រាស្រ័យទាក់ទងដើម្បីកែប្រែឥរិយាបថសង្គម (SBCC)បង្កើនការយល់ដឹងនិងលើកកម្ពស់ឥរិយាបថគ្រប់គ្រងសំណល់ដោយនិរន្តរភាព។<br>• ការត្រួតពិនិត្យការបំពុលទឹក ការត្រួតពិនិត្យ ការឃ្លាំមើល និងពង្រឹងការអនុវត្ត។ | • MISTI<br>• MoWRAM<br>• MoWA<br>• MPWT<br>• MLVT<br>• MoINFO |

[12] កំណត់សម្គាល់៖ ការគ្រប់គ្រងសំណល់រាវពីឧស្សាហកម្ម ដើម្បីផលប្រយោជន៍សង្គមនិងបរិស្ថាន តម្រូវឱ្យមានការអនុលោមតាមស្តង់ដាប្រព្រឹត្តកម្មនិងការបញ្ចេញចោល។

**គោលដៅយុទ្ធសាស្ត្រ១ : ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ : អនុវត្តក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗដែលណែនាំដោយ LTS4CN រួមមាន ថាមពល ឧស្សាហកម្ម កសិកម្ម ព្រៃឈើ និងសំណល់ និង ផែនទីបង្ហាញផ្លូវ SCP NDCs គោលនយោបាយជាតិ EE យុទ្ធសាស្ត្រក្របខ័ណ្ឌវិស័យបរិស្ថាន គោលនយោបាយជាតិប្រសិទ្ធភាពថាមពល ផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍបណ្ដាញស្ថានីយ៍សាកថ្មរថយន្តអគ្គិសនីនៅកម្ពុជា**

| លទ្ធផលយុទ្ធសាស្ត្រ | គោលដៅ | ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI | ថវិកាប៉ាន់ស្មាន | សកម្មភាព | ស្ថាប័នសំខាន់ៗជាអ្នកអនុវត្ត |
|---|---|---|---|---|---|
| ១.៥- បង្កើនទំហំលំហបៃតងក្នុងទីក្រុង និងទីក្រុងបៃតង ដោយលើកកម្ពស់ការប្រើប្រាស់ដំណោះស្រាយផ្អែកលើធម្មជាតិ | • បញ្ចូលដំណោះស្រាយផ្អែកលើធម្មជាតិ ទៅក្នុងវិធីសាស្ត្ររៀបចំផែនការយុទ្ធសាស្ត្រទីក្រុងបៃតងនិងផែនការយុទ្ធសាស្ត្រនិរន្តរភាពទីក្រុងរណបសម្រាប់ការធ្វើផែនការនិងការអភិវឌ្ឍទីក្រុង<br>• បង្កើនអត្រាលំហបៃតងក្នុងមនុស្សម្នាក់ៗ<br>• បង្កើនការប្រើប្រាស់រចនាបថប្រព័ន្ធត្រជាក់នៅក្នុងអគារ និងសំណង់ ។ | • ពិចារណាពីផលប៉ះពាល់នៃភាពតានតឹងបណ្ដាលពីកម្ដៅមកលើការងារដែលមានប្រាក់ចំណូលទាប និងខាងក្រៅផ្ទះ។ រួមបញ្ចូល លំហបៃតងក្នុងទីក្រុងនៅក្នុងសង្កាត់/ក្រៅសង្កាត់ និងទៅក្នុងគម្រោងលំនៅឋានសម្រាប់អ្នកដែលមានចំណូលទាប/ថ្លៃសមរម្យ។ | ៥០០លានដុល្លារអាម៉េរិក (សម្រាប់ តែក្រុងភ្នំពេញ រយៈពេល១០ឆ្នាំ)[13] រួមទាំង ការដាំដើមឈើ បង្កើនលំហបៃតង ការអនុវត្តហេដ្ឋារចនាសម្ព័ន្ធដំណោះស្រាយផ្អែកលើធម្មជាតិ-បៃតង។ (i-ii)<br><br>ពង្រីកកម្មវិធីភ្ញៀវទេសចរម្នាក់ ឈើមួយដើម (២ លានដុល្លារអាម៉េរិក) និងការចែកកូនឈើ (១ដុល្លារអាម៉េរិក/ដើម) (iv) | i- អនុវត្តគោលដៅអត្រាលំហបៃតងក្នុងទីក្រុង សម្រាប់មនុស្សម្នាក់ៗ។<br>ii- បញ្ជ្រាបនិងបញ្ចូលដំណោះស្រាយផ្អែកលើធម្មជាតិក្នុងការរៀបចំផែនការទីក្រុង បទប្បញ្ញត្តិ និងកូដអគារ រួមទាំង នៅថ្នាក់ក្រោមជាតិ។<br>iii- អនុវត្តគំរូហិរញ្ញប្បទានអាកាសជាតុសម្រាប់ភាពជាដៃគូសាធារណៈ ឯកជនលើការរចនាអគារបៃតង/ដោយនិរន្តរភាព និងធន់ សម្រាប់សំណង់ និងអចលនទ្រព្យ រួមទាំងលំនៅឋានដែលមានតម្លៃសមរម្យ និងធន់។<br>iv- បង្កើនល្បឿននិងពង្រីកយុទ្ធនាការដាំដើមឈើ។<br>v- ពង្រឹងការអនុវត្តឱ្យបានពេញលេញនូវបទបញ្ញត្តិកូដអគារ ការរចនាប្រព័ន្ធត្រជាក់ ការអនុញ្ញាតសាងសង់ បទបញ្ញត្តិរៀបចំផែនការទីក្រុង និងលក្ខខណ្ឌតម្រូវសម្រាប់លំហបៃតង<br>vi- បង្កើតនិងអនុវត្តការណែនាំទីក្រុងបៃតងនៅក្នុងផែនការមេស្តីពីការអភិវឌ្ឍទីក្រុង ដោយបញ្ចូលដំណោះស្រាយផ្អែកលើធម្មជាតិ។<br>vii- លើកកម្ពស់និងអនុវត្តការរចនាអគារឱ្យកាន់តែប្រសើរឡើង ផាសុកភាពខាងផ្នែកកម្ដៅ ពង្រីកយុទ្ធសាស្ត្រប្រព័ន្ធត្រជាក់នៅក្នុងការសាងសង់ថ្មី និងដំណោះស្រាយនៃការជួសជុលអគារចាស់ៗឡើងវិញ។ | • MoE<br>• MoH<br>• MAFF<br>• MLMUPC<br>• MRD<br>• MISTI<br>• MoWRAM<br>• MoWA<br>• MPWT<br>• MLVT<br>• MoINFO |

[13] ការសិក្សាវិភាគសេដ្ឋកិច្ចនិងគោលនយោបាយហេដ្ឋារចនាសម្ព័ន្ធបៃតងដែលធន់នៅតាមទីក្រុងក្នុងប្រទេសកម្ពុជា https://ncsd.moe.gov.kh/sites/default/files/2022-09/SV_Cambodia%20GI%20Report%20Final.pdf។

| | | | | | |
|---|---|---|---|---|---|
| | | | ពង្រឹងការអនុវត្តកូដអគារ (v) (*សូមអានកូដចរិកា អគារបៃតង ១.១ខាងលើ*)។ | **តម្រូវការបច្ចេកវិទ្យានិងសមត្ថភាពមនុស្ស**<br>• កម្មវិធីសិក្សានិងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាបន្តបន្ទាប់ ស្តីពីដំណោះស្រាយផ្អែកលើធម្មជាតិ វិស្វកម្ម និងការរចនា ការរចនាទីក្រុង ហេដ្ឋារចនាសម្ព័ន្ធបៃតងនិងប្រផេះ<br>• កម្មវិធីការសិក្សា/គ្រោងការណ៍សម្រាប់វិញ្ញាបនបត្របញ្ជាក់និងសវនកម្មអគារបៃតង<br>• បង្កើតវេទិកាសហគមន៍អ្នករចនាទីក្រុងនិងដំណោះស្រាយផ្អែកលើធម្មជាតិ។ | |

**គោលដៅយុទ្ធសាស្ត្រ១ :** ជំរុញការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ : អនុវត្តក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗដែលណែនាំដោយ LTS4CN រួមមាន ថាមពល ឧស្សាហកម្ម កសិកម្ម ព្រៃឈើ និងសំណល់ និង ផែនទីបង្ហាញផ្លូវ SCP NDCs គោលនយោបាយជាតិ EE យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន គោលនយោបាយជាតិប្រសិទ្ធភាពថាមពល ផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍបណ្តាញស្ថានីយ៍សាកថ្មយានយន្តអគ្គិសនីនៅកម្ពុជា

| លទ្ធផលយុទ្ធសាស្ត្រ | គោលដៅ | ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI | ថវិកាប៉ាន់ស្មាន | សកម្មភាព | ស្ថាប័នសំខាន់ៗជាអ្នកអនុវត្ត |
|---|---|---|---|---|---|
| ១.៦- បង្កើនគម្របព្រៃឈើ និងបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ (រួមទាំងបង្កើនការវិនិយោគនៃវិស័យឯកជន និងការចូលរួមក្នុង FOLU ការបង្កើតស្តង់ដាពាក់ព័ន្ធ និងគោលការណ៍ណែនាំ។ល។)។ | • អនុវត្ត និងតាមដានរាល់វិធានការដើម្បីកាត់បន្ថយអត្រាបាត់បង់ព្រៃឈើ បញ្ឈប់ការកាប់បំផ្លាញព្រៃឈើ(ត្រឹមឆ្នាំ២០៤៥) ការដាំព្រៃឈើ កសិរុក្ខកម្ម និងការអនុវត្តផែនការវិនិយោគ REDD+<br>• បង្កើនការវិនិយោគនិងការចូលរួមនៃវិស័យឯកជនក្នុងការដាំដើមឈើឡើងវិញ និងបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ | • វាយតម្លៃនិងកាត់បន្ថយផលប៉ះពាល់មកលើក្រុមនានា (ឧទាហរណ៍ សហគមន៍មូលដ្ឋាន) និងស្ត្រីដែលពឹងផ្អែកលើព្រៃឈើសម្រាប់ការចិញ្ចឹមជីវិត (អនុផលព្រៃឈើ - NTFP)។ | ២០០លានដុល្លារអាម៉េរិក (LTS4CN) (i-v)<br>២០លានដុល្លារអាម៉េរិក (vi) ការចែកកូនឈើដល់សហគមន៍ (១00 លានកូនឈើ ១ ដុល្លារអាម៉េរិកក្នុងមួយដើម) ប្រហែល | i- បង្កើតនិងអនុវត្តផែនការគ្រប់គ្រងធនធានធម្មជាតិដែលមានការចូលរួម។<br>ii- យុទ្ធសាស្ត្របង្កើនការចូលរួមនៃវិស័យឯកជននិងសហគមន៍ និងការពាក់ព័ន្ធក្នុងការគ្រប់គ្រងធនធានធម្មជាតិនិងការបង្កើនគម្របព្រៃឈើ (ឧ. តាមរយៈរេដបូក)។<br>iii- បង្កើនការរួមចំណែករបស់សហគមន៍មូលដ្ឋានក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (ឧ. ដោយរកប្រាក់ចំណូលពីឥណទានកាបូន)។<br>iv- អនុវត្តវិធីធ្វើកសិកម្មដែលមាននិរន្តរភាពក្នុងចំណោមសហគមន៍មូលដ្ឋាន ដូចជា ជៀសវាងការធ្វើកសិកម្មពនេចរ តាមរយៈការពង្រីកកសិរុក្ខកម្ម ដើម្បីលើកកម្ពស់ជីវភាពរស់នៅ និងសន្តិសុខស្បៀង។<br>v- ពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិឱ្យបានពេញលេញ ដើម្បីបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ។ | • MoT<br>• MAFF<br>• MoE<br>• MOP<br>• MLVT<br>• MAFF |

| | | | | | |
|---|---|---|---|---|---|
| | • សម្រេចបានគោលដៅLTS4CN ដែលពាក់ព័ន្ធ<br>• បង្កើនការទទួលយកគំរូកសិកម្មស្ថារគុណភាពដី និងឆ្លាតចំពោះអាកាសធាតុ និងសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័ន។ | | ១០០ ដុល្លារអាម៉េរិក (vii)<br>និងយុទ្ធនាការដាំកូនឈើ២លានដុល្លារអាម៉េរិក (vii)។ | vi- ពិនិត្យនិងបន្សុីគោលនយោបាយឡើងវិញ ដើម្បីបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ លុបចោលរាល់ការលើកទឹកចិត្តដែលនាំឱ្យមានការកាប់ឈើ។<br>vii- បង្កើនការចូលរួមនៃភាគីពាក់ព័ន្ធ អង្គការសង្គមស៊ីវិល សហគមន៍ និងវិស័យឯកជន ក្នុងយុទ្ធនាការដាំដើមឈើ (យ៉ាងតិច១លានដើម/ឆ្នាំ)។<br>**តម្រូវការបច្ចេកវិទ្យានិងសមត្ថភាពមនុស្ស**<br>• ការរៀនសូត្រនិងការបណ្តុះបណ្តាលជាបន្តបន្ទាប់អំពីរេដបូក ឥណទានកាបូន ហិរញ្ញប្បទានកាបូន ការល្បាតឆ្លាតវៃ GISនិងព័ត៌មានផ្កាយរណប<br>• ស្រាវជ្រាវនិងអភិវឌ្ឍន៍អំពីការពង្រីកមុខរបរដែលផ្អែកលើផលិតផលជំនួសនិងមិនមែនព្រៃឈើ<br>• ស្រាវជ្រាវ អភិវឌ្ឍន៍ និងពង្រីកកសិកម្មកចាំបាច់ក្តដី/ក្តតិចតួច<br>• បច្ចេកវិទ្យា ឧបករណ៍និងការបណ្តុះបណ្តាលដើម្បីប្រមូលព័ត៌មានបច្ចេកទេសការឃ្លាំមើល និងការអនុវត្តច្បាប់ប្រឆាំងការកាប់បំផ្លាញព្រៃឈើ<br>• មូលដ្ឋានទិន្នន័យជាតិ និងសហគមន៍អ្នកអនុវត្តស្តីពីបច្ចេកវិទ្យា ឧបករណ៍ការបណ្តុះបណ្តាលអំពីការគ្រប់គ្រងធនធានធម្មជាតិតាមបែបចូលរួម។ | |

## តារាងទី២ : គោលដៅយុទ្ធសាស្ត្រ២ : គោលដៅ សកម្មភាព និងធនធានសំខាន់ៗ សម្រាប់ពង្រឹងសមត្ថភាពបន្សាំ

| គោលដៅយុទ្ធសាស្ត្រ២ : ពង្រឹងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ : បញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) ទៅក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធ ដូចជា NDCs, ដំណើរការ NAP និងការប្រាស្រ័យទាក់ទងនិងហិរញ្ញប្បទាន ផែនការសកម្មភាពយុទ្ធសាស្ត្រជាតិកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | | | | | |
|---|---|---|---|---|---|
| លទ្ធផលយុទ្ធសាស្ត្រ | គោលដៅ | ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI | ថវិកាប៉ាន់ស្មាន | សកម្មភាព | ស្ថាប័នសំខាន់ៗជាអ្នកអនុវត្ត |
| ២.១- ពង្រឹងវិធានការបង្កើនភាពធន់នៅគ្រប់វិស័យសេដ្ឋកិច្ច និងសេវាសង្គមសំខាន់ៗ (សេវាកម្មទឹកស្អាត អគ្គិសនី អនាម័យ ការថែទាំសុខភាព អាហារូបត្ថម្ភ ការអប់រំ និងកិច្ចគាំពារកុមារនិងសង្គម ទេសចរណ៍ ប្រព័ន្ធស្បៀងអាហារ ដែលមាននិរន្តរភាព និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជា WASH ថាមពល | • កំណើនចំនួនទីសាធារណៈ ដែលមានភាពធន់ (ឧ. មន្ទីរពេទ្យ មជ្ឈមណ្ឌលសហគមន៍ និងសាលារៀន)<br>• ពង្រឹងកិច្ចគាំពារពលកម្ម និងកាត់បន្ថយការបាត់បង់ផលិតភាពពីភាពតានតឹងនៃកម្ដៅ<br>• ពង្រីកលទ្ធភាពទទួលបានទិន្នន័យសុខភាពជាសាធារណៈ<br>• បង្កើនសមត្ថភាពធន់នៃវិស័យសង្គមសំខាន់ៗ ដើម្បីកែលម្អមុខងារ និងសេវាកម្មក្នុងកំឡុងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ | • សមាហរណកម្ម GEDSI ទៅក្នុងការកសាងភាពធន់សម្រាប់វិស័យសេដ្ឋកិច្ច (រួមទាំងការងាររបស់យុវជន កុមារ ការអប់រំ) សមត្ថភាពសម្រាប់វាយតម្លៃភាពងាយរងគ្រោះ។ | សមត្ថភាពសម្រាប់ការវាយតម្លៃភាពងាយរងគ្រោះ ៣,៩លានដុល្លារអាមេរិក ធ្វើការវិភាគហានិភ័យអាកាសធាតុសម្រាប់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់និងផ្ដល់អនុសាសន៍ (៣២៥,000 ដុល្លារអាមេរិក) ពង្រឹងសមត្ថភាពស្ថាប័ន (១០៨,000ដុល្លារអាមេរិក) និងការវាយតម្លៃភាពងាយរងគ្រោះក្នុងការឈានទៅអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ (២,៦លានដុល្លារអាមេរិក) (i)<br>៣,៧ពាន់លានដុល្លារអាមេរិក – សម្រាប់ការបង្កើនស្តង់ដាធន់នៃហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនថ្មីៗ និងការកសាងបណ្តាញដឹកជញ្ជូនដែលធន់ (ii)<br>៩៤លានដុល្លារអាមេរិក - ភាពធន់នៃទីក្រុង (iii)<br>លំនៅឋានថ្លៃទាប/សមរម្យ ៣៣លានដុល្លារអាមេរិក (iv) | i- ការវាយតម្លៃភាពងាយរងគ្រោះពេញលេញខាង GEDSI នៃហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសំខាន់ៗ ទីក្រុង ឆ្នេរសមុទ្រ និងទន្លេ សន្តិសុខទឹក និងថាមពល និងអនុវត្តវិធានការទប់ទល់ (ដូចជា សង់បង្កើយទំនប់ការពារច្រាំងសមុទ្រ ទប់ស្កាត់ការហូរច្រោះតាមឆ្នេរសមុទ្រ គ្រប់គ្រង/ការពារទឹកជំនន់ក្នុងទីក្រុង កែលម្អទិន្នន័យសុខភាពមនុស្ស សត្វ និងរុក្ខជាតិ សមត្ថភាពផ្តល់កិច្ចគាំពារសង្គមនិងត្រួតពិនិត្យភាពខ្វះចន្លោះ)។<br>ii- បង្កើតនិងអនុវត្តស្តង់ដា/លក្ខខណ្ឌតម្រូវសម្រាប់ការរចនាដែលធន់នឹងអាកាសធាតុ និងសម្ភារៈសាងសង់ផ្លូវថ្មី និងការថែទាំផ្លូវដែលមានស្រាប់ឆ្លើយតបនឹងហានិភ័យអាកាសធាតុ និងភាពងាយរងគ្រោះ<br>iii- បង្កើតនិងអនុវត្តការណែនាំអំពីភាពបៃតងក្នុងទីក្រុង និងភាពធន់នៅក្នុងផែនការមេអភិវឌ្ឍន៍ទីក្រុង ដែលរួមបញ្ចូល GEDSI និងដំណោះស្រាយផ្អែកលើធម្មជាតិ (NbS)។<br>iv- បង្កើតនិងអនុវត្ត GEDSI ឆ្លើយតបទៅនឹងតម្រូវការលំនៅឋានថ្លៃសមរម្យថ្លៃទាប និងធន់ នៅក្នុងផែនការមេ និងការអភិវឌ្ឍទីក្រុង/ទីប្រជុំជន។ | • MME<br>• MAFF<br>• MEF<br>• MoE<br>• MoH<br>• MLMUPC<br>• MRD<br>• MoWA<br>• MPWT<br>• NCDM<br>• MISTI<br>• MoH<br>• MoEYS<br>• MOSVY<br>• NSPC |

| | | | | | |
|---|---|---|---|---|---|
| ផ្លូវថ្នល់។ល។) ដោយផ្តោតជាពិសេស លើតម្រូវការរបស់កុមារ និងសហគមន៍ដែលងាយរងគ្រោះបំផុត។ | • បង្កើនប្រវែងផ្លូវដែលបានជួសជុល ដែលបានបញ្ចូលភាពធន់នឹងអាកាសធាតុ<br>• ពង្រីកលទ្ធភាពទទួលបានលំនៅឋានថ្លៃទាបសម្រាប់គ្រួសារដែលមានចំណូលទាប និងបង្កើតជម្រកថ្លៃទាបដែលធន់នឹងអាកាសធាតុសម្រាប់អ្នកទទួលបានដីធ្លី<br>• បង្កើនសមត្ថភាពឆ្លើយតបទៅនឹងអសន្តិសុខស្បៀង កាត់បន្ថយហានិភ័យ។ | | ៣៧០លានដុល្លារអាម៉េរិកសម្រាប់វិស័យទឹកដែលធន់ - ការកែលំអ ការរៀបចំឡើងវិញ និងការស្តារឡើងវិញនូវអាងស្តុកទឹក និងទំនប់ដែលមានស្រាប់ និងការបន្ថែមមុខងារ ដូចជាការគ្រប់គ្រងទឹកជំនន់ និងសមត្ថភាពស្តុកបន្ថែម (v-viii)<br>៨០លានដុល្លារអាម៉េរិក សម្រាប់ WASH ដែលមានភាពធន់<br>៦២លានដុល្លារអាម៉េរិក – អគារមណ្ឌលថែទាំសុខភាពដែលធន់នឹងអាកាសធាតុ (ix-xi) | v- ពិនិត្យនិងរៀបចំកន្លែងស្តុកទឹកឡើងវិញសម្រាប់ភាពធន់នឹងអាកាសធាតុ សុវត្ថិភាព និងគុណភាពធនធានទឹក។<br>vi- ជំរុញការអនុវត្តវិធាននៃការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM)[14]។<br>vii- ពិនិត្យនិងផ្តល់អាទិភាពដល់កិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងតំបន់ និងជំនួយក្នុងការគ្រប់គ្រងធនធានទឹកឆ្លងដែន ដោយផ្អែកលើគោលការណ៍ GEDSI និងមិនទុកអ្នកណាម្នាក់ចោលឡើយ (LNOB)។<br>viii- កសាងផែនទីទឹកក្រោមដី ការត្រួតពិនិត្យ និងយុទ្ធសាស្ត្រគ្រប់គ្រងសម្រាប់សន្តិសុខទឹកនិងធន់នឹងអាកាសធាតុ។<br>ix- ផែនការធានាប់រងនិងការថែទាំសុខភាព កាលវិភាគធ្វើការសម្រាកកម្សាន្ត (WRS) ដែលត្រូវគ្នានឹងតម្រូវការនៃ GEDSI និងផលប៉ះពាល់សុខភាពពីការប្រែប្រួលអាកាសធាតុ ដូចជា ភាពតានតឹងដោយសារកម្តៅសម្រាប់កម្មករ/អ្នកធ្វើការងារក្រៅផ្ទះ។ | |

[14] ការគ្រប់គ្រងធនធានទឹកចម្រុះ(IWRM) ត្រូវបានកំណត់ដោយភាពជាដៃគូទឹកសកល (GWP) ថាជា "ដំណើរការដែលជំរុញការអភិវឌ្ឍដែលមានការសម្របសម្រួល និងគ្រប់គ្រងទឹក ដី និងធនធានដែលពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចនិងសុខុមាលភាពសង្គមដោយសមធម៌ ដោយមិនប៉ះពាល់ដល់និរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ"។ គោលគំនិតអំពី IWRM ត្រូវបានបញ្ចូលទៅក្នុងកម្មវិធី ភាគច្រើនរបស់គណៈកម្មការទន្លេមេគង្គ (MRC)។ ប្រទេសកម្ពុជាជាសមាជិកនៃ MRC ហើយអាចមានលទ្ធភាពទទួលបានចំណេះដឹងបច្ចេកទេស និងការកសាងសមត្ថភាពនៅក្នុងតំបន់នេះ ដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុក្នុងការគ្រប់គ្រងនិងសន្តិសុខធនធានទឹក។

| គោលដៅយុទ្ធសាស្ត្រ២ : ពង្រឹងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ : បញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម(GEDSI) ទៅក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធ ដូចជា NDCs, ដំណើរការ NAP និងការប្រាស្រ័យទាក់ទងនិងហិរញ្ញប្បទាន ផែនការសកម្មភាពយុទ្ធសាស្ត្រជាតិកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | | | | | |
|---|---|---|---|---|---|
| លទ្ធផលយុទ្ធសាស្ត្រ | គោលដៅ | ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI | ថវិកាប៉ាន់ស្មាន | សកម្មភាព | ស្ថាប័នសំខាន់ៗជាអ្នកអនុវត្ត |
| ២.២- បង្កើនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការត្រៀមបង្ការនិងការស្តារឡើងវិញនៅទូទាំងសហគមន៍ (សហគមន៍ឆ្នេរ បឹងទន្លេសាប និងសហគមន៍តាមដងទន្លេមេគង្គ) | • កាត់បន្ថយឱ្យបានច្រើននូវសំណល់និងការបំពុលប្លាស្ទិកនៅក្នុងបឹងទន្លេសាប និងតំបន់ឆ្នេរ ដីចំណីស្នឹងនៅតំបន់ខ្សែទឹកខាងលើ តំបន់ដីសើមនិងតំបន់បរិស្ថានផុយស្រួយផ្សេងទៀត ។<br>• ការកើនឡើងភាគរយនៃព្រៃលិចទឹក និងព្រៃកោងកាងដែលបានស្តារឡើងវិញនិងការពារ ធ្វើឱ្យអេកូឡូស៊ីបឹងនិងតំបន់ឆ្នេរមានជីវិតឡើងវិញ | សូមអានខាងលើ | ប្រព័ន្ធប្រកាសអាសន្ន និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ – ៣០លានដុល្លារអាម៉េរិក[15] | i- សាកល្បងនិងពង្រីកកិច្ចផ្តួចផ្តើមសេវាកម្មសង្គមឆ្លាតវៃ លើផ្នែកGEDSI ដែលឆ្លើយតបនឹងអាកាសធាតុ (ការអប់រំ សុខភាព កិច្ចគាំពារកុមារ)[16]។<br>ii- ពង្រីកអនុលោមភាពជាមួយគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោក សម្រាប់ឧបករណ៍ថែទាំសុខភាពដែលធន់នឹងអាកាសធាតុ និងនិរន្តរភាពបរិស្ថាន និងបន្សាំបច្ចេកវិទ្យា EWS[17] និងមូលដ្ឋានទិន្នន័យសុខភាព។<br>iii- ពិនិត្យនិងអនុវត្តការងារកែលម្អនៅក្នុងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ[18] ជំរុញផែនការអនុវត្ត ការអនុវត្តយុទ្ធសាស្ត្រផ្តល់ហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយ (២០២៣-២០២៨)។<br>iv- ពិនិត្យមើលសមត្ថភាពស្តុកទុកអាហារសង្គ្រោះបន្ទាន់ រួមទាំងកន្លែងផ្ទុកត្រជាក់។ | សូមអានខាងលើ |

[15] ជាតុចូលពីកម្មវិធីស្បៀងអាហារពិភពលោក (WFP) - គម្រោងបំពង់បង្ហូរប្រេងសំខាន់ៗដែលបានបញ្ជាក់នាពេលបច្ចុប្បន្នបានផ្តោតលើ EWS មានថវិកាសរុបចំនួនច្រើនជាង៣០លានដុល្លារអាម៉េរិក(CREWS, GCF-UNDP, SOFF)។ ការព្រមានជាមុនដល់ផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តទាំងអស់ (នឹងរៀបចំរួចរាល់ក្នុងពេលឆាប់ៗខាងមុខនេះ) នឹងផ្តល់នូវការប៉ាន់ប្រមាណតម្លៃលម្អិតបន្ថែមទៀតដែលទាក់ទងនឹង EWS ។

[16] កិច្ចគាំពារសង្គមដោយឆ្លាតវៃចំពោះអាកាសធាតុ ដោះស្រាយភាពងាយរងគ្រោះខាងអាកាសធាតុ សេដ្ឋកិច្ច បរិស្ថាន និងសង្គម ចំពោះអសន្តិសុខ និងភាពក្រីក្រ តាមរយៈកិច្ចការពារនិងលើកកម្ពស់ជីវភាពរស់នៅ (FAO, 2017) - គម្រោងទូទាត់សាច់ប្រាក់ តាមដានរបស់សុខភាពកំឡុងពេលមានគ្រោះមហន្តរាយ។ល។

[17] កែលម្អសង្គតិភាពលើការរចនានិងប្រព័ន្ធផ្សេងៗ។

[18] ផ្តោតលើការដាក់ពង្រាយសេវាសង្គ្រោះបន្ទាន់ថ្នាក់ជាតិ ការពង្រឹងប្រព័ន្ធប្រកាសអាសន្ន វិសាលភាពគ្របដណ្តប់នៃEWS1294 ហូតដល់**ចម្ងាយឆ្ងាយបំផុតនៃបណ្តាញទំនាក់ទំនង** (ការប្រើបាននិងកម្រិតទាន់ពេលវេលា) អាចបម្រើវិស័យដែលងាយរងគ្រោះដោយអាកាសធាតុ ដូចជា កសិកម្ម ថាមពល ធនធានទឹក ការផ្គត់ផ្គង់ សុខភាពជាដើម។ បន្សាំបច្ចេកវិទ្យានិងមូលដ្ឋានទិន្នន័យ EWS បច្ចុប្បន្ន។ល។ បង្កើតនិងអនុវត្ត "**ផែនការសកម្មភាពគ្រោងទុក និងប្រព័ន្ធប្រកាសអាសន្ន** " **ដែលពង្រឹងភាពធន់នឹងហានិភ័យគ្រោះមហន្តរាយ និងការឆ្លើយតប**។

| | | | | | |
|---|---|---|---|---|---|
| | • កាត់បន្ថយប្រភេទរាតត្បាតនៅតំបន់ដីសើម ដែនទឹក និងតំបន់ឆ្នេរ<br>• បង្កើនចំនួននៃការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍<br>• ពង្រីកវិធានការពង្រឹងសមត្ថភាពបន្សាំរបស់សហគមន៍ ទៅនឹងការប្រែប្រួលអាកាសធាតុ<br>• ពង្រឹងនិងធ្វើពិពិធកម្មជីវភាពក្នុងមូលដ្ឋាន កែលំអលក្ខខណ្ឌការងារសមរម្យ (រួមទាំងការងារបៃតងនិងការងារអេកូទេសចរណ៍ បន្ថែមពីលើការនេសាទ)<br>• ពង្រឹងនិងពង្រីកប្រព័ន្ធផ្តល់ព័ត៌មាន និងការត្រៀមបង្ការនិងការឆ្លើយតបនឹងគ្រោះមហន្តរាយ (រួមទាំងទិន្នន័យកម្រិតសហគមន៍ អំពីជំងឺសត្វនិងរុក្ខជាតិ សុខភាពមនុស្ស)<br>• ការស្តារនិងកែលំអឡើងវិញនូវប្រព័ន្ធអេកូឡូស៊ីដែលខូចគុណភាព និងការពារព្រៃឈើ វាលទំនាបលិចទឹក និងតំបន់ឆ្នេរ។ | | | v- បញ្ចូលវិធានការទប់ទល់នឹងហានិភ័យគ្រោះមហន្តរាយនិងវិធានការកាត់បន្ថយ ស្តង់ដាការពាររបបអាហារ និងទប់ស្កាត់កង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ ក្នុងករណីទឹកជំនន់និងគ្រោះរាំងស្ងួត។ (ក្នុងទម្រង់ជាសាច់ប្រាក់ដែលរំពឹងទុក និង SBC)។<br>vi- បង្កើនការយល់ដឹងនិងការអនុវត្តវិធានការអភិវឌ្ឍកាបូនខៀវ[19]។<br>vii- ឧបករណ៍វិភាគភូមិសាស្ត្រសម្រាប់អាកាសធាតុសម្រាប់បន្តការវាយតម្លៃភាពងាយរងគ្រោះនៅទូទាំងតំបន់ផុយស្រួយនៅក្នុងប្រទេស<br><br>**តម្រូវការបច្ចេកវិទ្យានិងសមត្ថភាពមនុស្ស**<br><br>• សមត្ថភាពបច្ចេកទេសលើការបញ្ចូល GEDSI និង LNOB ការវាយតម្លៃ និងការអនុវត្តអន្តរាគមន៍ដើម្បីកសាងភាពធន់និងការកាត់បន្ថយហានិភ័យ<br>• ប្រព័ន្ធព្រមានជាមុន បច្ចេកវិទ្យា និងឧបករណ៍ GEDSI/បរិយាបន្ន<br>• វេទិកា/ប្រព័ន្ធចែករំលែកព័ត៌មានអាកាសធាតុនិងទិន្នន័យឧតុនិយមទាន់ពេល<br>• ប្រព័ន្ធតាមដាននិងព័ត៌មានកសិកម្ម (AMIS)<br>• សមត្ថភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីធ្វើការវាយតម្លៃនិងការរចនាដែលធន់នឹងអាកាសធាតុ<br>• កម្មវិធីសិក្សា កម្មវិធីរៀនសូត្របន្ត និងអភិវឌ្ឍជំនាញវិជ្ជាជីវៈសម្រាប់វិទ្យាសាស្ត្រអាកាសធាតុ ឧតុនិយម និងគ្រោះមហន្តរាយ ការគ្រប់គ្រង ការស្តារឡើងវិញ និងការទប់ស្កាត់...<br>• ឧបករណ៍ឌីជីថលដើម្បីសម្រួលដល់ការចែកចាយជំនួយនិងការផ្ទេរសាច់ប្រាក់បន្ទាន់ប្រកបដោយប្រសិទ្ធភាព។ | |

[19] (WB 2023 - "កាបូនខៀវ" សំដៅលើ កាបូនដែលរក្សាទុកនៅក្នុងប្រព័ន្ធអេកូឡូស៊ីឆ្នេរសមុទ្រនិងសមុទ្រ។ ប្រព័ន្ធអេកូឡូស៊ីទាំងនេះ រាប់បញ្ចូលគ្រប់យ៉ាងទាំងអស់ ដែលរាប់ចាប់ពីព្រៃកោងកាងរហូតដល់វាលស្មៅសមុទ្រនិងវាលភក់។ ក្របខណ្ឌត្រៀមបង្ការសម្រាប់កាបូនខៀវដំបូងបង្អស់របស់ធនាគារពិភពលោក ផ្តល់អំណាចដល់រដ្ឋាភិបាលនានា ក្នុងការទាញយកសក្តានុពលកាបូនខៀវពេញលេញរបស់ខ្លួន ដើម្បីផ្តល់អត្ថប្រយោជន៍ដល់មនុស្សនិងភពផែនដី។ (WB 2023 - Unlocking Blue Carbon Development)។

| គោលដៅយុទ្ធសាស្ត្រ២ : ពង្រឹងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ : បញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) ទៅក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធ ដូចជា NDCs, ដំណើរការ NAP និងការប្រាស្រ័យទាក់ទងនិងហិរញ្ញប្បទាន ផែនការសកម្មភាពយុទ្ធសាស្ត្រជាតិកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | | | | | |
|---|---|---|---|---|---|
| **លទ្ធផលយុទ្ធសាស្ត្រ** | **គោលដៅ** | **ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI** | **ថវិកាប៉ាន់ស្មាន** | **សកម្មភាព** | **ស្ថាប័នសំខាន់ៗជាអ្នកអនុវត្ត** |
| ២.៣- ពង្រឹងការអភិរក្សប្រព័ន្ធអេកូឡូស៊ី និងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព (រួមទាំងទន្លេមេគង្គ បឹងទន្លេសាប ព្រៃឈើ ជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ីទីក្រុង និងបញ្ជ្រាបដំណោះស្រាយ និងការបន្សាំតាមធម្មជាតិ) | • ជំរុញការអភិរក្សប្រព័ន្ធអេកូឡូស៊ី<br>• ពង្រីកវិធានការដែលមាននិរន្តរភាពនិងធន់សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ (ឧ. ការបញ្ចូលវិធានការបន្សាំផ្អែកលើប្រព័ន្ធអេកូឡូស៊ី ការបង្កើតប្រព័ន្ធអេកូឡូស៊ី/ជម្រកឡើងវិញ)។ | • រួមបញ្ចូល GEDSI និងលើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាននៅក្នុងការអភិរក្ស និងភាពធន់នៃប្រព័ន្ធអេកូការអភិរក្សជីវៈចម្រុះ។ | ការគ្រប់គ្រងធនធានធម្មជាតិចម្រុះ(INRM)[20] នៅក្នុងតំបន់ទេសភាពដែលមានផលិតភាពធម្មជាតិ និងព្រៃឈើ នៃតំបន់ភាគខាងជើងប្រទេសកម្ពុជា និងគម្រោងអភិរក្សព្រៃឡង់ ប្រមាណ៦លានដុល្លារអាមេរិក (i)<br><br>កាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍មូលដ្ឋាន តាមរយៈកំណែទម្រង់អភិបាលកិច្ចអាកាសធាតុថ្នាក់ក្រោមជាតិ (ផ្តោតលើ | i- បង្កើនសមត្ថភាពសហគមន៍លើការគ្រប់គ្រងធនធានធម្មជាតិតាមបែបសហគមន៍ (CBNRM) ក្នុងចំណោមសហគមន៍ឆ្នេរ បឹងទន្លេសាប និងសហគមន៍ទន្លេមេគង្គ តំបន់ឆ្នេរសមុទ្រ តំបន់ខ្ពង់រាប និងសហគមន៍ទីក្រុង។<br>ii- សមត្ថភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ពង្រឹងភាពអង់អាចរបស់សហគមន៍មូលដ្ឋាន ដើម្បីអភិវឌ្ឍ/កែលំអទេសចរណ៍ធម្មជាតិតាមសហគមន៍។<br>iii- ពង្រីកការអភិរក្ស សាងសង់ទីជម្រាល និងកន្លែងស្តុកទឹក និងពង្រីក NbS សម្រាប់ការអភិរក្សនិងការគ្រប់គ្រងធនធានទឹក។<br><br>**តម្រូវការបច្ចេកវិទ្យានិងសមត្ថភាពមនុស្ស**<br><br>• ពង្រឹងសមត្ថភាពស្ត្រីនិងស្ត្រីក្នុងភាពជាអ្នកដឹកនាំ ដើម្បីការពារនិងអភិរក្សធនធានធម្មជាតិ រួមមានព្រៃឈើ ជលផល និងធនធានទឹក។<br>• បង្កើតសហគមន៍អ្នកអនុវត្តសម្រាប់ប្រព័ន្ធអេកូឡូស៊ីនិងការបន្សាំនៅតាមសហគមន៍។ | • MME<br>• MAFF<br>• MEF<br>• MoE<br>• MoH<br>• MLMUPC<br>• MRD<br>• MoWA<br>• MPWT<br>• NCDM<br>• MISTI<br>• MoEYS<br>• MOSVY<br>• NCDM<br>• MOP |

[20] INRM គាំទ្រ និងជំរុញការបង្កើតកម្មវិធីចម្រុះ នៅទូទាំងវិស័យដែលតាមធម្មតា ចាត់ថ្នាក់ជា "បរិស្ថាន" ដូចជាការប្រើប្រាស់ដី ព្រៃឈើ និងការអភិរក្សជីវៈចម្រុះ និងការប្រែប្រួលអាកាសធាតុ ព្រមទាំងវិស័យជាច្រើនដែលតាមប្រពៃណីមិនបានផ្សារភ្ជាប់ទៅនឹងកម្មវិធីបរិស្ថាន ប៉ុន្តែតាមពិតមានទំនាក់ទំនងយ៉ាងរឹងមាំ (ឧ. សន្តិសុខស្បៀង សុខភាព និងអភិបាលកិច្ច)។(USAID, 2021 - ការគ្រប់គ្រងធនធានធម្មជាតិចម្រុះ https://pdf.usaid.gov/pdf_docs/PA00XX15.pdf

| | | | | | |
|---|---|---|---|---|---|
| | | | គោលនយោបាយ) ១០លានដុល្លារអាម៉េរិក និងការកសាងសមត្ថភាពបន្សាំ និងធន់សម្រាប់មន្ត្រីMRD នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ – ១០លានដុល្លារអាម៉េរិក (ii)។ | | • NSAF<br>• NCDDS |

| គោលដៅយុទ្ធសាស្ត្រ២ : ពង្រឹងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ : បញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) ទៅក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធ ដូចជា NDCs, ដំណើរការ NAP និងការប្រាស្រ័យទាក់ទងនិងហិរញ្ញប្បទាន ផែនការសកម្មភាពយុទ្ធសាស្ត្រជាតិកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | | | | | |
|---|---|---|---|---|---|
| **លទ្ធផលយុទ្ធសាស្ត្រ** | **គោលដៅ** | **ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI** | **ថវិកាប៉ាន់ស្មាន** | **សកម្មភាព** | **ស្ថាប័នសំខាន់ៗជាអ្នកអនុវត្ត** |
| ២.៤- ពង្រឹងភាពធន់នៃក្រុមជនដែលងាយរងគ្រោះ (ដូចជា កុមារ និងសហគមន៍មូលដ្ឋាន) និងបញ្ជ្រាប GEDSI ទៅក្នុងសកម្មភាពដោះស្រាយបញ្ហាអាកាសធាតុ និងភាពធន់ | • ពង្រឹងសមត្ថភាពស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបញ្ចូលការឆ្លើយតបខាងយេនឌ័រនៅក្នុងគោលនយោបាយ ផែនការ ការបង្កើតកម្មវិធី រួមទាំងថវិកាសម្រាប់កិច្ចការយេនឌ័រ<br>• ពង្រឹងប្រព័ន្ធតាមដាននិងវាយតម្លៃរបស់ក្រសួងតាមវិស័យ ដើម្បីតាមដានលទ្ធផលយេនឌ័រក្នុងកិច្ចផ្តួចផ្តើមប្រែប្រួលអាកាសធាតុ ដោយផ្តោតដែលរួមទាំងអំពីការប្រមូល និង | • ការវាយតម្លៃតម្រូវការសមត្ថភាពរបស់ក្រុមងាយរងគ្រោះ<br>• ការចុះបញ្ជីគ្រួសារដែលងាយរងគ្រោះ ទន់ខ្សោយ និងគ្រួសារដែលមានពិការភាព ធ្វើការវិភាគផែនទីហានិភ័យ។ | ខ្សែចង្វាក់ផ្គត់ផ្គង់ទីផ្សារសម្រាប់ស្ត្រីសហគ្រិននៅតាមជនបទដែលធន់នឹងការប្រែប្រួលអាកាសធាតុ – ៨លានដុល្លារអាម៉េរិក (ii)<br>ពង្រឹងសមត្ថភាពស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបញ្ចូលការឆ្លើយតបខាងយេនឌ័រ – ០,៥លានដុល្លារអាម៉េរិក (iii)<br>បង្កើនការសម្របសម្រួលនិងការអនុវត្តយន្តការគណនេយ្យភាព ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុរបស់ស្ត្រីដែល | i- អនុវត្តប្រព័ន្ធគាំពារសង្គមដែលអាចបន្សាំបានទូលំទូលាយ (ឧ. ពង្រីកកម្មវិធីផ្ទេរសាច់ប្រាក់ជំនួយសង្គមដែលគ្របដណ្តប់គ្រួសារដែលងាយរងគ្រោះ (និងក្រុមនានា ដូចជា កុមារ ជនពិការ និងសហគមន៍មូលដ្ឋាន)<br>ii- ធ្វើពិពិធកម្មរបរចិញ្ចឹមជីវិតសម្រាប់ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលមិនកើតឡើងភ្លាមៗក្នុងចំណោមក្រុមដែលងាយរងគ្រោះ<br>iii- កសាងសមត្ថភាពធន់សម្រាប់សហគមន៍ដែលងាយរងគ្រោះនិងសហគមន៍គ្រប់គ្រងធនធានធម្មជាតិតាម | |

| | | | | | |
|---|---|---|---|---|---|
| | គ្រប់គ្រងទិន្នន័យដែលញែកដាច់គ្នាតាមភេទ សូចនាករយេនឌ័រ និងថវិកា និងការរាយការណ៍ផ្អែកលើលទ្ធផល។<br>• ពង្រឹងការចូលរួមរបស់មនុស្សដែលត្រូវបានកំណត់ថា ជាជនងាយរងគ្រោះក្នុងដំណើរការគោលនយោបាយ។ | | ជួបការលំបាក និងក្រុមដែលខ្វះខាតផ្សេងទៀត – ៥០.០០០ដុល្លារអាមេរិក (iii)<br>គោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការបញ្ជ្រាបយេនឌ័រទៅក្នុងដំណើរការ NDC - ០,១២លានដុល្លារអាមេរិក (iv)<br>ពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃតាមវិស័យរបស់ក្រសួងនានាដើម្បីតាមដានលទ្ធផលយេនឌ័រនៅក្នុងកិច្ចផ្តួចផ្តើមប្រែប្រួលអាកាសធាតុដោយផ្តោតលើជាពិសេសការប្រមូល និងគ្រប់គ្រងទិន្នន័យញែកតាមភេទ សូចនាករយេនឌ័រ និងថវិកា – ០,២លានដុល្លារអាមេរិក<br>(v)ការអភិវឌ្ឍសមត្ថភាពសមាជិកគណៈកម្មាធិការប្រែប្រួលអាកាសធាតុ និងក្រសួងនានាលើការវិភាគយេនឌ័រ ការឆ្លើយតបខាងយេនឌ័រ និង NDC – ០,៤លានដុល្លារអាមេរិក (v)<br>០,៥ ពាន់លានដុល្លារអាមេរិក[21] (i-v) | រយៈការវិនិយោគគម្រោងបន្សាំផ្អែកលើធម្មជាតិ ការទទួលបានការផ្តល់ដំណឹងជាមុននិងការត្រៀមនឹងគ្រោះមហន្តរាយ និងជីវភាពធន់នឹងអាកាសធាតុ<br>iv- បង្កើតនិងអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ក្រសួង និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរួមបញ្ចូល GEDSI ទៅក្នុងគោលនយោបាយ ផែនការ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។<br>v- ពង្រីកការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តការឆ្លើយតបខាងយេនឌ័រ (រួមទាំងការដោះស្រាយអំពើហិង្សាផ្អែកលើយេនឌ័រ GBV) ផែនការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ<br>vi- រួមបញ្ចូលការអនុវត្តដែលផ្អែកលើលទ្ធផលនៃការឆ្លើយតបខាងយេនឌ័រទៅក្នុង ឆ្នាំCCCSP ២០២៤-២០៣៣ M&E និងប្រព័ន្ធរាយការណ៍<br>vii- បង្កើតលក្ខណៈវិនិច្ឆ័យដើម្បីជូនដំណឹងអំពីលទ្ធភាពទទួលបានសេវាកាន់តែប្រសើរឡើង ដូចជាកិច្ចគាំពារសង្គម សុខភាព ការអប់រំ និងប្រព័ន្ធទ្រទ្រង់មុខរបរ។ | |

[21] 20201231_NDC_Update_Cambodia.pdf (unfccc.int) ជំពូកការថវិកាបន្សាំ ២៦-៣០ អាចរកបានទិន្នន័យតិចតួចស្តីពីហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុ និងចំណងទាក់ទងជាមួយយេនឌ័រ (CPER 2022). ប៉ាន់ស្មានប្រហែល ៥០០លានដុល្លារអាមេរិក (UNICEF)

| | | | | | |
|---|---|---|---|---|---|
| | | | | តម្រូវការបច្ចេកវិទ្យានិងសមត្ថភាពមនុស្ស<br>• ក្របខ័ណ្ឌ GEDSI និងសមត្ថភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសម្រាប់ការពង្រឹងភាពធន់នៃក្រុមដែលងាយរងគ្រោះ និង GEDSI សំខាន់ៗក្នុងសកម្មភាពអាកាសធាតុ និងភាពធន់។ | |

**គោលដៅយុទ្ធសាស្ត្រ២ : ពង្រឹងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ : បញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម (GEDSI) ទៅក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធ ដូចជា NDCs, ដំណើរការ NAP និងការប្រាស្រ័យទាក់ទងនិងហិរញ្ញប្បទាន ផែនការសកម្មភាពយុទ្ធសាស្ត្រជាតិកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ**

| លទ្ធផលយុទ្ធសាស្ត្រ | គោលដៅ | ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI | ថវិកាប៉ាន់ស្មាន | សកម្មភាព | ស្ថាប័នសំខាន់ៗជាអ្នកអនុវត្ត |
|---|---|---|---|---|---|
| ២.៥- ពង្រឹងវិធានការនិរន្តរភាព និងភាពធន់ (រួមទាំង បច្ចេកវិទ្យាឆ្លាតវៃចំពោះលក្ខខណ្ឌអាកាសធាតុ កសិកម្មដែលស្ដារគុណភាពដីឡើងវិញ។ល។) ក្នុងវិស័យកសិកម្ម និងខ្សែចង្វាក់តម្លៃស្បៀង | • ពង្រីកកសិកម្មដែលធន់នឹងអាកាសធាតុ ដំណាំដែលធន់ ធនាគារគ្រាប់ពូជ ផលិតកម្ម/កាត់បន្ថយការបាត់បង់ផលដំណាំក្នុងពេលប្រមូលផលនិងពេលផលិត<br>• បង្កើតឯកសារណែនាំការបណ្ដុះបណ្ដាលស្ដីពី | • លទ្ធភាពក្នុងការកសាងសមត្ថភាព និងការបណ្ដុះបណ្ដាលដល់ស្ត្រី និងយុវជន ការចូលរួម និងការពង្រឹងភាពអង់អាច<br>• ការរចនានិងការអនុវត្តបច្ចេកវិទ្យាឆ្លាតវៃចំពោះអាកាសធាតុ | សកម្មភាព ៖<br>• ការកែលម្អសេវាគាំទ្រនិងការកសាងសមត្ថភាពសម្រាប់ការផលិតដំណាំដែលធន់នឹងការប្រែប្រួលអាកាសធាតុ - ៦៩លានដុល្លារអាម៉េរិក។<br>• ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍និងការលើកកម្ពស់ផលិតភាព គុណភាពកសិកម្ម និងការផ្ទេរសាច់ប្រាក់ ២លានដុល្លារអាម៉េរិក និង | i- ស្រាវជ្រាវនិងអភិវឌ្ឍ និងពង្រីកសេវាផ្សព្វផ្សាយដល់កសិករ ដោយលើកកម្ពស់ភាពធន់នឹងអាកាសធាតុ ដំណាំមានតម្លៃខ្ពស់ តម្លៃបន្ថែម និងលទ្ធភាពប្រើប្រាស់ទីផ្សារ។<br>ii- ពង្រីកការអនុវត្តកសិកម្មឆ្លាតវៃខាងអាកាសធាតុ ឧបករណ៍ហិរញ្ញវត្ថុ (រួមទាំងការធានារ៉ាប់រងដំណាំ កិច្ចការពារ/ស្ដារពីគ្រោះមហន្តរាយវិញ) និងតាមដានការទទួលយកបច្ចេកវិទ្យា/ការអនុវត្តនិងប្រសិទ្ធភាពនៃបច្ចេកវិទ្យានិងការអនុវត្តទាំងនោះ។<br>iii- បញ្ជ្រាប និងលើកទឹកចិត្តផ្នែកកសិកម្មអេកូឡូស៊ី ដំណោះស្រាយផ្អែកលើធម្មជាតិ និងការអនុវត្តកសិកម្មបង្កើនគុណភាពដី។ | • MEF<br>• MAFF<br>• MoE<br>• MoH<br>• MLMUPC<br>• MRD<br>• MoWA<br>• MPWT<br>• NCDM |

| | | | | | |
|---|---|---|---|---|---|
| អាហារសម្រាប់ប្រព័ន្ធស្បៀងដែលមាននិរន្តរភាព។ | មុខរបរឆ្លាតវៃ និងមាននិរន្តរភាពចំពោះអាកាសធាតុសម្រាប់អ្នកពាក់ព័ន្ធក្នុងខ្សែចង្វាក់តម្លៃកសិកម្ម<br>• ពង្រីកផលិតកម្មកសិកម្មដែលធន់នឹងអាកាសធាតុ ការកែច្នៃ ការចែកចាយ និងការប្រើប្រាស់ដែលរួមបញ្ចូលនៅទូទាំងតំបន់ដែលងាយរងគ្រោះ (ដូចជាតំបន់ភាគខាងជើងបឹងទន្លេសាប)<br>• បង្កើនពិពិធកម្មប្រព័ន្ធផលិតកម្ម ការចាត់ចែង និងការរក្សាទុកក្រោយការប្រមូលផល ពង្រឹងខ្សែចង្វាក់តម្លៃអាហារ និងបង្កើនស្បៀងបម្រុង។ | ដែលឆ្លើយតបនឹងយេនឌ័រ។ | • ការអភិវឌ្ឍបច្ចេកវិជ្ជាថ្មីនិងការបង្កើនទិន្នផល ដោយប្រើពូជដំណាំថ្មីដែលសម្របទៅនឹងការប្រែប្រួលអាកាសធាតុ ១៥លានដុល្លារអាមេរិក។<br>បង្កើតសៀវភៅណែនាំសម្រាប់បណ្តុះបណ្តាលនិងផ្តល់ការបណ្តុះបណ្តាលអំពីវិធីសាស្ត្រសម្រាប់អភិវឌ្ឍន៍ដែលឆ្លាតវៃចំពោះអាកាសធាតុ និងរបរដែលមាននិរន្តរភាពសម្រាប់ជនក្រីក្រនៅជនបទ - ១០ លានដុល្លារអាមេរិក (ចំណាំគម្រោងជានាវ៉ាប់រង ០,២៥ លានដុល្លារអាមេរិក) (ii)<br>អន្តរកាលកសិកម្មអេកូឡូស៊ីនៅតំបន់ខ្ពង់រាបនៃខេត្តបាត់ដំបង - ១០លានដុល្លា (iii)<br>ការគ្រប់គ្រងនិងការពារប្រព័ន្ធអេកូឡូស៊ីតំបន់សមុទ្រ និងតំបន់ឆ្នេរដោយប្រសិទ្ធភាព - ៧០លានដុល្លារអាមេរិក (iv)<br>ឯកសារណែនាំការបណ្តុះបណ្តាលនិងផ្តល់ការបណ្តុះបណ្តាលស្តីពីកសិកម្មឆ្លាតវៃចំពោះអាកាសធាតុ –១០លានដុល្លារអាមេរិក និងដលផលដែលធន់នឹងអាកាសធាតុ ៣៣,៥លានដុល្លារអាមេរិក (v) | iv- ពង្រីកកិច្ចការពារ(រួមទាំងពង្រឹងការអនុវត្ត)នៃជម្រកសំខាន់ៗសម្រាប់ជលផល (ព្រៃកោងកាង ស្មៅសមុទ្រ។ល។)។<br>v- ផ្តល់ការលើកទឹកចិត្តនៅកម្រិតសហគមន៍(ថ្នាក់ក្រោមជាតិ)ការវិនិយោគដែលធន់នឹងអាកាសធាតុសម្រាប់កសិករខ្នាតតូច(ការផ្ទុក ការបន្ថែមតម្លៃ ការប្រើប្រាស់ទីផ្សារ ការដំឡើងប្រព័ន្ធថាមពលព្រះអាទិត្យ ការប្រមូលទឹកភ្លៀង សន្តិសុខទឹក WASH។ល។)។<br>vi- ពិនិត្យនិងជំរុញការស្តារឡើងវិញនិងការពង្រីកប្រព័ន្ធស្រោចស្រព (ផ្តោតលើភាពធន់នឹងអាកាសធាតុ និងប្រសិទ្ធភាព)ផងដែរ ដោយគិតគូរអំពីទំនាក់ទំនងទឹក អាហារ ថាមពល (WFE)[22]។<br>vii- ធ្វើការវាយតម្លៃតម្រូវការសមត្ថភាព បង្កើត និងអនុវត្តកម្មវិធីស្តីពីរបរដែលធន់នឹងអាកាសធាតុនិងមាននិរន្តរភាព។<br>vii- បង្កើនការគាំទ្រដល់សហគមន៍ងាយរងគ្រោះ ដើម្បីអនុវត្តកសិកម្មឆ្លាតវៃ បច្ចេកវិទ្យាក្រោយការប្រមូលផល និងរបរដែលមាននិរន្តរភាព។<br>**តម្រូវការបច្ចេកវិទ្យានិងសមត្ថភាពមនុស្ស**<br>• កម្មវិធីកសាងសមត្ថភាពសម្រាប់មន្ត្រីបច្ចេកទេសកសិកម្មថ្មីនៅថ្នាក់ឃុំ និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិលើបច្ចេកវិទ្យាឆ្លាតវៃចំពោះអាកាសធាតុ កសិកម្មបង្កើនគុណភាពដី ឧបករណ៍វាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ។ល។ នៅក្នុងខ្សែចង្វាក់តម្លៃកសិកម្ម ស្បៀងអាហារ និងផ្តល់ការផ្សព្វផ្សាយបច្ចេទេសដល់សហគមន៍ងាយរងគ្រោះ | • MISTI |

[22] WFE ចែងអំពីការយល់ដឹងនិងការគ្រប់គ្រងផលប្រយោជន៍ដែលមានលក្ខណៈប្រកួតប្រជែងគ្នាជាញឹកញាប់ ដែលទាក់ទងនឹងសន្តិសុខទឹក អាហារ និងថាមពល ទន្ទឹមនឹងធានាបាននូវសុចរិតភាពនៃប្រព័ន្ធអេកូឡូស៊ី (FAO). https://www.fao.org/land-water/water/watergovernance/waterfoodenergynexus/en/

| | | | | | |
|---|---|---|---|---|---|
| | | | ពង្រីកផលិតកម្មកសិកម្មដែលធន់នឹងអាកាសធាតុតាមរយៈការបង្កើនលទ្ធភាពទទួលបានប្រព័ន្ធស្រោចស្រពដើរដោយថាមពលព្រះអាទិត្យ-១០លានដុល្លារអាម៉េរិក (vi)<br><br>សូមអាន ៣.២ (vii) ផងដែរ<br><br>ការអភិវឌ្ឍដំណាំសាកវប្បកម្មនិងដំណាំស្មៀងផ្សេងៗ - ១៥.៣លានដុល្លារអាម៉េរិក) និងការអភិវឌ្ឍដំណាំឧស្សាហកម្ម - ១២.៥លានដុល្លារអាម៉េរិក (viii)។ | • បច្ចេកវិទ្យាកាត់បន្ថយការបាត់បង់ក្រោយការប្រមូលផល និងកាត់បន្ថយសំណល់អាហារ<br>• សហគមន៍អ្នកអនុវត្ត (ក្នុងចំណោម IHL អង្គការសង្គមស៊ីវិល ស្ថាប័នពាក់ព័ន្ធនិងវិស័យឯកជន) ស្តីពីកសិកម្មឆ្លាតវៃចំពោះអាកាសធាតុ និងដែលបង្កើនគុណភាពដី។ | |

| គោលដៅយុទ្ធសាស្ត្រ២ : ពង្រឹងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ : បញ្ជ្រាបសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម(GEDSI) ទៅក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធ ដូចជា NDCs, ដំណើរការ NAP និងការប្រាស្រ័យទាក់ទងនិងហិរញ្ញប្បទាន ផែនការសកម្មភាពយុទ្ធសាស្ត្រជាតិកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ | | | | | |
|---|---|---|---|---|---|
| លទ្ធផលយុទ្ធសាស្ត្រ | គោលដៅ | ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI | ថវិកាប៉ាន់ស្មាន | សកម្មភាព | ស្ថាប័នសំខាន់ៗជាអ្នកអនុវត្ត |
| ២.៦- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធនិងការសាងភាពធន់ និងចីរភាពបរិស្ថាន (រួមទាំង ពង្រីកការអនុវត្តស្តង់ដាអគារបៃតង ការរចនាប្រព័ន្ធត្រជាក់ លេខកូដអគារ ហេដ្ឋារចនាសម្ព័ន្ធបៃតង និងប្រផេះ។ល។) | • គោលការណ៍ណែនាំអំពីអគារបៃតង កូដអគារ រួមជាមួយលក្ខណវិនិច្ឆ័យភាពធន់<br>• ពង្រីកការអនុវត្តកូដអគារបៃតងនិងបទប្បញ្ញត្តិពាក់ព័ន្ធ<br>• កំណើនចំនួនអគារជាមួយនឹងការរចនាប្រព័ន្ធរក្សាភាពត្រជាក់ និងការអនុលោមតាមកូដអគារបៃតង | • សិក្សាអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើស្ត្រីក្នុងលំនៅឋានមិនរឹងមាំ<br>• បញ្ចូលរបកគំហើញពីការសិក្សាទៅក្នុងកូដអគារបៃតងដែលពាក់ព័ន្ធ។ | កូដអគារនិងការអនុវត្តច្បាប់ - ២៥លានដុល្លារអាម៉េរិក ការអនុវត្តបទប្បញ្ញត្តិ និងគុណភាពខ្យល់នៅការដ្ឋានសំណង់ ០,៥លានដុល្លារអាម៉េរិក (i)<br><br>បន្សុីស្តង់ដារចនាផ្លូវជាមួយកម្រិតហានិភ័យអាកាសធាតុនៃទីតាំងជាក់លាក់ បង្កើនស្តង់ដាភាពធន់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនថ្មី និងបង្កើនការវិភាជន៍សម្រាប់ថែទាំផ្លូវ ០,៩៤ពាន់លានដុល្លារអាម៉េរិក[23] (ii) | i- ពង្រឹងការអនុវត្តបទប្បញ្ញត្តិស្តីពីស្តង់ដាអគារបៃតងដែលធន់ និងការអភិវឌ្ឍទីក្រុង (គោលការណ៍ណែនាំអគារបៃតងជាតិ និងកូដអគារផែនការសកម្មភាពសីតកម្មជាតិ។ល។ ដែលពិចារណាអំពីការប្រើប្រាស់ដីតាមវិធីចម្រុះ ជាមួយលំហបៃតង និងខៀវ។<br>ii- បញ្ជ្រាបលក្ខខណ្ឌតម្រូវអំពីភាពធន់នឹងអាកាសធាតុសម្រាប់គ្រប់ការសាងសង់និងថែទាំផ្លូវថ្មីទាំងអស់ និងកែលម្អផ្លូវដែលមានស្រាប់។<br>iii- បញ្ជ្រាបការអនុវត្តកូដអគារបៃតងនិងនិងអនុលោមភាព។<br>iv- នៅតាមទីក្រុងនានា ពិចារណាអំពីការប្រើប្រាស់ដីតាមវិធីចម្រុះ ជាមួយទីធ្លាបៃតងនិងខៀវ។<br><br>**តម្រូវការបច្ចេកវិទ្យានិងសមត្ថភាពមនុស្ស**<br><br>• កម្មវិធីកសាងសមត្ថភាពនៅកម្រិតរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិស្តីពីការអនុវត្តកូដអគារបៃតង<br>• កម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈជាបន្តបន្ទាប់ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធបៃតងនិងពណ៌ប្រផេះ(នៅ IHL)<br>• ស្រាវជ្រាវនិងអភិវឌ្ឍទៅជាធនធានសម្ភារៈសំណង់ដែលមានប្រសិទ្ធផលខ្ពស់ | • MoE<br>• MoH<br>• MLMUPC<br>• MoWA<br>• MPWT<br>• NCDM<br>• MISTI |

23 https://documents1.worldbank.org/curated/en/099092823045528995/pdf/P178871154c24a0917720149301a3431d83a4f0ced08.pdf ទំព័រ ១២ បន្សុីស្តង់ដារចនាផ្លូវ ទៅនឹងកម្រិតហានិភ័យអាកាសធាតុនៃទីតាំងជាក់លាក់ បង្កើនស្តង់ដាភាពធន់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនថ្មី និងបង្កើនវិភាជន៍ថវិកាសម្រាប់ការថែទាំផ្លូវប្រហែល ៩៤ លានដុល្លារអាម៉េរិកក្នុងមួយឆ្នាំ ដោយផ្តល់អាទិភាពដល់ការវិនិយោគសម្រាប់ផ្លូវជនបទសំខាន់ៗ ជាពិសេសក្នុងខេត្តបាត់ដំបង ព្រៃវែង និងកំពង់ចាម។

| | | | | | |
|---|---|---|---|---|---|
| | | | បញ្ចូលការអភិវឌ្ឍអគារបៃតង ៧,៩លានដុល្លារអាមេរិក (iii)។ | | |

## តារាងទី៣ : គោលដៅយុទ្ធសាស្ត្រ៣ : គោលដៅ សកម្មភាព និងធនធានសំខាន់ៗ សម្រាប់អភិបាលកិច្ចល្អ

| គោលដៅយុទ្ធសាស្ត្រ : លើកស្ទួយអភិបាលកិច្ចល្អនិងបរិវត្តកម្មឌីជីថល : ពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្ស អភិវឌ្ឍនិងអនុវត្តគោលនយោបាយនិងយន្តការហិរញ្ញប្បទាន ដោយផ្តោតលើកស្តុតាង បរិយាបន្ន និងបរិវត្តកម្មឌីជីថល | | | | | |
|---|---|---|---|---|---|
| លទ្ធផលយុទ្ធសាស្ត្រ | គោលដៅ | ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI | ថវិកាប៉ាន់ស្មាន | សកម្មភាព | ស្ថាប័នសំខាន់ៗជាអ្នកអនុវត្ត |
| ៣.១- ពង្រឹងយន្តការហិរញ្ញប្បទានអាកាសធាតុ។ | • ការអនុវត្តមូលនិធិហិរញ្ញប្បទានអាកាសធាតុកម្ពុជា (CCFF) សម្រាប់ការផ្តល់ហិរញ្ញវត្ថុ<br>• បញ្ចូលយុទ្ធសាស្ត្រ ផែនការ និងគោលនយោបាយអាកាសធាតុទៅក្នុងការអនុវត្តសារពើពន្ធ និង PFM<br>• ពង្រឹងឱកាសទីផ្សារកាបូនដើម្បីបង្កើតការវិនិយោគឯកជនយ៉ាងច្រើនលើសកម្មភាពអាកាសធាតុ | • បញ្ចូល GEDSI និងតម្រូវការហិរញ្ញប្បទានអាកាសធាតុនៃក្រុមជនងាយរងគ្រោះ (ការវាយតម្លៃការរចនា ការអនុវត្ត និង M&E)។ | ថវិកាបម្រុងបច្ចុប្បន្នសម្រាប់មូលនិធិហិរញ្ញប្បទានអាកាសធាតុកម្ពុជាគឺ១០០ | i- បង្កើតចំណាត់ថ្នាក់ហិរញ្ញវត្ថុបៃតង ដើម្បីបង្កើតកាសារវិនិយោគបៃតងដែលឆ្លើយតបនឹងយេនឌ័រទូទៅ និងសម្រាប់ប្រព័ន្ធហិរញ្ញវត្ថុបៃតង។<br>ii- គណៈកម្មាធិការជាតិ/ក្រុមការងារយេនឌ័រ និងអាកាសធាតុដែលឆ្លើយតបទៅនឹងយន្តការហិរញ្ញវត្ថុបៃតង លទ្ធកម្មសាធារណៈបៃតង ការគ្រប់គ្រងបទប្បញ្ញត្តិ និងស្តង់ដា។ | • MEF<br>• MoE<br>• ធនាគាររដ្ឋាភិបាល<br>• MAFF<br>• MPWT<br>• MME<br>• NSPC |

| | | | | | |
|---|---|---|---|---|---|
| | • ពង្រឹងភាពជាដៃគូសាធារណៈ-ឯកជនក្នុងការវិនិយោគកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងបន្សាំ<br>• បង្កើតផែនការហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយ (ក្រោមយុទ្ធសាស្ត្រហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយ)<br>• អនុវត្តការលើកទឹកចិត្តសម្រាប់ការវិនិយោគ និងការដំឡើងEE និងRE<br>• អនុវត្តការលើកទឹកចិត្តសម្រាប់បច្ចេកវិទ្យាឆ្លាតវៃខាងអាកាសធាតុ<br>• បញ្ចូលលក្ខណៈវិនិច្ឆ័យឆ្លើយតបខាងយេនឌ័រទៅក្នុងការផ្តល់ហិរញ្ញប្បទានអាកាសធាតុ | | លានដុល្លារអាម៉េរិក[24] (ដល់ ១៥០លានដុល្លារអាម៉េរិក)។ សកម្មភាព (i-xiii) ដើម្បីកៀរគរហិរញ្ញប្បទានហិរញ្ញប្បទានអាកាសធាតុ។ ផ្អែកលើការពិនិត្យការចំណាយសាធារណៈលើការងារអាកាសធាតុ ឆ្នាំ២០២២ ការផ្តល់មូលនិធិ NDC មាន ៤៨៣,៧លានដុល្លារអាម៉េរិក ជារៀងរាល់ឆ្នាំ។ | iii- កៀរគរហិរញ្ញប្បទាន ឧ. តាមរយៈ CCFF ជាមួយប្រភពមូលនិធិថ្លៃប្រឹក និងវិធីសាស្ត្រនានា ដូចជា មូលបត្របៃតង ការផ្តល់ហិរញ្ញប្បទានចម្រុះ[25]។<br>iv- គោលនយោបាយដើម្បីជួយសម្រួលដល់ការទទួលបានសេវាធានារ៉ាប់រងឥណទានសម្រាប់ការស្តារពីគ្រោះមហន្តរាយ និងភាពធន់ ដែលឆ្លើយតបនឹងយេនឌ័រ និងក្រុមដែលងាយរងគ្រោះ។<br>v- បញ្ចូលការផ្តល់ហិរញ្ញប្បទានអាកាសធាតុនៅក្នុងថវិកានិងការចំណាយសាធារណៈ និងការត្រួតពិនិត្យនិងការវាយតម្លៃ។<br>vi- តាមដានការចំណាយនៅថ្នាក់ជាតិលើកិច្ចការអាកាសធាតុ ទាំងសាធារណៈ និងឯកជន<br>vii- បង្កើតយុទ្ធសាស្ត្រហិរញ្ញប្បទានអាកាសធាតុជាតិទូលំទូលាយមួយ<br>viii- កសាងសមត្ថភាពស្ថាប័នឱ្យក្លាយជាស្ថាប័នមានសម្បទាសម្រាប់មូលនិធិអាកាសធាតុបៃតង<br>ix. ធ្វើការសិក្សាលទ្ធភាពខាងឱកាសទីផ្សារកាបូន អនុវត្តវិធានការពង្រឹកប្រព័ន្ធទីផ្សារសម្រាប់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ រួមទាំងក្របខ័ណ្ឌច្បាប់និងស្ថាប័ន យោងតាមលក្ខខណ្ឌតម្រូវនៃមាត្រា៦(ស្តីពីទីផ្សារកាបូន) កិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ។<br>x- ស្វែងយល់ពីការកៀរគរហិរញ្ញវត្ថុអាកាសធាតុ តាមរយៈការជួញដូរកាបូន។<br>xi- អនុវត្ត ETF សម្រាប់របាយការណ៍អាកាសធាតុ(បន្សីជាមួយកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុ)។<br>xii- ធ្វើប្រតិបត្តិការហិរញ្ញវត្ថុអាកាសធាតុ កម្រងទិន្នន័យព័ត៌មានអំពីការផ្តល់មូលនិធិ និងហិរញ្ញប្បទានឥតសំណង(ឧ. នៅក្នុងកម្មវិធីតាមដាន NDC)។ | |

[24] គោលដៅអន្តរវិស័យនៃគម្រោងផ្តល់ហិរញ្ញប្បទានអាកាសធាតុកម្ពុជា(CCFF) រួមមានការបង្កើនល្បឿននៃការអនុវត្តសកម្មភាពផែនការជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (NDC) ពង្រឹកហិរញ្ញវត្ថុអាកាសធាតុ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទន្ទឹមនឹងជំរុញភាពធន់នឹងអាកាសធាតុ។ CCFF នឹងផ្តល់ហិរញ្ញប្បទានដល់គម្រោងអាកាសធាតុដែលមានឥទ្ធិពលខ្ពស់ ដោយផ្តោតលើវិស័យអាទិភាពរបស់ NDC ដែលជួបបញ្ហាខាងធនធាន តាមរយៈការផ្តល់កម្ចីសម្បទានរយៈពេលវែង និងការកៀរគរការចូលរួមពីវិស័យឯកជន។ https://www.greenclimate.fund/project/fp228

[25] CCFF គួរឈានឱ្យហួសពីការផ្តល់ហិរញ្ញប្បទាន GCF ជាមួយទម្រង់នៃការផ្តល់មូលនិធិផ្សេងទៀត ដូចជា ការផ្តល់ហិរញ្ញប្បទានចម្រុះពីប្រភពសាធារណៈ ឬសប្បុរសធម៌ ដើម្បីបង្កើនការវិនិយោគរបស់វិស័យឯកជនក្នុងការអភិវឌ្ឍដោយចីរភាព។ (https://www.convergence.finance/blended-finance)

| | | | | | |
|---|---|---|---|---|---|
| | • ពង្រីកផលិតផលហិរញ្ញវត្ថុបៃតង (មូលបត្របៃតង ហិរញ្ញប្បទានចម្រុះ)<br>• បង្កើតស្តង់ដា GPP និងនីតិវិធីប្រតិបត្តិការស្តង់ដា | | | xiii- បន្សុំគោលនយោបាយ យុទ្ធសាស្ត្រ និងបទប្បញ្ញត្តិបច្ចុប្បន្ន ដើម្បីសម្រេចបានគោលដៅកាត់បន្ថយ និងការបន្សាំនៅកម្រិតជាតិ។ | |
| | | | | **តម្រូវការបច្ចេកវិទ្យានិងសមត្ថភាពមនុស្ស** | |
| | | | | • កម្មវិធីកសាងសមត្ថភាពខាងហិរញ្ញវត្ថុបៃតងសម្រាប់អ្នកពាក់ព័ន្ធ រួមមានស្ថាប័នហិរញ្ញវត្ថុ និងនិយ័តករ (ការស្តារឡើងវិញពីគ្រោះមហន្តរាយ ការគ្រប់គ្រង និងការទប់ទល់)<br>• ផ្តល់អំណាចដល់ស្ថាប័នជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីអភិវឌ្ឍន៍និងធ្វើការប្រមូលទិន្នន័យហិរញ្ញប្បទានបៃតងដែលឆ្លើយតបនឹងយេនឌ័រ និងសកម្មភាពបន្តបន្ទាប់<br>• ពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេសនិងជាន់ខ្ពស់នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងវិស័យឯកជនលើផ្នែកទីផ្សារកាបូន GPP មូលបត្របំណុលបៃតង និងផលិតផលច្នៃប្រឌិតផ្សេងទៀត។ | |

| គោលដៅយុទ្ធសាស្ត្រ៣ : លើកស្ទួយអភិបាលកិច្ចល្អនិងបរិវត្តកម្មឌីជីថល : ពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្ស អភិវឌ្ឍនិងអនុវត្តគោលនយោបាយនិងយន្តការហិរញ្ញប្បទាន ដោយផ្តោតលើភស្តុតាង បរិយាបន្ន និងបរិវត្តកម្មឌីជីថល | | | | | |
|---|---|---|---|---|---|
| លទ្ធផលយុទ្ធសាស្ត្រ | គោលដៅ | ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI | ថវិកាប៉ាន់ស្មាន | សកម្មភាព | ស្ថាប័នសំខាន់ៗជាអ្នកអនុវត្ត |
| ៣.២- បង្កើនលទ្ធភាពប្រើប្រាស់និងការអប់រំព័ត៌មានដែលផ្តោតចំគោលដៅ ការប្រាស្រ័យទាក់ទង និងការបណ្តុះបណ្តាលអំពីការប្រែប្រួលអាកាសធាតុ | • ដំឡើងឯកកម្រិតនៃកម្មវិធីសិក្សានិងវិធីសាស្ត្របណ្តុះបណ្តាលរួមទាំងបណ្ណាល័យ ដើម្បីរួមបញ្ចូលមុខវិជ្ជាប្រែប្រួលអាកាសធាតុនៅក្នុងសាលាបឋមសិក្សា ការអប់រំក្រៅប្រព័ន្ធ ការសិក្សាពេញមួយជីវិត<br>• បានបង្កើតកម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់សមត្ថភាពមនុស្សក្នុងវិស័យសាធារណៈអំពីការប្រែប្រួលអាកាសធាតុ សកម្មភាពអាកាសធាតុ អន្តរាគមន៍ វិធានការបន្សាំ និងហិរញ្ញប្បទាន<br>• ពង្រឹងនិងបង្កើនគុណភាពនៃមធ្យោបាយផ្សព្វផ្សាយ និងពង្រីកសមត្ថភាពផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុទូទាំងប្រទេស។ | • រួមបញ្ចូល GEDSI និងតម្រូវការរបស់ក្រុមងាយរងគ្រោះ សម្រាប់ជាគោលដៅនៃការអប់រំ ទំនាក់ទំនង និងបណ្តុះបណ្តាលព័ត៌មានអំពីការប្រែប្រួលអាកាសធាតុ និងកម្មវិធី SBCC។ | ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សានិងកម្មវិធីបណ្តុះបណ្តាលមន្ត្រីអប់រំអំពីការប្រែប្រួលអាកាសធាតុ(២លានដុល្លារអាម៉េរិក) (i) កសាងសមត្ថភាពបន្សាំនិងភាពធន់ដល់មន្ត្រីMRD និងមេភូមិ – ២០លានដុល្លារអាម៉េរិក (ii) ការបណ្តុះបណ្តាលនិងលើកកម្ពស់សមត្ថភាពមនុស្សអំពីការប្រែប្រួលអាកាសធាតុក្នុងវិស័យព័ត៌មាន – ០,៧៥លានដុល្លារអាម៉េរិក (ii)<br><br>ពង្រឹងគុណភាពនៃមធ្យោបាយផ្សព្វផ្សាយ និងសមត្ថភាពគ្របដណ្តប់– ៥លានដុល្លារអាម៉េរិក (iii, iv) យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ ២០លានដុល្លារអាម៉េរិក (iii, iv)<br><br>ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារអភិវឌ្ឍន៍ក្នុងប្រទេសនិងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល – ១លានដុល្លារអាម៉េរិក (v) | i- ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាលើមុខវិជ្ជាប្រែប្រួលអាកាសធាតុសម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សា IHL និងការអប់រំក្រៅប្រព័ន្ធ ការសិក្សាពេញមួយជីវិត។<br>ii- ពង្រីកការបណ្តុះបណ្តាលដល់ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល អ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយ និងសហគមន៍ អំពីគោលនយោបាយពាក់ព័ន្ធនឹងសកម្មភាព។ អាកាសធាតុ ដូចជា LTS4CN យុទ្ធសាស្ត្រចក្រាវិស័យបរិស្ថាន NDC RE, EE ជាដើម។<br>iii- យុទ្ធនាការផ្សព្វផ្សាយនិងបង្ហាញអំពីបច្ចេកវិទ្យាបញ្ចេញកាបូនទាបនិងប្រសិទ្ធភាពតម្លៃ។<br>iv- បង្កើតនិងអនុវត្តយុទ្ធនាការអប់រំទូទាំងប្រទេសអំពីសកម្មភាពបរិស្ថាននិងអាកាសធាតុ។<br>v- កម្មវិធីអភិវឌ្ឍន៍សមត្ថភាពអំពីការរចនា និងការអនុវត្តការប្រាស្រ័យទាក់ទង ដែលកែប្រែឥរិយាបថសង្គមជាក់លាក់របស់អ្នកពាក់ព័ន្ធ (SBCC) អំពីសកម្មភាពអាកាសធាតុ។ | • MoEYS<br>• MAFF<br>• MoINFO (បណ្តាញព័ត៌មានរដ្ឋាភិបាលនិងឯកជន)<br>• MoE |

| | | | | | |
|---|---|---|---|---|---|
| | | | | vi- ពង្រីកការចូលរួមពីភាគីពាក់ព័ន្ធច្រើនក្នុងការរចនា និងការអនុវត្តកម្មវិធី SBCC ។ | |
| ៣.៣- ពង្រឹងកម្លាំងពលកម្មបច្ចុប្បន្ន និងអនាគតដើម្បីឈានឆ្ពោះទៅអន្តរកាលកាបូនតិច និងធន់។ | ● ពង្រីកការស្រាវជ្រាវនិងសមត្ថភាពអភិវឌ្ឍន៍នៃវិទ្យាស្ថានឧត្តមសិក្សា (IHL) ដើម្បីគាំទ្រសកម្មភាពអាកាសធាតុ ការអភិវឌ្ឍគោលនយោបាយ GEDSI ការសម្រេចចិត្តផ្អែកលើភស្តុតាង<br>● បានពិនិត្យកម្មវិធីសិក្សានៅ IHLs និងវិទ្យាស្ថានវិជ្ជាជីវៈ និងបានអនុវត្តវិធានការឆ្លើយតបនឹងអាកាសធាតុនិងយេនឌ័រសម្រាប់កម្លាំងពលកម្មដែលត្រៀមរួចជាស្រេចនាពេលអនាគត។ | • រួមបញ្ចូល GEDSI និងតម្រូវការរបស់ក្រុមដែលងាយរងគ្រោះអន្តរកាលទៅរកកាបូនតិច និងធន់ នាពេលអនាគត។ | • សូមអាន៣.២ ផងដែរ (i)សម្រាប់ការសិក្សាពេញមួយជីវិត<br>• ធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សានិងវិធីសាស្ត្របណ្តុះបណ្តាល - ២លានដុល្លារអាម៉េរិក (ii)<br>• បង្កើតមជ្ឈមណ្ឌលឧត្តមភាពសម្រាប់ការផ្តល់វគ្គបណ្តុះបណ្តាល និងការស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ ៣,៥លានដុល្លារអាម៉េរិក (ស្រាវជ្រាវនិងអភិវឌ្ឍន៍/មណ្ឌលស្រាវជ្រាវ) (ii,iii)។ | i- លើកទឹកចិត្តដល់វិស័យឯកជន/និយោជកដើម្បីឱ្យវិនិយោគលើកម្លាំងពលកម្មដែលមានជំនាញក្នុងវិស័យបៃតង ជាពិសេសការលើកកម្ពស់ជំនាញស្ត្រី។<br>ii- ពិនិត្យនិងកែសម្រួលកម្មវិធីសិក្សាផ្លូវការសម្រាប់កម្លាំងពលកម្មបៃតង/កាបូនទាប (STEM អគារត្រជាក់ ថាមពលស្អាត បច្ចេកវិទ្យាឆ្លាតវៃអាកាសធាតុ)។<br>iii- បង្កើនកិច្ចប្រឹងប្រែង R&D ក្នុងការច្នៃប្រឌិតបច្ចេកវិទ្យាបៃតង ដើម្បីជំរុញប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាស្អាតថ្នាក់ជាតិ និងបង្កើនល្បឿននៃការទទួលយកបច្ចេកវិទ្យាពណ៌បៃតងដែលឆ្លើយតបនឹងយេនឌ័រ (រួមទាំងបច្ចេកវិទ្យាត្រជាក់ សេវាកម្ម និងការថែទាំឧបករណ៍បច្ចេកវិទ្យាបៃតង ឧបករណ៍ និងកម្មវិធី)។ | ● MoEYS<br>● MoE<br>● MAFF<br>● MoWA<br>● MLVT |

| គោលដៅយុទ្ធសាស្ត្រ៣ : លើកស្ទួយអភិបាលកិច្ចល្អនិងបរិវត្តកម្មឌីជីថល : ពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្ស អភិវឌ្ឍនិងអនុវត្តគោលនយោបាយនិងយន្តការហិរញ្ញប្បទាន ដោយផ្តែកលើកស្តុតាង បរិយាបន្ន និងបរិវត្តកម្មឌីជីថល | | | | | |
|---|---|---|---|---|---|
| លទ្ធផលយុទ្ធសាស្ត្រ | គោលដៅ | ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI | ថវិកាប៉ាន់ស្មាន | សកម្មភាព | ស្ថាប័នសំខាន់ៗ ជាអ្នកអនុវត្ត |
| ៣.៤- ពង្រឹងការចូលរួមពីភាគីពាក់ព័ន្ធនានា និងការចូលរួមក្នុងការអនុវត្តយុទ្ធសាស្ត្រ។ | • ពង្រីកភាពជាដៃគូពហុភាគី ការចូលរួម និងការគាំទ្រដល់វិធានការកាត់បន្ថយនិងបន្សុាំទៅនឹងអាកាសធាតុ<br>• ពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃរបស់ក្រសួង ដើម្បីតាមដានលទ្ធផលយេនឌ័រក្នុងកិច្ចផ្តួចផ្តើមអំពីការប្រែប្រួលអាកាសធាតុ (ឧ. ការប្រមូល និងគ្រប់គ្រងទិន្នន័យដែលញែកតាមភេទ សូចនាករយេនឌ័រ និងការរាយការណ៍ផ្តែកលើលទ្ធផល និងការផ្សព្វផ្សាយ)។ | •ការកសាងសមត្ថភាពលើការបញ្ជ្រាប GEDSI ទៅក្នុងការអនុវត្ត CCCSP ឆ្នាំ២០២៤-២០៣៣<br>• ការរចនានិងការអនុវត្ត M&Eដែលឆ្លើយតបយេនឌ័រ<br>• ការប្រមូលទិន្នន័យឆ្លើយតបយេនឌ័រ។ | ធ្វើបច្ចុប្បន្នភាពនិងអនុវត្តផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា (CCCSP) លានដុល្លារអាមេរិក (១) បញ្ចូលវិធានការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយជាតិ យុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ និងផែនការតាមវិស័យ និងបង្កើនសមត្ថភាពស្ថាប័នលើការប្រែប្រួលអាកាសធាតុ (ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សុាំ គោលនយោបាយយុទ្ធសាស្ត្រ ផែនការ និងហិរញ្ញវត្ថុ) – ៧លានដុល្លារអាមេរិក (ii, iii និង iv)។ | i- បង្កើនការចូលរួមក្រុមការងារបច្ចេកទេសបរិស្ថាននិងការប្រែប្រួលអាកាសធាតុជាមួយស្ថាប័នហិរញ្ញវត្ថុ IHL NSPC ស្ថាប័នស្រាវជ្រាវ អ្នកជំនាញផ្នែកទំនាក់ទំនង/ប្រព័ន្ធផ្សព្វផ្សាយ។<br>ii- ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រតាមវិស័យនិងបង្កើតព្រមទាំងអនុវត្តផែនការអនុវត្ត/ផែនការសកម្មភាព CCCSP ឆ្នាំ២០២៤-២០៣៣។<br>iii- បន្សុី M&Eរបស់ក្រសួងពាក់ព័ន្ធ ជាមួយCCCSP ឆ្នាំ២០២៤-២០៣៣/ NDC/ LTS4CN MRV។<br>iv-រួមបញ្ចូល CCCSP ឆ្នាំ២០២៤-៣៣ ទៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ក្រសួង ស្ថាប័នរៀងៗខ្លួន។<br>v- ពង្រឹងយន្តការសម្របសម្រួលរវាងស្ថាប័នសំខាន់ៗ ដែលនាំមុខដោយ MOE (DRR និងស្ថាប័ន EWS ដូចជា MoWRAM, NCDM, MEF និង MoE) ទាក់ទងនឹងការគ្រប់គ្រងហិរញ្ញប្បទានអាកាសធាតុ ដើម្បីកែលម្អការយល់ដឹងអំពីមូលនិធិនានា។ | • MoE<br>• MoINFO |

| | | | | | |
|---|---|---|---|---|---|
| ៣.៥- ពង្រឹងលទ្ធភាពទទួលបានជំនួយបច្ចេកទេសសម្រាប់ការកសាងសមត្ថភាពពហុភាគី។ | • ពង្រឹងសមត្ថភាពស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអំពី GEDSI ការចូលរួមនៃពហុភាគីពាក់ព័ន្ធ គោលនយោបាយបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ផែនការ ការបង្កើតកម្មវិធី និងថវិកា។ | | ពង្រឹងភាពធន់ និងសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងខេត្ត/ស្រុក/ឃុំភាគច្រើនដែលងាយរងគ្រោះ-១០លានដុល្លារអាម៉េរិក<br>ផ្តល់ការកសាងសមត្ថភាព និងការគាំទ្រសម្រាប់ការច្នៃប្រឌិតលើផ្នែកប្រែប្រួលអាកាសធាតុនៅខេត្តតាមដងទន្លេសាប–២,៥លានដុល្លារអាម៉េរិក។ | i- ពិនិត្យនិងអនុវត្តការងារកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការវាយតម្លៃតម្រូវការបច្ចេកវិទ្យា និងសមត្ថភាពបន្សាំតាម និងលើអនុសាសន៍។ | • ស្ថាប័នពាក់ព័ន្ធទាំងអស់ |

| គោលដៅយុទ្ធសាស្ត្រ៣ : លើកស្ទួយអភិបាលកិច្ចល្អនិងបរិវត្តកម្មឌីជីថល : ពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្ស អភិវឌ្ឍនិងអនុវត្តគោលនយោបាយនិងយន្តការហិរញ្ញប្បទាន ដោយផ្តេកលើកស្ទួតាង បរិយាបន្ន និងបរិវត្តកម្មឌីជីថល | | | | | |
|---|---|---|---|---|---|
| **លទ្ធផលយុទ្ធសាស្ត្រ** | **គោលដៅ** | **ផលប៉ះពាល់លើក្រុមជនងាយរងគ្រោះ និង GEDSI** | **ថវិកាប៉ាន់ស្មាន** | **សកម្មភាព** | **ស្ថាប័នសំខាន់ៗ ជាអ្នកអនុវត្ត** |
| ៣.៦- ដោះស្រាយគម្លាតទិន្នន័យ និងព័ត៌មានសម្រាប់ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃប្រកបដោយប្រសិទ្ធភាព។ | ពង្រឹងនិងពង្រីកការវាយតម្លៃភាពងាយរងគ្រោះ ទិន្នន័យការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឧស្ម័ន សមិទ្ធកម្មវិស័យសេដ្ឋកិច្ច ទិន្នន័យអន្តរាគមន៍ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ការប្រមូល និងការវិភាគទិន្នន័យដែលឆ្លើយតបនឹង GEDSI | | សូមអាន៣.៥ខាងលើ (i)<br>ប្រព័ន្ធជាតិសម្រាប់ការព្រមានមុនពីដើមដល់ចុងថ្នាក់ជាតិ ១៥លានដុល្លារអាម៉េរិកនិងបង្កើតបណ្តាញត្រួតពិនិត្យស្វ័យប្រវត្តទិន្នន័យជលសាស្ត្រ-អាកាសធាតុ ទូទាំង | i- ពិនិត្យនិងដំឡើងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីបំពេញគម្លាតទិន្នន័យក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ<br>ii- ស្វែងរកលទ្ធភាពក្នុងការបង្កើតមជ្ឈមណ្ឌលទិន្នន័យកណ្តាលស្តីពីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ (ផ្តេកលើកម្រងទិន្នន័យដែលមានស្រាប់ដែលរក្សាដោយ CCCA/NCSD, ធនាគារពិភពលោក។ល។ ដោយបន្សុីជាមួយ ETF និងគាំទ្រឱ្យមានអនុលោមភាពជាមួយយន្តការផ្តល់មូលនិធិសម្រាប់ការបាត់បង់ និងការខូចខាត | • MoE<br>• MOP / NIS<br>• ក្រសួងមហាផ្ទៃ (សម្រាប់ការសម្របសម្រួលក្នុងការប្រមូលទិន្នន័យ និងដំណើរការគ្រប់គ្រង)<br>• NCDM<br>• MOWRAM<br>• MEF |

| | | | | | |
|---|---|---|---|---|---|
| | បង្កើតទិន្នន័យផ្អែកលើភស្តុតាងដែលស្វែងយល់ពីទំនាក់ទំនងនៃការប្រែប្រួលអាកាសធាតុដែលគេមិនសូវស្គាល់ (ចំណាកស្រុក សុខភាព ផលិតភាព ការខាតបង់សេដ្ឋកិច្ច) ដើម្បីគាំទ្រដល់ការសម្រេចចិត្ត ការរៀបចំគម្រោង និងការអនុវត្ត បញ្ជីទិន្នន័យ និងព័ត៌មានអាកាសធាតុជាមួយនឹងគោលការណ៍ណែនាំ និងឧបករណ៍ ETF។ | | ប្រទេស និងកម្មវិធីបញ្ចូនទិន្នន័យ – ៤៨លានដុល្លារអាម៉េរិក (ii)<br>សម្រាប់ iii សូមអាន៣.២ (v)។ | iii- ស្វែងរកកិច្ចសហប្រតិបត្តិការជាមួយរាជបណ្ឌិត្យសភា ស្ថាប័នស្រាវជ្រាវ និងដៃគូអភិវឌ្ឍ ដើម្បីកំណត់អត្តសញ្ញាណទំនាក់ទំនងនៃការប្រែប្រួលអាកាសធាតុដែលគេមិនសូវស្គាល់ (ចំណាកស្រុក ហានិភ័យកុមារ សុខភាព ផលិតភាព ការបាត់បង់សេដ្ឋកិច្ច) ដែលត្រូវគាំទ្រ ដើម្បីបង្កើតទិន្នន័យផ្អែកលើភស្តុតាង។<br>**តម្រូវការបច្ចេកវិទ្យានិងសមត្ថភាពមនុស្ស**<br>• សមត្ថភាពបច្ចេកទេសអំពី ETF និងយន្តការផ្តល់មូលនិធិការបាត់បង់និងការខូចខាតនៅកម្រិតផ្សេងគ្នានៃអាជ្ញាធរនិងស្ថាប័នពាក់ព័ន្ធ<br>• ការបន្សីកម្មវិធីតាមដាន NDC បន្ថែមទៀតជាមួយ ETF - ពង្រឹងជំនាញគ្រូតពិនិត្យបច្ចេកទេសនិងរបាយការណ៍សារពើភណ្ឌ ការវាយតម្លៃហិរញ្ញវត្ថុ ការផ្ទេរបច្ចេកវិទ្យានិងការពង្រឹងសមត្ថភាពដែលត្រូវការ និងទទួលបាន។ | • វិទ្យាស្ថានឧត្តមសិក្សា (IHL)<br>• អង្គការស្រាវជ្រាវ |
| ៣៧-ពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូក្នុងតំបន់ និងអន្តរជាតិ (រួមទាំង អាស៊ាន គណៈកម្មការទន្លេមេគង្គ កិច្ចផ្តួចផ្តើមសហប្រតិបត្តិការមេគង្គ ទីភ្នាក់ងារនៃអង្គការសហប្រជាជាតិ មូលនិធិហិរញ្ញវត្ថុអាកាសធាតុ ធនាគារអភិវឌ្ឍន៍ និងទីភ្នាក់ងារ | ពង្រីកការចូលរួមនិងការរួមចំណែករបស់កម្ពុជាក្នុងកិច្ចប្រឹងប្រែងបន្តរបស់ UNFCCC និងស្ថាប័នផ្សេងទៀតនៃអង្គការសហប្រជាជាតិ<br><br>ពង្រីកការចូលរួមយ៉ាងសកម្ម និងការរួមចំណែករបស់កម្ពុជានៅក្នុងកិច្ចផ្តួចផ្តើមក្នុងតំបន់ ដូចជាអាស៊ាន ភាពជាដៃគូមេគង្គពហុភាគី។ | ការធ្វើជាតំណាង និងបញ្ចូល GEDSI និងផលប្រយោជន៍របស់ក្រុមងាយរងគ្រោះទៅក្នុងកិច្ចផ្តួចផ្តើមអន្តរជាតិ និងតំបន់។ | សម្រាប់ i សូមអាន ៣.២ (v)<br><br>១លានដុល្លារអាម៉េរិកសម្រាប់ក្រសួងនីមួយៗ (MoH) (ii) | i- ពង្រឹងកម្មវិធីសហប្រតិបត្តិការអន្តរជាតិនៃស្ថាប័នពាក់ព័ន្ធ ដើម្បីសម្រួលដល់ការផ្ទេរបច្ចេកវិទ្យា និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស<br>ii- ពង្រឹងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ និងជំនាញចរចាក្នុងវេទិកាអាកាសធាតុអន្តរជាតិ និងតំបន់ រួមបញ្ចូលផលប្រយោជន៍និងកង្វល់របស់ជាតិ<br>iii- អនុវត្តបរិយាកាសអំណោយផលក្នុងចំណោមគោលនយោបាយជាតិតាមវិស័យ និងក្របខ័ណ្ឌស្ថាប័នថ្នាក់ក្រោមជាតិ និងការប្តេជ្ញាចិត្តខាងអាកាសធាតុអន្តរជាតិ រួមមាន NDCs យុទ្ធសាស្ត្រអភិវឌ្ឍន៍ | ស្ថាប័នពាក់ព័ន្ធ និងគ្រឹះស្ថានសាធារណៈទាំងអស់ |

| | | | | | |
|---|---|---|---|---|---|
| អភិវឌ្ឍន៍)។ | | | | រយៈពេលវែងប្រកបដោយអព្យាក្រឹតកាបូន វិសោធនកម្ម Kigali ការសន្យាជាសាកលអំពីប្រព័ន្ធត្រជាក់។ | |
| ៣.៨- ការរៀបចំផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តបរិវត្តកម្មឌីជីថលសម្រាប់ការងារបរិស្ថាននិងការប្រែប្រួលអាកាសធាតុ | កំណត់តម្រូវការនិងអាទិភាពអំពីការអភិវឌ្ឍថ្នាលឌីជីថល ក៏ដូចជាធនធានមនុស្សសម្រាប់ប្រសិទ្ធភាពសកម្មភាពក្នុងគោលដៅយុទ្ធសាស្ត្រទាំង៣<br><br>ការកសាងភាពជាដៃគូជាមួយស្ថាប័នរដ្ឋ វិស័យឯកជន និងដៃគូអភិវឌ្ឍ ក្នុងការចែករំលែកទិន្នន័យនិងព័ត៌មានសម្រាប់ដំណើរការថ្នាលឌីជីថលនិងហេដ្ឋារចនាសម្ព័ន្ធឌីជីថល | | ២០០ ០០០ដុល្លារសម្រាប់រៀបចំផែនទីបង្ហាញផ្លូវ និង ថវិកាប្រហែល ១,៥លានដុល្លារសម្រាប់ការអនុវត្តសកម្មភាពអាទិភាពក្នុងរយៈពេល១០ឆ្នាំ | i) ការសិក្សាឯកសារដែលមានស្រាប់ និងការពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ។<br>ii) ការសិក្សាតម្រូវការបច្ចេកវិទ្យា និងការចំណាយនិងចំណេញលើការអភិវឌ្ឍថ្នាលឌីជីថលចាំបាច់ជាដំណាក់កាល។<br>iii) ការរៀបចំផែនទីបង្ហាញផ្លូវនិងវិភាគតម្រូវការថវិកានិងធនធានមនុស្ស។ | ស្ថាប័នពាក់ព័ន្ធ ដូចជាក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។ល។ |

## ៦.៤.១- ដំណាក់កាលទី១ : ក្នុងរយៈពេលបន្ទាន់ចំពោះមុខ(ឆ្នាំ២០២៤-២០២៨)

ដំណាក់កាលនៃការអនុវត្ត CCCSP ឆ្នាំ២០២៤-២០៣៣ គួរតែត្រូវបានបន្សុីជាមួយអាណត្តិរបស់ស្ថាប័នពាក់ព័ន្ធ។ ដំណាក់កាលដំបូងនៃការអនុវត្ត CCCSP ឆ្នាំ២០២៤-២០៣៣ មានគោលបំណងបង្កើនល្បឿននៃសកម្មភាព ទន្ទឹមនឹងដោះស្រាយគម្លាតទិន្នន័យ និងការពង្រឹងសមត្ថភាពមនុស្ស និងការគ្រប់គ្រងការវិនិយោគសាធារណៈដែលឆ្លើយតបទៅនឹងអាកាសធាតុ និងបង្កើតការយល់ដឹងកាន់តែទូលំទូលាយអំពីផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុលើសេដ្ឋកិច្ច សុខភាពមនុស្ស និងបរិស្ថាន។ ដើម្បីជួយសម្រួលដល់ការអនុវត្តដំណាក់កាលទី១ រាជរដ្ឋាភិបាលបានកំណត់នូវសកម្មភាពទូលំទូលាយដូចខាងក្រោម ស្របតាមគោលដៅយុទ្ធសាស្ត្រ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ អភិបាលកិច្ច ការកសាងសមត្ថភាព និងការកៀរគរហិរញ្ញប្បទានអាកាសធាតុ។

**តារាងទី៤ : ដំណាក់កាលទី១ : កម្មវិធីរយៈពេលបន្ទាន់(ឆ្នាំ២០២៤-២០២៨)**

| រយៈពេលបន្ទាន់ | ដំណាក់កាលទី១ ឆ្នាំ២០២៤-២០២៨ | |
|---|---|---|
| | i) | បង្កើនល្បឿននៃការអនុវត្តវិធានការអភិបាលកិច្ច ដែលអនុញ្ញាតឱ្យមានអនុលោមភាព និងការអនុវត្តបទប្បញ្ញត្តិ និងយុទ្ធសាស្ត្រពាក់ព័ន្ធ។ |
| | ii) | ពង្រឹងភាពធន់នឹងអាកាសធាតុក្នុងវិស័យកសិកម្ម **អគារ ទីក្រុង** និងហេដ្ឋារចនាសម្ព័ន្ធ និងការទទួលបានសេវាសំខាន់ៗ។ |
| | iii) | **ពង្រឹងការគ្រប់គ្រងលើការវិនិយោគសាធារណៈដែលឆ្លើយតបនឹងអាកាសធាតុ។** |
| | iv) | **ពង្រឹងការសម្របសម្រួលអន្តរស្ថាប័នឱ្យរលូន។** |
| | v) | ដោះស្រាយតម្រូវការបច្ចេកវិទ្យានិងធនធានមនុស្សសម្រាប់សកម្មភាពអាកាសធាតុ និងGEDSI។ |
| | vi) | បង្កើនល្បឿននៃការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។ |
| | vii) | ដោះស្រាយគម្លាតទិន្នន័យនិងការពង្រឹងយន្តការត្រួតពិនិត្យនិងវាយតម្លៃការឆ្លើយតបខាងយេនឌ័រ។ |
| | viii) | លើកកម្ពស់ការយល់ដឹងនៅគ្រប់វិស័យនិងគ្រប់កម្រិតនៃរដ្ឋបាលនិងសង្គម។ |
| **កម្មវិធី** | ១- | ការកាត់បន្ថយ : កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងលើកកម្ពស់ការអភិវឌ្ឍដែលបញ្ចេញកាបូនទាប។<br>• បង្កើនល្បឿននៃការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយ និងពង្រឹងការអនុវត្តបទប្បញ្ញត្តិដែលទាក់ទងនឹងការបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ ការលើកកម្ពស់ការដាំឈើឡើងវិញ និងការពង្រីកការអនុវត្តដំណោះស្រាយផ្អែកលើធម្មជាតិ ស្តង់ដាអនុវត្តថាមពលអប្បបរមា(MEPS)<br>• អនុវត្តនិងពង្រឹងបទប្បញ្ញត្តិជាតិបច្ចេកទេសអគារនិងវិញ្ញាបនបត្រអគារបៃតងសម្រាប់ប្រសិទ្ធភាពថាមពល និងការរចនាប្រព័ន្ធត្រជាក់ និងសម្ភារៈដែលមានប្រសិទ្ធភាពធនធាន<br>• អនុវត្តការញែកសំណល់តាមប្រភពនិងប្រតិបត្តិការទីលានចាក់សំរាមអនាម័យ/វិស្វកម្ម |

| | | |
|---|---|---|
| | | • អនុវត្តកម្មវិធីបៃតងក្នុងទីក្រុងនិងកម្មវិធីដំណោះស្រាយផ្អែកលើធម្មជាតិនៅក្នុងទីក្រុងដែលមានផែនការទីក្រុងកាន់តែប្រសើរនិងកន្លែងសាងសង់ប្រកបដោយផាសុកភាព<br>• ពង្រីកការរចនានិងលើកកម្ពស់ការប្រើប្រាស់សេវាកម្មដឹកជញ្ជូនទ្រង់ទ្រាយធំប្រកបដោយចីរភាព។ |

| រយៈពេលបន្ទាន់ | ដំណាក់កាលទី១ ២០២៤-២០២៨ | |
|---|---|---|
| កម្មវិធី | ២- | ការបន្សាំ : ការកសាងភាពធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។<br>• ការវាយតម្លៃភាពងាយរងគ្រោះដែលឆ្លើយតបនឹងGEDSI នៃវិស័យសេដ្ឋកិច្ចសំខាន់ៗ និងអ្នកពាក់ព័ន្ធ និងរួមបញ្ចូលកម្មករក្នុងវិស័យក្រៅ និងក្នុងប្រព័ន្ធ<br>• ពង្រីកប្រព័ន្ធផ្តល់ដំណឹងជាមុនសម្រាប់ព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ – ក្រុមគោលដៅ ពេលវេលា និងទីតាំងជាក់លាក់<br>• អនុម័តលក្ខណវិនិច្ឆ័យភាពធន់នឹងអាកាសធាតុសម្រាប់ហេដ្ឋារចនាសម្ព័ន្ធនិងអគារ<br>• ការទទួលយកកាន់តែទូលំទូលាយនូវបច្ចេកវិទ្យាកសិកម្មដែលធន់នឹងអាកាសធាតុនិងដែលឆ្លើយតបទៅនឹងយេនឌ័រ<br>• បង្កើនសមត្ថភាពបន្សាំរបស់សហគមន៍ដែលប្រឈមនឹងការប៉ះទង្គិចនៃអាកាសធាតុដោយបង្កើនល្បឿននៃដំណើរការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ សំខាន់ៗ និងយុទ្ធសាស្ត្រប្រព័ន្ធផ្តល់ដំណឹងជាមុន រួមមាន NAP-DRR ផែនទីបង្ហាញផ្លូវនៃការអនុវត្ត EW4ALL ក្របខ័ណ្ឌ SRSP និងយុទ្ធសាស្ត្រជាតិ DRF |
| | ៣- | អភិបាលកិច្ច : ការពង្រឹងសមត្ថភាពស្ថាប័ន ការអនុវត្តគោលនយោបាយ ការអនុវត្តបទប្បញ្ញត្តិ។<br>• បង្កើនល្បឿននៃការយល់ដឹងនិងកសាងសមត្ថភាពនៅគ្រប់កម្រិតនៃការគ្រប់គ្រង<br>• ពិនិត្យឡើងវិញនូវគោលនយោបាយនិងបទប្បញ្ញត្តិ ដើម្បីពង្រឹងការបន្សាំតាមយុទ្ធសាស្ត្រដែលពាក់ព័ន្ធ<br>• ពង្រីកការចូលរួមពីភាគីពាក់ព័ន្ធច្រើនផ្នែកដែលឆ្លើយតបទៅនឹងយេនឌ័រ ជំរុញភាពជាដៃគូកាន់តែច្រើន ផ្តល់វេទិកាទៀងទាត់សម្រាប់ការផ្លាស់ប្តូរការអនុវត្តល្អ និងការយល់ដឹងកាន់តែទូលំទូលាយអំពីគោលនយោបាយ និងបទប្បញ្ញត្តិរបស់រដ្ឋាភិបាល និងធ្វើការសម្រេចចិត្តទិញឧបករណ៍ប្រសិទ្ធភាពថាមពល និងផលិតផលបៃតង/ចីរភាព<br>• ពង្រឹងសមត្ថភាពស្ថាប័នសម្រាប់លទ្ធកម្មសាធារណៈបៃតងដែលមានប្រសិទ្ធភាព<br>• ពង្រឹងវិធានការសម្របសម្រួលអន្តរស្ថាប័នដោយរលូន<br>• ការរៀបចំផែនទីបង្ហាញផ្លូវអំពីវិវត្តកម្មឌីជីថល។ |

| រយៈពេលបន្ទាន់ | | ដំណាក់កាលទី១ ឆ្នាំ២០២៤-២០២៨ |
|---|---|---|
| កម្មវិធី | ៤- | ការកសាងសមត្ថភាព : ការវិនិយោគលើធនធានមនុស្ស បច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធធន់ និងការយល់ដឹងជាសាធារណៈ។<br>• លើកកម្ពស់ព័ត៌មាន ការអប់រំ ការយល់ដឹង និងការបណ្តុះបណ្តាលសម្រាប់មន្ត្រីរដ្ឋាភិបាល ស្ត្រី យុវជន (កម្លាំងពលកម្មនាពេលអនាគត) សហគមន៍មូលដ្ឋាន និងការកែលម្អលទ្ធភាពទទួលបានព័ត៌មានអំពីអាកាសធាតុ<br>• ពិនិត្យនិងកែលម្អកម្មវិធីសិក្សា និងការស្រាវជ្រាវ និងការអភិវឌ្ឍនៅ IHL ដើម្បីគាំទ្រតម្រូវការផ្នែកសេដ្ឋកិច្ចសម្រាប់កំណើនបៃតង និងសកម្មភាពអាកាសធាតុ<br>• ពង្រឹងការប្រមូលទិន្នន័យ (ការប្រមូលទិន្នន័យដែលឆ្លើយតបនឹងយេនឌ័រ) យន្តការត្រួតពិនិត្យ និងការវាយតម្លៃនៅទូទាំងស្ថាប័ន និងកម្រិតនៃការគ្រប់គ្រងដែលស្វែងរកការបន្សីជាមួយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ ក្របខ័ណ្ឌពង្រឹងតម្លាភាព (ETF) |
| | ៥- | ហិរញ្ញប្បទានអាកាសធាតុ និងការវិនិយោគ : ការកៀរគរធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តកាន់តែទូលំទូលាយនៃវិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ច។<br>• វិធានការនានាសម្រាប់ដំណើរការនៃប្រភពថវិកាយ៉ាងច្រើន ប្រកបដោយប្រសិទ្ធផល ប្រសិទ្ធភាព និងទាន់ពេលវេលា<br>• បង្កើយសមាហរណកម្មចំណាត់ថ្នាក់ហិរញ្ញប្បទានបៃតងដែលរួមបញ្ចូលយេនឌ័រ<br>• បង្កើតយុទ្ធសាស្ត្រហិរញ្ញប្បទានអាកាសធាតុជាតិទូលំទូលាយ រួមទាំងយន្តការផ្តល់មូលនិធិសម្រាប់ការបាត់បង់ និងការខូចខាត<br>• ពង្រីកការអនុវត្តអនុក្រឹត្យលេខ៤១របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) សម្រាប់ការគ្រប់គ្រងការវិនិយោគសាធារណៈដែលឆ្លើយតបនឹងអាកាសធាតុ[26]។ |

## ៦.៤.២- ដំណាក់កាលទី២ : ក្នុងរយៈពេលមធ្យម(ឆ្នាំ២០២៩-២០៣៣)

ដំណាក់កាលទីពីរនៃCCCSP ឆ្នាំ២០២៤-២០៣៣ សង្កត់ធ្ងន់លើសកម្មភាពរយៈពេលមធ្យមដើម្បីដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនិងពង្រឹងភាពធន់របស់ប្រទេស។ ដំណាក់កាលនេះមានកម្មវិធីសំខាន់ៗ ក្នុងគោលបំណងជំរុញកំណើនបៃតង កាត់បន្ថយកំណើនសេដ្ឋកិច្ចពីការរេចរឹលធនធានធម្មជាតិ GEDSI កាន់តែទូលំទូលាយ ការពង្រឹងសុខភាពសាធារណៈ និងកម្មវិធីធន់នឹងអាកាសធាតុនៅទូទាំងវិស័យសេដ្ឋកិច្ចសំខាន់ៗ។

[26] អនុក្រឹត្យលេខ៤១(ខែធ្នូ ឆ្នាំ២០២០) បង្កើតនីតិវិធីស្តង់ដាប្រតិបត្តិការ (SOP) សម្រាប់គម្រោងដែលទទួលមូលនិធិពីក្នុងស្រុក ហើយត្រូវបានគេរំពឹងថានឹង (i) បង្កើតលក្ខណៈវិនិច្ឆ័យស្តង់ដាសម្រាប់ការជ្រើសរើសគម្រោង (ii) អនុញ្ញាតឱ្យ MEF ត្រួតពិនិត្យដំណើរការគម្រោង និង (iii) ណែនាំនីតិវិធីសម្រាប់ត្រួតពិនិត្យប្រចាំឆ្នាំនៃគម្រោងវិនិយោគសាធារណៈដោយក្រសួងពាក់ព័ន្ធ។

*តារាងទី៥ : ដំណាក់កាលទី២ : កម្មវិធីសម្រាប់រយៈពេលមធ្យម(ឆ្នាំ២០២៩-២០៣៣)*

<table>
<tr><th>រយៈពេលមធ្យម</th><th colspan="2">ដំណាក់កាលទី២ ឆ្នាំ២០២៩-២០៣៣</th></tr>
<tr><td colspan="3">i ) ការកៀរគរហិរញ្ញប្បទានអាកាសធាតុ។<br>ii ) កាត់បន្ថយកំណើនសេដ្ឋកិច្ចពីការរេចរឹលធនធានធម្មជាតិ។<br>iii ) ការពង្រីកវិធានការកាត់បន្ថយការបញ្ចេញឧស្ម័ន។<br>iv ) ការពង្រីកវិធានការធន់ទៅនឹងអាកាសធាតុដែលឆ្លើយតបទៅនឹងយេនឌ័រនៅក្នុងហេដ្ឋារចនាសម្ព័ន្ធ សហគមន៍ ដែលងាយរងគ្រោះ។<br>v ) ការពង្រីកការអនុវត្តការគ្រប់គ្រងសំណល់ប្រកបដោយចីរភាព និងហេដ្ឋារចនាសម្ព័ន្ធ។<br>vi ) ការអនុវត្ត ETF សម្រាប់ NDC, M&E និងការរាយការណ៍អំពីយុទ្ធសាស្ត្រដែលពាក់ព័ន្ធដែលឆ្លើយតបនឹង យេនឌ័រផងដែរ។<br>vii ) ការពង្រឹងសុខភាពសាធារណៈ និងកម្មវិធីធន់នឹងអាកាសធាតុនៅទូទាំងវិស័យសេដ្ឋកិច្ចសំខាន់ៗ។</td></tr>
<tr><td>កម្មវិធី</td><td>១-</td><td>ការកាត់បន្ថយ : កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងលើកកម្ពស់ការអភិវឌ្ឍដែលបញ្ចេញកាបូនតិច។<br>• កៀរគរការវិនិយោគ ការលើកទឹកចិត្ត និងហិរញ្ញប្បទានដើម្បី EE និង RE សម្រាប់ការសាងសង់ សំណង់ និងការដឹកជញ្ជូន<br>• បញ្ឈប់ការកាប់ព្រៃឈើនិងបង្កើនជីវភាពពីកម្មវិធី REDD+ ឬគម្រោងស្ថិតក្រោមមាត្រា ៦នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ<br>• បង្កើនប្រាក់ចំណូលនិងលើកកម្ពស់ជីវភាព និងការងារសមរម្យសម្រាប់ស្ត្រីនិងសហគមន៍ងាយរងគ្រោះ<br>• ពង្រីកការបង្កើតឡើងវិញនិងការស្តារឡើងវិញនូវតំបន់ទេសភាពដែលខូចគុណភាព និងបង្កើនផលិតកម្ម<br>• ពង្រីកការដឹកជញ្ជូនសាធារណៈប្រកបដោយចីរភាពនិងការធ្វើដំណើរក្នុងទីក្រុង<br>• កាត់បន្ថយការបញ្ចេញឧស្ម័ននិងបង្កើនភាពធន់ក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ<br>• ការពង្រីកកន្លែងស្តារ និងកែច្នៃសម្ភារៈសំណល់និងកន្លែងចាក់សំរាមអនាម័យ ត្រួសត្រាយផ្លូវសម្រាប់រោងចក្រ RDF/WTE<br>• បង្កើនការផលិត/លទ្ធភាពទទួលបានជម្រើសជំនួស SUP</td></tr>
</table>

| | | |
|---|---|---|
| | ២- | ការបន្សាំ : ការកសាងភាពធន់នឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ<br>• ការដាក់ពង្រាយ GEDSI រួមបញ្ចូលគ្នានូវភាពធន់នឹងគ្រោះមហន្តរាយ និងការផ្តល់ហិរញ្ញប្បទានស្តារឡើងវិញដែលបង្កដោយគ្រោះមហន្តរាយ<br>• ប្រព័ន្ធប្រកាសដំណឹងជាមុនប្រកបដោយប្រសិទ្ធផលនិងប្រសិទ្ធភាពនៅកម្រិតរដ្ឋបាលផ្សេងៗគ្នា<br>• ភាពជាដៃគូពហុភាគីក្នុងការកសាងភាពធន់ទៅនឹងគ្រោះមហន្តរាយនិងការស្តារឡើងវិញ<br>• ការពង្រីកដំណោះស្រាយផ្អែកលើធម្មជាតិនិងការបន្សាំតាមប្រព័ន្ធអេកូឡូស៊ីនៃប្រព័ន្ធអេកូឡូស៊ីនិងសហគមន៍ដែលងាយរងគ្រោះអាកាសធាតុ( ទន្លេសាប សហគមន៍ឆ្នេរសមុទ្រ )<br>• ការពង្រីកវិធានការបន្សាំនឹងអាកាសធាតុដែលឆ្លើយតបទៅនឹងយេនឌ័រនិងវិធានការធន់ទ្រាំនៅក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ<br>• បង្កើនការអនុលោមតាមតម្រូវការធន់នឹងអាកាសធាតុក្នុងចំណោមគ្រឹះស្ថានសុខាភិបាលសាធារណៈ សាលារៀន និងមជ្ឈមណ្ឌលសហគមន៍<br>• ពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងសំណង់ដែលធន់នឹងអាកាសធាតុ រួមទាំងការពិចារណាអំពីភាពធន់នឹងកម្តៅ( ផ្លូវ អគារថ្មី និងដែលមានស្រាប់និងសម្ភារៈបរិក្ខារ ) |

| រយៈពេលមធ្យម | ដំណាក់កាលទី២ | ឆ្នាំ ២០២៩-២០៣៣ |
|---|---|---|
| **កម្មវិធី** | ៣- | អភិបាលកិច្ច : ការពង្រឹងសមត្ថភាពស្ថាប័ន អនុវត្តគោលនយោបាយ ពង្រឹងការអនុវត្តបទប្បញ្ញត្តិ។<br>• គោលនយោបាយនិងយុទ្ធសាស្ត្រត្រូវបានបន្សីគ្នាសម្រាប់ការអនុវត្ត CCCSP ឆ្នាំ២០២៤-២០៣៣ ដោយប្រសិទ្ធភាព<br>• ការរចនានិងការអនុវត្តគោលនយោបាយផ្អែកលើភស្តុតាង (គាំទ្រដោយ ETF និង MRV)<br>• ពង្រឹងការឃ្លាំមើល ការត្រួតពិនិត្យ និងការអនុវត្តច្បាប់សម្រាប់តំបន់ការពារធម្មជាតិ ការគ្រប់គ្រងការបំពុល ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ<br>• ប្រភពចម្រុះនៃហិរញ្ញប្បទានអាកាសធាតុ<br>• ភាគីពាក់ព័ន្ធច្រើន រួមបញ្ចូល GEDSI និងការចូលរួមក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំ និងការកសាងសមត្ថភាព<br>• ការថែទាំនិងការកែលម្អជាបន្តបន្ទាប់នូវទិន្នន័យកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងបន្សាំនឹងអាកាសធាតុ និង MRV។ |
| | ៤- | ការកសាងសមត្ថភាព : ការវិនិយោគលើធនធានមនុស្ស បច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធទន់ និងការយល់ដឹងជាសាធារណៈ។<br>• ពង្រីកជំនាញក្នុងមូលដ្ឋាន ជាមួយនឹងការបង្កើនឱកាសការងារបៃតង<br>• ពង្រីកកម្មវិធីសិក្សា IHL ដែលឆ្លើយតបនឹងអាកាសធាតុ និង R&D<br>• ព័ត៌មាន ការអប់រំ ការធ្វើទំនាក់ទំនង ការយល់ដឹង និងកម្មវិធីបណ្តុះបណ្តាលច្បាស់លាស់ជាក់លាក់សម្រាប់អ្នកពាក់ព័ន្ធ និងការប្រាស្រ័យទាក់ទងដើម្បីការផ្លាស់ប្តូរឥរិយាបថសង្គម (SBCC)<br>• បង្កើន R&D និងសហគមន៍នៃការអនុវត្តក្នុងចំណោម IHL លើការកាត់បន្ថយបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំនៅទូទាំងវិស័យសេដ្ឋកិច្ចសំខាន់ៗ និងក្រុមអ្នកពាក់ព័ន្ធ ដែលរួមទាំងស្ត្រី និងសហគមន៍ដែលងាយរងគ្រោះ។ |
| | ៥- | ហិរញ្ញប្បទានអាកាសធាតុនិងការវិនិយោគ : ការកៀរគរធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តកាន់តែទូលំទូលាយនូវវិធានការកាត់បន្ថយបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំ និងអភិបាលកិច្ច។<br>• ប្រភពហិរញ្ញប្បទានចម្រុះ រួមទាំងការវិនិយោគពីវិស័យឯកជនលើការកាត់បន្ថយបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំ និងការកសាងសមត្ថភាព<br>• បង្កើននិរន្តរភាពនៃការរៀបចំរបាយការណ៍ដោយវិស័យឯកជន។ |

## ៦.៥- ការរៀបចំស្ថាប័ន

នៅឆ្នាំ២០១៧ ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ(CCTWG) ត្រូវបានបង្កើតឡើងជាវេទិកាសម្រាប់កិច្ចសន្ទនាបច្ចេកទេសរវាងស្ថាប័នជាតិនិងជាវេទិកាមួយសម្រាប់ចូលរួមជាមួយដៃគូអភិវឌ្ឍ វិស័យអប់រំ វិស័យឯកជន និងសង្គមស៊ីវិល។ CCTWG មានសមាជិកចំនួន៣៨នាក់ មកពីក្រសួង/ស្ថាប័នចំនួន១៩ផ្សេងៗគ្នា និងអ្នកសង្កេតការណ៍មកពីដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងរាជបណ្ឌិត្យសភា។ កម្មវិធីអាណត្តិនិងអាទិភាពរបស់ CCTWG គឺផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងប្រឹក្សាដល់ NCSD ដើម្បីពង្រឹងសមត្ថភាពរបស់កម្ពុជាក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ក្រុមការងារបច្ចេកទេសប្រែប្រួលអាកាសធាតុ(CCTWG) ត្រូវបានប្រែសម្រួលឈ្មោះមកជាក្រុមការងារបច្ចេកទេសបរិស្ថាននិងការប្រែប្រួលអាកាសធាតុ(ECCTWG) ក្នុងឆ្នាំ២០២៤។

ក្រុមការងារបច្ចេកទេសបរិស្ថាននិងការប្រែប្រួលអាកាសធាតុ(ECCTWG) ដើរតួជាលេខាធិការដ្ឋានសម្រាប់សម្របសម្រួលក្នុងការបង្កើត និងការអនុវត្ត CCCSP ឆ្នាំ២០២៤-២០៣៣។ លេខាធិការដ្ឋាននេះក៏នឹងទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍វឌ្ឍនភាព CCCSP និង M&E ផងដែរ។ ក្រសួងពាក់ព័ន្ធ មូលនិធិហិរញ្ញប្បទានអាកាសធាតុ វិទ្យាស្ថានជាតិស្ថិតិ និងភាគីផ្សេងទៀតដែលចាប់អារម្មណ៍ក្នុងការចូលរួមយ៉ាងសកម្មក្នុងដំណើរការនេះមាននាទីពិនិត្យនិងឯកភាពលើសូចនាករ នីតិវិធី និងការទទួលខុសត្រូវលើការប្រមូលទិន្នន័យ។ ក្រុមអ្នកវិភាគស្ថាប័នស្រាវជ្រាវ និងវិទ្យាស្ថានឧត្តមសិក្សា(IHL) អាចត្រូវអញ្ជើញចូលរួម ដើម្បីផ្តល់ការគាំទ្រក្នុងការជំរុញសកម្មភាពនានា ការអនុវត្ត និងM&E នៃCCCSP ឆ្នាំ២០២៤-២០៣៣។ សហគមន៍ រួមទាំង តំណាងស្ត្រី និងក្រុមយុវជន កម្មករ និងសហជីព ក៏នឹងត្រូវអញ្ជើញចូលរួមក្នុងការពិគ្រោះយោបល់ផងដែរ។

ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព CCCSP បង្កើតរចនាសម្ព័ន្ធស្ថាប័ន តាមរយៈក្រុមការងារបច្ចេកទេសបរិស្ថាននិងការប្រែប្រួលអាកាសធាតុ។ ក្រសួងពាក់ព័ន្ធនិងអាជ្ញាធរមូលដ្ឋាន ទទួលខុសត្រូវលើការបញ្ចូលការពិចារណាអំពីការប្រែប្រួលអាកាសធាតុ ទៅក្នុងគោលនយោបាយ កម្មវិធី និងគម្រោងរៀងៗខ្លួន ជាមួយផែនការសកម្មភាព។ កិច្ចប្រឹងប្រែងនឹងធ្វើឡើងយ៉ាងសកម្ម ដើម្បីបង្កើនការពាក់ព័ន្ធនិងការចូលរួមនៃស្ថាប័នហិរញ្ញវត្ថុ ក្នុងគោលដៅពង្រីកនិងកៀរគរមូលនិធិសម្រាប់ការកាត់បន្ថយបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំ និងអភិបាលកិច្ច។

CCCSP ឆ្នាំ២០២៤-២០៣៣ សង្កត់ធ្ងន់ទៅលើការផ្សព្វផ្សាយ ទំនាក់ទំនង ការយល់ដឹងនិងបណ្តុះបណ្តាលដោយប្រសិទ្ធភាពនិងបរិយាបន្ន សម្រាប់ភាគីពាក់ព័ន្ធ ដើម្បីពង្រឹងសាមគ្គីភាពនិងសកម្មភាពក្នុងការកាត់បន្ថយបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំ និងការត្រួតពិនិត្យនិងការវាយតម្លៃ។

**ក្រុមការងារបច្ចេកទេសបរិស្ថាននិងការប្រែប្រួលអាកាសធាតុ (ECCTWG)**
- សម្របសម្រួលផ្ទៃក្នុង
- ត្រួតពិនិត្យវឌ្ឍនភាពនិងការរាយការណ៍ (បន្សីជាមួយប្រព័ន្ធតាមដាន NDC / LTS4CN)
- ផ្តួចផ្តើមការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ និងការវាយតម្លៃឥទ្ធិពលនៃ CCCSP ឆ្នាំ២០២៤-២០៣៣

**ស្ថាប័នដឹកនាំ (ក្រសួង/នាយកដ្ឋាន)**
- គាំទ្រសមាហរណកម្ម CCCSP ឆ្នាំ២០២៤-២០៣៣
- ការធ្វើផែនការ និងការអនុវត្តសម្រាប់វិស័យពាក់ព័ន្ធ រួមទាំងផែនការសកម្មភាពដែលពាក់ព័ន្ធ
- រៀបចំទិន្នន័យ និងរបាយការណ៍ពាក់ព័ន្ធ

- វិស័យឯកជន (ឧស្សាហកម្ម ស្ថាប័នហិរញ្ញវត្ថុ) វិនិយោគិន។ល។
- អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិល (NGOs/CSOs) និងសហជីព
- ដៃគូអភិវឌ្ឍ
- ម្ចាស់ជំនួយ
- វិទ្យាស្ថានឧត្តមសិក្សា (IHL)
- មូលនិធិហិរញ្ញវត្ថុអាកាសធាតុ

*រូបទី៤ : ការរៀបចំស្ថាប័ន*

(ពណ៌ទឹកក្រូចចាស់) ភាគីពាក់ព័ន្ធផ្ទៃក្នុង (រដ្ឋាភិបាល/វិស័យសាធារណៈ) – គោលនយោបាយគាំទ្រ បទប្បញ្ញត្តិ និងនីតិវិធី យុទ្ធសាស្ត្រហិរញ្ញប្បទាន (ភាពជាដៃគូឯកជន-សាធារណៈ ការលើកទឹកចិត្ត នីតិវិធីផ្តល់ហិរញ្ញប្បទាន) និង M&E។

(ពណ៌ទឹកក្រូចស្រាល) ភាគីពាក់ព័ន្ធខាងក្រៅ - ការគាំទ្រដល់ការអនុវត្ត ហិរញ្ញប្បទាន ជំនួយបច្ចេកទេស ការអនុវត្ត ការកសាងសមត្ថភាព ការស្រាវជ្រាវ និងការរៀបចំរបាយការណ៍ ការបញ្ជ្រាប GEDSI គាំទ្រដល់ការអប់រំ ការបណ្តុះបណ្តាល និងការយល់ដឹង ការអនុលោមតាមគោលនយោបាយ និងបទប្បញ្ញត្តិ។

ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០២៤-២០៣៣ អាចអនុវត្តដោយប្រសិទ្ធភាព តាមរយៈការរៀបចំស្ថាប័ន ដែលរួមមាន៖

១- ពង្រឹងយន្តការនិងវិធានការត្រួតពិនិត្យ និងសម្របសម្រួលគោលនយោបាយ កម្មវិធី និងគម្រោងនានានៅទូទាំងក្រសួងនិងវិស័យនានា។

២- ពង្រឹងសមត្ថភាពរបស់ស្ថាប័នដែលមានស្រាប់ ដូចជាក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកដ្ឋានធនធានទឹក ដើម្បីធ្វើសមាហរណកម្មការពិចារណាអំពីការប្រែប្រួលអាកាសធាតុទៅក្នុងផែនការប្រតិបត្តិការរបស់ពួកគេ។

៣- ពង្រឹងការផ្តល់ហិរញ្ញប្បទានអាកាសធាតុនិងធនធានផ្សេងទៀតសម្រាប់គម្រោងអាទិភាពនិងកិច្ចផ្តួចផ្តើម។

៤- ពង្រឹងភាពជាដៃគូជាមួយរដ្ឋាភិបាលមូលដ្ឋាន សង្គមស៊ីវិល វិស័យឯកជន និងអង្គការអន្តរជាតិ ដើម្បីសម្រួលដល់ការចែករំលែកចំណេះដឹង ការប្រមូលផ្តុំធនធាន និងការអនុវត្តរួមគ្នានៃសកម្មភាពអាកាសធាតុ។

៥- ត្រួតពិនិត្យវាយតម្លៃ និងរាយការណ៍ជាប្រចាំអំពីវឌ្ឍនភាពនៃផែនការយុទ្ធសាស្ត្រ ដើម្បីធានាគណនេយ្យភាព និងសម្របសម្រួលវិធីសាស្ត្រតាមការចាំបាច់។

## ៦.៦- តម្រូវការហិរញ្ញវត្ថុនិងបច្ចេកវិទ្យា

តម្រូវការហិរញ្ញវត្ថុនិងបច្ចេកវិទ្យា មានយោងនៅក្នុងយុទ្ធសាស្ត្រ គោលនយោបាយ ធនាគារអភិវឌ្ឍន៍ និងរបាយការណ៍របស់ទីភ្នាក់ងារអង្គការសហប្រជាជាតិសំខាន់ៗ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដូចជា NDC, LTS4CN, ប្រព័ន្ធតាមដានការអនុវត្ត NDC, យុទ្ធសាស្ត្របញ្ចកោណ, ការពិនិត្យការចំណាយសាធារណៈលើការងារអាកាសធាតុកម្ពុជា(ឆ្នាំ២០២២) និងរបាយការណ៍របស់ធនាគារពិភពលោក UNDP និង FAO។ ប្រភពទាំងនេះផ្តល់ការប៉ាន់ប្រមាណល្អបំផុត ក្នុងស្ថានភាពដែលខ្វះខាតទិន្នន័យដូចបច្ចុប្បន្ន។ យោងតាមរបាយការណ៍ត្រួតពិនិត្យការចំណាយសាធារណៈលើការងារអាកាសធាតុកម្ពុជា – CPER (ឆ្នាំ២០២២) ការចំណាយលើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់មាន៤% និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ៩៦% នៃចំណាយសរុបក្នុង CPER នាឆ្នាំ២០២២។ របាយការណ៍របស់ធនាគារពិភពលោកស្តីពីការវាយតម្លៃស្ថាប័នប្រែប្រួលអាកាសធាតុកម្ពុជា បានសង្កត់ធ្ងន់លើតម្រូវការផ្សេងទៀតផងដែរ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព(PFM) សម្រាប់សកម្មភាពអាកាសធាតុ បង្កើនការសម្របសម្រួលអន្តរស្ថាប័ន និងសមត្ថភាពបច្ចេកទេស និងការបង្កើនល្បឿននៃការអនុវត្តលទ្ធកម្មសាធារណៈបៃតង(GPP)។ រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើការជាមួយដៃគូរបស់ខ្លួន ដើម្បីស្វែងរក អនុវត្ត និងផ្តល់ផលិតផលហិរញ្ញវត្ថុច្នៃប្រឌិតទៅកាន់ទីផ្សារ ដែលជាមធ្យោបាយផ្តល់ហិរញ្ញប្បទានអាកាសធាតុ។ ក្នុងចំណោមផលិតផលដែលកំពុងរុករក គឺមូលបត្របៃតង។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានចូលរួមជាដៃគូដើម្បីពង្រឹងការកសាងសមត្ថភាពភាគីពាក់ព័ន្ធ កំណត់គម្រោងសមស្រប និងអ្នកចេញមូលបត្រ បង្កើតការលើកទឹកចិត្ត (ដូចជាការលើកទឹកចិត្តផ្នែកពន្ធសម្រាប់វិនិយោគិនក្នុងស្រុកនិងអ្នកចេញមូលបត្រ)និងជំនួយបច្ចេកទេស។[27] ប្រព័ន្ធ PFM ឆ្លើយតប និងធន់ អាស្រ័យលើសមត្ថភាពរបស់ RGC ដើម្បីឆ្លើយតបកាន់តែមានប្រសិទ្ធផលនិងប្រសិទ្ធភាព ចំពោះគ្រោះមហន្តរាយដែលបង្កឡើងដោយអាកាសធាតុនិងការរំខានទន្ទឹមនឹងកំណើនសុចរិតភាពនិងគណនេយ្យភាព។

យោងតាមផែនការ NDC តម្រូវការមូលនិធិសម្រាប់សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់គឺ ៥,៨ពាន់លានដុល្លារអាម៉េរិក និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុសរុបចំនួន២ពាន់លានដុល្លារអាម៉េរិក សម្រាប់ការអនុវត្តដែលមានរយៈពេល១០ឆ្នាំ(ឬសរុបជាមធ្យម៧៨០លានដុល្លារអាម៉េរិក ក្នុងមួយឆ្នាំៗ)។ ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍ និងស្ថិតក្នុងចំណោមប្រទេសដែលងាយរងគ្រោះបំផុតបណ្តាលពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ រាជរដ្ឋាភិបាលកម្ពុជាបានរំពឹងថាវិធានការបន្សាំ នឹងទាមទារនូវតម្រូវច្រើននៃហិរញ្ញប្បទានអាកាសធាតុ និងថវិកាជាតិ។[28]

---

[27] ទីផ្សារមូលបត្របំណុលបៃតងសម្រាប់កម្ពុជា។ https://www.adb.org/sites/default/files/publication/827631/green-bond-market-survey-cambodia.pdf

[28] គេរំពឹងថា ប្រទេសកំពុងអភិវឌ្ឍ នឹងទទួលរងការខូចខាតកាន់តែច្រើនឡើង ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប (GDP) របស់ខ្លួន បើប្រៀបធៀបទៅនឹងប្រទេសអភិវឌ្ឍន៍។ ការវិភាគត្រួសៗដោយ OECD អំពីជំពូក សកម្មភាពដែលផ្តល់មូលនិធិដោយ ODA បានស្នើថា ច្រើនជាង ៦០ ភាគរយនៃ ODA សរុប អាចពាក់ព័ន្ធទៅនឹងសមត្ថភាពបន្សាំនិងការបន្សាំ។ (https://www.iisd.org/system/files/publications/financing_mitigation_new_options.pdf)

ការអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់កម្ពុជាសម្រាប់អនាគត ការអភិវឌ្ឍដែលបញ្ចេញកាបូនតិច ត្រូវបានកំណត់ដោយការបង្កើនការយកចិត្តទុកដាក់លើការអប់រំផ្នែក STEM បង្កើនការចុះឈ្មោះស្ត្រីក្នុងការសិក្សា STEM និងវិស្វកម្ម។ ប្រការនេះក៏នឹងនាំឱ្យមានសង្កត់ធ្ងន់កាន់តែច្រើនឡើង លើការចូលរួមរបស់វិស័យឯកជន និងផ្តោតលើការផ្តល់ជំនាញដែលមានតម្រូវការក្នុងឧស្សាហកម្ម ដើម្បីគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការសម្រេចគោលដៅជាយុទ្ធសាស្ត្រ ដើម្បីកែប្រែខ្សែចង្វាក់តម្លៃ បង្កើនផលិតភាព និងគាំទ្រកំណើនឆ្ពោះទៅរកសេដ្ឋកិច្ចដែលបញ្ចេញកាបូនតិចផងដែរ។

## ៦.៦.១- ការកៀរគរធនធានហិរញ្ញវត្ថុ

ការផ្តល់មូលនិធិសម្រាប់សកម្មភាពអាកាសធាតុ ពាក់ព័ន្ធនឹងយន្តការជាច្រើនដែលអាចចែកចេញដូចខាងក្រោម៖

- យន្តការផ្តល់មូលនិធិអន្តរជាតិនិងពហុភាគីដែលផ្តល់ហិរញ្ញប្បទានឥតសំណង និងទម្រង់ហិរញ្ញប្បទានផ្សេងទៀត - ជាទូទៅមូលនិធិអាកាសធាតុបៃតង (GCF) និងមូលនិធិបន្សាំសកល។ ការរៀបចំមូលនិធិអន្តរជាតិថ្មីមួយទៀត ត្រូវបានឯកភាពនៅក្នុងកិច្ចប្រជុំ COP27 ក្នុងឆ្នាំ២០២២ ដើម្បីជួយដល់ប្រទេសដែលងាយរងគ្រោះបណ្តាលពីផលប៉ះពាល់អវិជ្ជមានដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ក្នុងកិច្ចប្រជុំ COP28 ឆ្នាំ២០២៣ ធនាគារពិភពលោកត្រូវបានអញ្ជើញឱ្យប្រតិបត្តិការមូលនិធិអន្តរការីហិរញ្ញវត្ថុ (FIF) សម្រាប់រយៈពេលបណ្តោះអាសន្ន៤ឆ្នាំ។ យន្តការផ្តល់មូលនិធិនេះហៅថា មូលនិធិការបាត់បង់ និងការខូចខាតដែលមានគោលបំណងផ្តល់ធនធានបន្ថែម រួមទាំងការផ្តល់ហិរញ្ញប្បទានពីខាងក្រៅ ដល់ប្រទេសកំពុងអភិវឌ្ឍដែលកំពុងប្រឈមនឹងភាពងាយរងគ្រោះខ្លាំងបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។
- ការផ្តល់ហិរញ្ញប្បទានទ្វេភាគី ដូចជាភាពជាដៃគូប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ/តិចតួចបំផុតក្នុងទម្រង់ជាហិរញ្ញប្បទានឥតសំណង កម្ចីនិងគម្រោងក្រោមមាត្រា៦ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ
- ការវិនិយោគក្នុងវិស័យឯកជន ដូចជាមូលនិធិវិស័យឯកជន (PSF) របស់GCF និងហិរញ្ញប្បទានចម្រុះរួមគ្នា
- យន្តការហិរញ្ញប្បទានប្រកបដោយភាពច្នៃប្រឌិត ដូចជាសញ្ញាបណ្ណបៃតង ការជួញដូរឥណទានកាបូន ហិរញ្ញប្បទានចម្រុះ។

*តារាងទី៦ : ប្រភពថវិកាដែលអាចមានសម្រាប់សកម្មភាពអាកាសធាតុ*

| ប្រភព[29] (មិនទាន់អស់ទេ) | គោលបំណង | អ្នកទទួលជាគោលដៅ | វិធីសាស្ត្រ |
|---|---|---|---|
| **ថវិការដ្ឋាភិបាល** | គាំទ្ររបៀបវារៈអាកាសធាតុ | វិស័យសាធារណៈ | ការរួមចំណែកចំពោះរបៀបវារៈជាតិ សញ្ញាបណ្ណបៃតង |
| **មូលនិធិបរិស្ថានសកល** | គាំទ្រគម្រោងសកម្មភាពអាកាសធាតុជាក់លាក់ | វិស័យសាធារណៈ | ប្រទេសដាក់ជូនសំណើ |

29 ការវិភាគប្រភពហិរញ្ញវត្ថុដែលមានសម្រាប់ប្រទេសអភិវឌ្ឍតិចតួចធ្វើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ខែវិច្ឆិកា ឆ្នាំ២០២៣ Mapping of adaptation finance.pdf (unfccc.int)

| | | | |
|---|---|---|---|
| មូលនិធិបន្សាំសកល | គាំទ្រគម្រោង និងកម្មវិធីបន្សាំជាក់ស្តែងនៅក្នុងប្រទេសកំពុងអភិវឌ្ឍ | វិស័យសាធារណៈតាមរយៈអង្គភាពអនុវត្តជាតិ (NIEs) | |
| មូលនិធិអាកាសធាតុបៃតង | គាំទ្រគម្រោងសកម្មភាពអាកាសធាតុជាក់ស្តែង - ឥណទានឥតសំណង កម្ចីសម្បទាន ភាគហ៊ុន/ទ្រព្យសកម្ម និងការធានា | វិស័យសាធារណៈ តាមរយៈអង្គភាពដែលបានការទទួលស្គាល់ (NIEs) | |
| ធនាគារអភិវឌ្ឍន៍ (ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី។ល។) | គម្រោងអភិវឌ្ឍន៍ហិរញ្ញវត្ថុ / ហេដ្ឋារចនាសម្ព័ន្ធ (វិធានការកាត់បន្ថយនិងបន្សាំអាកាសធាតុចម្រុះ) - កម្ចីនិងឥណទានឥតសំណង | វិស័យសាធារណៈ | |
| មូលនិធិសកលសម្រាប់ការកាត់បន្ថយ និងស្តារគ្រោះមហន្តរាយ | គាំទ្រដល់ប្រទេសដែលមានចំណូលទាប និងមធ្យម - កែលម្អការយល់ដឹងនិងកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រទេសទាំងនោះចំពោះមុខគ្រោះថ្នាក់ធម្មជាតិនិងការប្រែប្រួលអាកាសធាតុ - ឥណទានឥតសំណង កម្ចីសម្បទាន ការផ្តល់មូលនិធិផ្ទាល់ | វិស័យសាធារណៈ | |
| កិច្ចផ្តួចផ្តើមអាកាសធាតុអន្តរជាតិ (IKI) | គាំទ្រសកម្មភាពអាកាសធាតុ ការបន្សាំ និងការអភិរក្សជីវៈចម្រុះ – កម្ចីសម្បទាននិងជំនួយ | វិស័យសាធារណៈ និងតួអង្គមិនមែនរដ្ឋ | ប្រទេសឆ្លើយតបទៅនឹងការប្រកាសឱ្យដាក់សំណើ |
| ផ្សេងទៀត : អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ(ដូចជា OXFAM និង SNV) វិស័យឯកជន ធនាគារ មូលនិធិអភិវឌ្ឍន៍កសិកម្ម កម្មវិធីសហប្រតិបត្តិការទ្វេភាគី និងពហុភាគី (ដូចជា Aus4ASEANFutures, មូលនិធិសមាហរណកម្មជប៉ុន-អាស៊ាន - ឬ JAIF, កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងកិច្ចសហប្រតិបត្តិការមេគង្គ-កូរ៉េ) | ការគាំទ្រច្រើនតែផ្តល់សម្រាប់សកម្មភាពតាមវិស័យ – ឥណទានឥតសំណង | វិស័យសាធារណៈ និងតួអង្គមិនមែនរដ្ឋ | ប្រទេសឆ្លើយតបទៅនឹងការប្រកាសឱ្យដាក់សំណើ /ដាក់ស្នើសំណើដោយគ្មានការប្រកាសទទួល ឥណទានកាបូនមូលនិធិការបាត់បង់ និងការខូចខាត |

រាជរដ្ឋាភិបាលកម្ពុជានឹងធ្វើពិពិធកម្មប្រភពហិរញ្ញវត្ថុសម្រាប់ការអនុវត្ត CCCSP ឆ្នាំ២០២៤-២០៣៣ ដែលពាក់ព័ន្ធនឹងការពង្រឹងភាពជាដៃគូពហុភាគី និងការកសាងសមត្ថភាពមន្ត្រីវិស័យសាធារណៈក្នុងការរចនា និងអនុវត្តអន្តរាគមន៍ ប្រែប្រួលអាកាសធាតុជាទ្រង់ទ្រាយធំ។ អន្តរាគមន៍នេះនឹងរាប់បញ្ចូលវិធានការដើម្បីទ្រទ្រង់លទ្ធផល និងសកម្មភាពជាបន្តបន្ទាប់ ដែលជារឿយៗតម្រូវឱ្យមានការថែរក្សានិងធ្វើបច្ចុប្បន្នកម្មចំណេះដឹង និងព័ត៌មានរបស់ស្ថាប័ន។ ខាងក្រោមនេះគឺជាការពិចារណាសំខាន់ៗមួយចំនួនសម្រាប់ការកៀរគរធនធានហិរញ្ញវត្ថុ៖

១- ប្រភព។

២- គោលដៅ។

៣- វិធីសាស្ត្រ។

ការកៀរគរមូលនិធិអាចធ្វើទៅតាមវិស័យជាក់លាក់ ដូចជាកសិកម្ម ទេសចរណ៍ និងហេដ្ឋារចនាសម្ព័ន្ធ ឬក្រុមគោលដៅជាក់លាក់ ឧទាហរណ៍ កសិករខ្នាតតូចនិងសហគមន៍ក្នុងតំបន់ងាយរងគ្រោះ។ ទិដ្ឋភាពនៃមីក្រូហិរញ្ញវត្ថុនៅក្នុងរាជរដ្ឋាភិបាលបង្ហាញពីឱកាសក្នុងការកៀរគរហិរញ្ញប្បទានអាកាសធាតុខ្នាតតូច និងតម្លៃសមរម្យសម្រាប់សហគមន៍ជនបទ និងសហគ្រាសធុនមីក្រូ តូច និងមធ្យម ដែលតែងតែមានឧបសគ្គខាងផ្នែកហិរញ្ញវត្ថុក្នុងការបញ្ជ្រាបសកម្មភាពអាកាសធាតុ។

# ៧- ការតាមដាន ត្រួតពិនិត្យ និងការវាយតម្លៃ(M&E)

## ៧.១- ការវាយតម្លៃលទ្ធផលផែនការយុទ្ធសាស្ត្រ CCCSP ឆ្នាំ២០១៤-២០២៣

រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសដាក់ឱ្យប្រើប្រាស់នូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា(CCCSP) ឆ្នាំ២០១៤-២០២៣ នៅខែតុលា ឆ្នាំ២០១៣ ក្នុងគោលបំណងកំណត់នូវចក្ខុវិស័យ ដើម្បីឱ្យកម្ពុជាអភិវឌ្ឍឆ្ពោះទៅរកសង្គមមួយដែលបៃតង បញ្ចេញកាបូនទាប ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល។ ក្នុងរយៈពេលជាងមួយទសវត្សនៃការអនុវត្ត CCCSP កម្ពុជាសម្រេចបាននូវសមិទ្ធផលការងារជាច្រើនលើការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទាំងនៅកម្រិតអន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយក្នុងនោះក្រសួងស្ថាប័នជាតិចំនួន១៤បានរៀបចំនិងអនុវត្តនូវផែនការសកម្មភាពប្រែប្រួលអាកាសធាតុតាមវិស័យរបស់ខ្លួន(CCAPs) ហើយបានវិភាជថវិកាក្នុងការអនុវត្តសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាពខ្ពស់ និងបានសហការជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការសង្គមស៊ីវិល ក្នុងការអនុវត្តការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមរយៈការលើកកម្ពស់អភិបាលកិច្ច ការជំរុញសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ជាក់ស្តែង ការចំណាយជាសាធារណៈលើការងារប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជាមានការកើនឡើងជាលំដាប់ ដោយក្នុងឆ្នាំ២០១៥ មានប្រមាណជា១,២% ធៀបនឹងផលិតផលក្នុងស្រុកសរុប(GDP) ហើយអត្រានេះបានកើនឡើងរហូតដល់២,១% ក្នុងឆ្នាំ២០២៣។ បន្ថែមលើសពីនេះ ការងារប្រែប្រួលអាកាសធាតុបានដាក់បញ្ចូលទៅក្នុងយុទ្ធសាស្ត្រចតុកោណ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិតាមវិស័យផងដែរ។ សមិទ្ធផលសំខាន់ៗ ក្នុងការអនុវត្តការងារប្រែប្រួលអាកាសធាតុ ក្នុងCCCSP តាំងពីឆ្នាំ២០១៤ មានដូចខាងក្រោម៖

- **វិស័យថាមពល** : មានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការពង្រីកលទ្ធភាពទទួលបានអគ្គិសនី និងលើកកម្ពស់ថាមពលកកើតឡើងវិញនៅក្នុងល្បាយថាមពលជាតិ។ គិតត្រឹមឆ្នាំ២០២៣ ប្រជាជនកម្ពុជា៩២,៣% មានអគ្គិសនីប្រើប្រាស់ ខណៈឆ្នាំ២០១៤ មានត្រឹមតែ៧១% តែប៉ុណ្ណោះ។ ការរួមចំណែកនៃថាមពលកកើតឡើងវិញនៅក្នុងល្បាយថាមពលជាតិបានកើនឡើងពី៥១% ក្នុងឆ្នាំ២០១៤ ដល់៥៧,២៥% ក្នុងឆ្នាំ២០២៣ ពិសេសថាមពលទឹក(ស្ថានីយវារីអគ្គិសនី) ថាមពលសូឡា។
- **វិស័យកសិកម្ម** : បានអនុវត្តនូវគំនិតផ្តួចផ្តើមជាច្រើនដើម្បីលើកកម្ពស់កសិកម្មឆ្លាតវៃខាងអាកាសធាតុ រួមទាំងកម្មវិធីអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុនិងកម្មវិធីសេវាកម្មកសិកម្មផ្សេងទៀត។ គំនិតផ្តួចផ្តើមទាំងនេះបានបង្កើនភាពធន់ក្នុងវិស័យកសិកម្មចំពោះមុខនៃផលប៉ះពាល់ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។ ផលិតកម្មស្រូវបានកើនឡើងពី៩,២ លានតោនក្នុងឆ្នាំ២០១៤ ដល់១០,៥ លានតោនក្នុងឆ្នាំ២០១៩ ទោះបីជាមានបញ្ហាប្រឈមដោយសារការប្រែប្រួលអាកាសធាតុក៏ដោយ។
- **វិស័យឧស្សាហកម្ម** : បានអនុវត្តគោលនយោបាយនិងគំនិតផ្តួចផ្តើមមួយចំនួន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពថាមពល និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្នុងវិស័យឧស្សាហកម្ម រួមមានយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រសិទ្ធភាពថាមពលជាតិ និងគម្រោងប្រសិទ្ធភាពថាមពលឧស្សាហកម្មកម្ពុជា។ ការរួមចំណែកនៃការប្រើប្រាស់ថាមពលកកើតឡើងវិញក្នុងវិស័យឧស្សាហកម្មបានកើនឡើងពី១% ក្នុងឆ្នាំ២០១៤ ដល់២,៦% ក្នុងឆ្នាំ២០១៩។
- **វិស័យអប់រំ** : បានអនុវត្តគំនិតផ្តួចផ្តើមជាច្រើនដើម្បីលើកកម្ពស់ការយល់ដឹងនិងកសាងសមត្ថភាពស្តីពីការប្រែប្រួលអាកាសធាតុដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងសាធារណជនទូទៅ តាមរយៈការរៀបចំយុទ្ធសាស្ត្រសិក្សាជាតិអំពីការប្រែប្រួលអាកាសធាតុនិងកម្មវិធីអប់រំ ស្តីពីការប្រែប្រួលអាកាសធាតុ។ សិស្សានុសិស្សនិងគ្រូបង្រៀនប្រមាណ៣ ០០០នាក់ត្រូវបានបណ្តុះបណ្តាលពីការប្រែប្រួលអាកាសធាតុ ហើយការអប់រំអំពីការប្រែប្រួលអាកាសធាតុត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិគ្រប់កម្រិត។
- **វិស័យដឹកជញ្ជូន** : បានអនុវត្តគោលនយោបាយនិងគំនិតផ្តួចផ្តើមមួយចំនួនដើម្បីលើកកម្ពស់មធ្យោបាយដឹកជញ្ជូនប្រកបដោយចីរភាព រួមទាំងគោលនយោបាយជាតិដឹកជញ្ជូនប្រកបដោយចីរភាព និងផែនការសកម្មភាពជំរុញខ្យល់ស្អាត។ ជាលទ្ធផល ការចូលរួមចំណែកនៃការដឹកជញ្ជូនតាមមធ្យោបាយសាធារណៈក្នុងតំបន់ទីក្រុងបានកើនឡើងពី៣,៣% ក្នុងឆ្នាំ២០១៤ ដល់១០,៨% ក្នុងឆ្នាំ២០១៩។
- **វិស័យសំណល់** : បានអនុវត្តគំនិតផ្តួចផ្តើមជាច្រើនដើម្បីលើកកម្ពស់ការគ្រប់គ្រងកាកសំណល់ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីកាកសំណល់ រួមមានយុទ្ធសាស្ត្រ និងផែនការសកម្មភាពជាតិគ្រប់គ្រងសំណល់រឹង និងគម្រោងគ្រប់គ្រងសំណល់រឹង និងការប្រែប្រួលអាកាសធាតុ។ ជាលទ្ធផល ភាគរយនៃកាកសំណល់ដែលត្រូវបោះចោលក្នុងទីលានចាក់សំរាម បានថយចុះពី៨៧% ក្នុងឆ្នាំ២០១៤ មក៤២% ក្នុងឆ្នាំ២០១៩។
- **វិស័យព្រៃឈើនិងការប្រើប្រាស់ដី** : បានអនុវត្តគំនិតផ្តួចផ្តើមជាច្រើនដើម្បីកាត់បន្ថយការបញ្ចេញឧស្ម័នពីការកាប់បំផ្លាញព្រៃឈើ និងការរេចរឹលព្រៃឈើ និងដើម្បីលើកកម្ពស់ការអនុវត្តការប្រើប្រាស់ដីប្រកបដោយចីរភាព រួមមានកម្មវិធី REDD+ (ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់និងរេចរឹលព្រៃឈើ) និងគម្រោងទេសភាពនិងអេកូទេសចរណ៍ប្រកបដោយចីរភាព។ ជាលទ្ធផល គម្របព្រៃឈើនៅកម្ពុជាបានកើនឡើងពី៥៧,៥% ក្នុងឆ្នាំ២០១០ ដល់៥៩,៦% ក្នុងឆ្នាំ២០១៩។

ទោះបីជាការអនុវត្ត CCCSP ឆ្នាំ២០១៤-២០២៣ បានផ្តល់នូវសមិទ្ធផលជាច្រើន និងជំរុញដល់ការអនុវត្តសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុតាមវិស័យក៏ដោយ តែក៏នៅមានបញ្ហាប្រឈមមួយចំនួន រួមមានៈ ការរៀបចំគោលនយោបាយនិងស្ថាប័ន ការចូលរួមពីថ្នាក់ក្រោមជាតិ ការវាយតម្លៃតម្រូវការបច្ចេកវិទ្យា កង្វះថវិកា និងការសម្របសម្រួលពីម្ចាស់ជំនួយ ការសម្របសម្រួលសាធារណៈ ការត្រួតស៊ីគ្នា សមត្ថភាពស្ថាប័ន និងមន្ត្រីនៅមានកម្រិត និងការត្រួតពិនិត្យ ការរាយការណ៍ និងការផ្ទៀងផ្ទាត់(MRV)។

## ៧.២- ក្របខ័ណ្ឌតាមដានវាយតម្លៃសម្រាប់ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) ឆ្នាំ២០២៤-២០៣៣

យន្តការ M&E នឹងកំណត់សូចនាករចំបងសម្រាប់វាស់វែងប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃកម្មវិធី ផ្អែកលើលទ្ធផលវាយតម្លៃ CCCSP ឆ្នាំ២០១៤-២០២៣ៈ

- វាស់ស្ទង់ឱ្យដឹងថា តើកិច្ចខិតខំប្រឹងប្រែងបន្សាំមានប្រសិទ្ធភាពកម្រិតណា ក្នុងការរក្សាការអភិវឌ្ឍលើលំនាំនៃការប្រែប្រួលអាកាសធាតុ
- តាមដានសកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់និងគោលនយោបាយអភិវឌ្ឍន៍ដែលបញ្ចេញកាបូនតិច
- ផ្តល់ទិន្នន័យ ផ្អែកលើភស្តុតាង ដើម្បីគាំទ្រដល់ការកៀរគរធនធានគ្រប់គ្រាន់ សម្រាប់ការអនុវត្តយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព បរិយាបន្ន និងចីរភាព
- បង្កើតភស្តុតាងនិងមេរៀនជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍគោលនយោបាយនាពេលអនាគត
- សម្របសម្រួលការបញ្ចូល M&E នៃការប្រែប្រួលអាកាសធាតុឱ្យស៊ីចង្វាក់គ្នានៅក្នុងផែនការអភិវឌ្ឍន៍ជាតិ និងវិស័យសំខាន់ៗ
- គាំទ្រការរាយការណ៍អំពីកាតព្វកិច្ចចំពោះ UNFCCC និងដៃគូអភិវឌ្ឍ។

គោលការណ៍ដែលគួសបញ្ជាក់អំពីក្របខ័ណ្ឌនេះគឺៈ

- ការប្រើប្រាស់ប្រព័ន្ធនិងនីតិវិធីរបស់ជាតិ : ក្របខ័ណ្ឌនេះនឹងត្រូវបញ្ចូលជាមួយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១/NDC/LTS4CN M&E និងប្រព័ន្ធតាមដាន និងបង្កើតសូចនាករ គោលដៅយន្តការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់(MRV)។ ប្រព័ន្ធ M&E នៃCCCSP ឆ្នាំ២០២៤-២០៣៣ នឹងត្រូវរចនាឡើងស្របតាមគោលការណ៍នៃក្របខ័ណ្ឌពង្រឹងតម្លាភាព ក្រោមកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ ដែលនឹងរួមចំណែកក្នុងការផ្តល់ទិន្នន័យដែលមានប្រយោជន៍ សម្រាប់ការដាក់ស្នើរបាយការណ៍តម្លាភាពប្រចាំពីរឆ្នាំ (BTR) និងការប្តេជ្ញាចិត្តរាយការណ៍ផ្សេងទៀតនៅក្រោម UNFCCC ។
- ការបញ្ជ្រាប M&E នៃការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ ផែនការតាមវិស័យ និងនៅថ្នាក់ក្រោមជាតិ។

- ការពង្រឹងគណនេយ្យភាព សមធម៌ និងតម្លាភាព : ក្របខ័ណ្ឌនេះនឹងផ្តល់មធ្យោបាយសម្រាប់វាស់ស្ទង់ថាតើធនធានត្រូវបានប្រើប្រាស់យ៉ាងមានប្រសិទ្ធផលនិងមានប្រសិទ្ធភាពប៉ុណ្ណា ដើម្បីសម្រេចបាននូវគោលដៅដែលបានកំណត់ក្នុងគោលនយោបាយនិងផែនការសកម្មភាព ដូច្នេះវាជាការកែលម្អគណនេយ្យភាពចំពោះសាធារណៈ ស្ថាប័នរដ្ឋ សង្គមស៊ីវិល និងម្ចាស់ជំនួយអន្តរជាតិ។
- ការលើកកម្ពស់ការសិក្សាតាមបែបផែននៃការចូលរួម : ក្របខ័ណ្ឌនេះនឹងផ្តោតលើការបង្កើតចំណេះដឹងតាមរយៈវិធីសាស្ត្រចូលរួម ដែលនឹងគាំទ្រដល់ការកំណត់អត្តសញ្ញាណ និងការចែករំលែកមេរៀនដែលទទួលបាន។
- ការដោះស្រាយបញ្ហាយេនឌ័រ : ស្ត្រីនិងក្រុមដែលជួបការលំបាក ច្រើនតែស្ថិតក្នុងចំណោមក្រុមដែលរងផលប៉ះពាល់ដោយការប្រែប្រួលអាកាសធាតុ។ ក្របខ័ណ្ឌនេះនឹងដោះស្រាយសមភាពយេនឌ័រ ការអនុវត្តយេនឌ័រក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនិងការបញ្ជ្រាបយេនឌ័រ ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ រួមទាំងការបង្កើតនិងការអនុវត្តស្តង់ដាវាយតម្លៃភាពងាយរងគ្រោះនៃ GEDSI ឬគោលការណ៍ណែនាំក្នុង FOLU ថាមពល កសិកម្ម ទេសចរណ៍ និងវិស័យសំណង់។

ក្របខ័ណ្ឌសូចនាករនឹងចែកចេញជាពីរក្រុមសម្រាប់ការវាស់ស្ទង់អំពីការឆ្លើយតបរបស់ស្ថាប័ន សម្រាប់ការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងសមិទ្ធកម្មនៃការអភិវឌ្ឍលើការប្រែប្រួលអាកាសធាតុៈ

- សូចនាករដើមខ្សែ ដែលតាមដានប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យអាកាសធាតុ : ក្រុមនេះនឹងមានបញ្ចូលសូចនាករដែលទាក់ទងនឹងក្របខ័ណ្ឌស្ថាប័ន ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ និងដំណើរការរៀបចំផែនការ ហិរញ្ញប្បទានអាកាសធាតុ សមត្ថភាពស្ថាប័ន សមធម៌ និងតម្លាភាព និងការចូលរួមរបស់អ្នកពាក់ព័ន្ធ និងវិស័យឯកជន។
- សូចនាករចុងខ្សែ ដែលតាមដានការប្រែប្រួលនៃស្ថានភាពអភិវឌ្ឍន៍ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងភាពងាយរងគ្រោះនៃសហគមន៍ និងប្រព័ន្ធអេកូឡូស៊ីដោយសារអាកាសធាតុ : សូចនាករនេះនឹងមានបញ្ចូលទិន្នន័យ ស្ថិតិអភិវឌ្ឍន៍ជាតិ បង្គុំសូចនាករដែលបានពីវិស័យនានា និងគម្រោងបន្សាំ និងកាត់បន្ថយនីមួយៗ។

## ៧.៣- ការអនុវត្ត M&E

ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិ(MTR) នឹងត្រូវចាប់ផ្តើមនៅឆ្នាំ២០២៨ ដើម្បីពិនិត្យមើលវឌ្ឍនភាព និងកែប្រែគោលដៅ សូចនាករ និងសកម្មភាពតាមការចាំបាច់។ ការវាយតម្លៃផលប៉ះពាល់ នឹងត្រូវចាប់ផ្តើមនៅចុងបញ្ចប់នៃដំណាក់កាលទី២(ក្នុងឆ្នាំ២០៣៣)។ ការពិនិត្យនេះជាសកម្មភាពបន្ថែមពីលើសកម្មភាពត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំដែលបានស្នើឡើងខាងលើ។ សកម្មភាព M&E ប្រចាំឆ្នាំ នឹងផ្តល់ធាតុចូលសំខាន់ៗដល់ MTR និងការវាយតម្លៃផលប៉ះពាល់។

គោលបំណងនៃ MTR និងការវាយតម្លៃផលប៉ះពាល់គួរតែៈ

- វាយតម្លៃប្រសិទ្ធភាពនៃសកម្មភាពក្នុងការសម្រេចលទ្ធផលនៃ CCCSP ឆ្នាំ២០២៤-២០៣៣
- ពិនិត្យមើលការរៀបចំស្ថាប័ននិងតម្រូវការធនធានសម្រាប់ CCCSP ឆ្នាំ២០២៤-២០៣៣
- កំណត់យុទ្ធសាស្ត្រសម្រាប់ដំណាក់កាលទី២ និងនៅក្រោយឆ្នាំ២០៣៣។

## ៨- សេចក្ដីសន្និដ្ឋាន

ឯកសារនេះបានណែនាំនិងពិនិត្យមើលឡើងវិញនូវផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជាដែលបានស្នើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា។ ឯកសារផែនការយុទ្ធសាស្ត្រនេះកើតចេញការអនុវត្តនិងការវាយតម្លៃផែនការយុទ្ធសាស្ត្រឆ្លើយតបការប្រែប្រួលអាកាសធាតុ ដំណាក់កាលទី១ ឆ្នាំ២០១៤-២០២៣ សំដៅទៅការកសាងសហគមន៍មួយដែលមានសមត្ថភាព និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ ផែនការយុទ្ធសាស្ត្រនេះនឹងសម្រសបម្រួលនិងដឹកនាំអនុវត្តដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រសួងបរិស្ថាន នឹងចូលរួមអនុវត្តដោយក្រសួងស្ថាប័នទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ទៅតាមវិធានការដែលក្រសួងស្ថាប័នបានរៀបចំឡើងនៅក្នុងផែនការយុទ្ធសាស្ត្រនេះ។

កម្ពុជាក៏ត្រូវលើកម្ពស់ការអភិវឌ្ឍសង្គមឱ្យកាន់តែទូលំទូលាយ ថែមទាំងការពារបរិស្ថាន ធនធានធម្មជាតិ និងមានភាពធន់នឹងការប្រែប្រួលអាកាសធាតុផងដែរ។ ផែនការយុទ្ធសាស្ត្រឆ្លើយតបការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០២៤-២០៣៣ បានគិតគូរច្បាស់លាស់ពីការដាក់បញ្ចូលនូវវិធានការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងបន្សាំ ការប្រែប្រួលអាកាសធាតុឆ្ពោះទៅសម្រេចឱ្យបាននូវអព្យាក្រឹត្យកាបូននាឆ្នាំ២០៥០។

ដើម្បីសម្រេចឱ្យបាននូវគោលដៅ ផែនការយុទ្ធសាស្ត្រឆ្លើយតបការប្រែប្រួលអាកាសធាតុកម្ពុជា ឆ្នាំ២០២៤-២០៣៣ ទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីធានានូវការកំណត់ធនធានឱ្យបានច្បាស់លាស់តាមរយៈការកំណត់តួនាទីស្ថាប័នវាយតម្លៃហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ ព្រមទាំងធានានូវសង្គតិភាពទៅនឹងការរៀបចំគម្រោងកម្មវិធីវិនិយោគសាធារណៈ និងទុនវិនិយោគ។

# ឧបសម្ព័ន្ធ

## ការប៉ាន់ប្រមាណថវិកាសម្រាប់សកម្មភាពលទ្ធផលជាយុទ្ធសាស្ត្រ។

ការប៉ាន់ស្មានថវិកាបានមកពី៖

- ផែនការបច្ចុប្បន្នភាពជាតិរួមចំណែកឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ(NDC) ឆ្នាំ២០២០
- ធនាគារពិភពលោក - របាយការណ៍អាកាសធាតុ និងការអភិវឌ្ឍន៍ប្រទេស(ឆ្នាំ២០២៣)
- ការពិនិត្យចំណាយសាធារណៈលើការងារអាកាសធាតុកម្ពុជា(ឆ្នាំឆ្នាំ២០២២)
- កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល(ឆ្នាំ២០២២-២០២៤)។

ការប៉ាន់ប្រមាណដុលសម្រាប់សកម្មភាពនីមួយៗ បានមកពីប្រភពដែលតំណាងឱ្យសកម្មភាពដ៏ល្អបំផុត ដូចដែលបានបង្ហាញក្នុងតារាងខាងក្រោម។ សកម្មភាព CCCSP ក្នុងឆ្នាំ២០២៤-២០៣៣ ត្រូវបានរៀបចំឡើងដើម្បីឱ្យស្របតាមគោលនយោបាយនិងសកម្មភាពយុទ្ធសាស្ត្រដែលមានស្រាប់។ សកម្មភាពទាំងនេះគួរតែបានរួមបញ្ចូល និងត្រូវបានធ្វើឡើងដោយផ្អែកលើសកម្មភាពដែលបានគ្រោងទុកនៅក្នុងយុទ្ធសាស្ត្រនិងគោលនយោបាយពាក់ព័ន្ធ (ជាពិសេសកម្មវិធីចំណាយនិងការវិនិយោគអាកាសធាតុដែលមានប្រភពពី NDC និង RGC)។

សម្រាប់សកម្មភាពដែលគ្មានថវិកាប៉ាន់ស្មាន គេអាចធ្វើការសិក្សាលទ្ធភាព ឬការវិភាគអត្ថប្រយោជន៍នៃការចំណាយ ។

គួរកត់សម្គាល់ថា ថវិកានេះ គឺជាតួលេខដុល ដែលផ្អែកលើការប៉ាន់ប្រមាណកន្លងមក ដូចជា NDCs ដូច្នេះអាចជាតួលេខប៉ាន់ស្មានទាប។ គម្រោងឬផែនការសកម្មភាពលម្អិតនិងផែនការកៀរគរធនធាន គួរតែបានបង្កើតឡើងដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ដើម្បីធានាថា លទ្ធផលរំពឹងទុកនឹងសម្រេចទៅបាននូវក្របខ័ណ្ឌនៃការចំណាយដែលមានប្រសិទ្ធភាពនិងទាន់ពេលវេលា។

## ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

*តារាងទី៧ : សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ប្រភពនៃការប៉ាន់ប្រមាណថវិកា*

| លទ្ធផលយុទ្ធសាស្ត្រ | សកម្មភាព | សកម្មភាពដែលត្រូវគ្នានៅក្នុងប្រភព | ប្រភព |
|---|---|---|---|
| **១.១- បង្កើនការរួមចំណែករបស់ RE នៅក្នុងល្បាយថាមពលរបស់ជាតិ**<br>**១.២- បង្កើន EE និង RE នៅក្នុងការដំឡើងអគារ លំនៅឋាន និង** | i- ពង្រីកការអនុវត្ត/ពិនិត្យនិងកែលម្អកូដអគារបៃតង ដោយបញ្ចូលគោលការណ៍ណែនាំអំពីការដំឡើង EE និង RE នៅក្នុងអគារដែលមានស្រាប់ និងថ្មីៗ រួមបញ្ចូលនៅក្នុងផែនការអភិវឌ្ឍន៍លំនៅឋានប្រកបដោយចីរភាព និងតម្លៃសមរម្យ អគារសាធារណៈថ្មី និងដែលមានស្រាប់ | ការសិក្សាផែនទីបង្ហាញផ្លូវស្តីពីការបញ្ចូលធនធានថាមពលកកើតឡើងវិញ (ព្រះអាទិត្យ ខ្យល់ ទឹក ជីវម៉ាស) ទៅក្នុងល្បាយថាមពល | សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - សកម្មភាពទី ១៨<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័ន - ២៣ |

| | | | |
|---|---|---|---|
| ការដឹកជញ្ជូន (ការដឹកជញ្ជូនសាធារណៈ/ខ្នាតធំ រថយន្តអគ្គិសនី) | ដូចជាមណ្ឌលថែទាំសុខភាព សាលារៀន និងអគាររដ្ឋាភិបាល | | |
| | i- អនុវត្តនិងពង្រឹងការអនុវត្តបទប្បញ្ញត្តិស្របតាមគោលនយោបាយ EE និង RE | កូដអគារនិងការអនុវត្ត/ពង្រឹងការអនុវត្តសម្រាប់អគារថ្មីៗនិងអគារដែលកំពុងស្ថិតក្នុងដំណាក់កាលជួសជុល។ | សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ១៤ |
| | ii- បង្កើតនិងអនុវត្តស្តង់ដាសាកអាគុយ និងថែទាំ និងបទប្បញ្ញត្តិសុវត្ថិភាព | ការបញ្ចូលអាគុយ/ថែទាំរថយន្តអគ្គិសនីសម្រាប់ផ្លូវល្បឿនលឿន៤ | ធនាគារពិភពលោក (២០២៤); អនុសាសន៍របស់ប្រទេសកម្ពុជាចំពោះផែនទីផ្លូវជាតិសម្រាប់អន្តរកាលទៅយានយន្តអគ្គិសនី https://documents1.worldbank.org/curated/en/099031924073537111/pdf/P17690614457da0e71a4501e8dcdea2d59d.pdf |
| | iii- បង្កើតនិងអនុវត្តផែនការសកម្មភាព និងគោលដៅសម្រាប់ការដំឡើង RE ដែលសមស្រប ជាក់ស្តែងនិងតាមតម្លៃសមរម្យក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ (កសិកម្ម ទេសចរណ៍ ការផលិត និងសំណង់) | ការសិក្សាផែនទីបង្ហាញផ្លូវស្តីពី ការបញ្ចូលប្រភពថាមពលការកកើតឡើងវិញ (ព្រះអាទិត្យ ខ្យល់ ទឹក ជីវម៉ាស) ទៅក្នុងល្បាយថាមពល | សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ១៨ |
| | iv- កាត់បន្ថយការចំណាយលើការទិញ ផលិត ថែទាំ និងសេវាកម្មនៃការដំឡើង និងបរិក្ខារប្រសិទ្ធភាពថាមពល (ឧ. ការលើកទឹកចិត្តខាងផ្នែកពន្ធ)។ | ចំណាំ : *ពុំមានការប៉ាន់ប្រមាណថវិកាសម្រាប់សកម្មភាពនេះទេ ព្រោះវាអាចបញ្ចូលក្នុងសកម្មភាព iv និង v* | សូមអានសកម្មភាព iv ខាងលើ |
| | v- បញ្ចូល EE និង RE សម្រាប់លក្ខខណ្ឌតម្រូវក្នុងដឹកជញ្ជូនទ្រង់ទ្រាយធំក្នុងការអនុវត្ត «ផែនទីបង្ហាញផ្លូវសម្រាប់ផែនការមេទូលំទូលាយស្តីពីប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ពុជា ឆ្នាំ២០២៣-៣៣» | បង្កើតស្តង់ដាសម្រាប់ការសាងសង់និងថែទាំផ្លូវជាតិនិងផ្លូវខេត្ត ដោយគិតគូរពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ រួមទាំងការបង្កើតក្របខ័ណ្ឌ M&E សម្រាប់ភាពធន់នឹង | សកម្មភាព NDC៖<br>• ការបន្សាំ ៥៦<br>*ផែនការមេទូលំទូលាយរបស់ RGC ស្តីពីប្រព័ន្ធដឹកជញ្ជូន និងភស្តុភារកម្ពុជាឆ្នាំ២០២៣-៣៣* |

| | | | |
|---|---|---|---|
| | | អាកាសធាតុនិង**បច្ចេកវិទ្យាដែលបញ្ចេញកាបូនតិច។** | *ចំនួន១៧៤គម្រោង ៣៦,៧ ពាន់លានដុល្លារអាម៉េរិក(រាប់ទាំងកំពង់ផែ ផ្លូវដែក ផ្លូវថ្នល់ ផ្លូវទឹក សមុទ្រ និងផ្លូវអាកាស)។* |
| **១.៣- ពង្រឹងការអនុវត្ត CE និងការទប់ស្កាត់ការបំពុលក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗ (ទេសចរណ៍ កសិកម្ម សំណង់ ការផលិត ការដឹកជញ្ជូន។ល។)** | i- បង្កើត និងអនុវត្តផែនទីបង្ហាញផ្លូវ(ឬផែនការមេ)ស្តីពីការកាត់បន្ថយប្លាស្ទិក | ធនាគារពិភពលោក-កម្ពុជា : គម្រោងកែលម្អការគ្រប់គ្រងសំណល់រឹង និងប្លាស្ទិក(គម្រោង៥ឆ្នាំ២០២៤-២០២៩; ៦៧លានដុល្លារអាម៉េរិក) | https://projects.worldbank.org/en/projects-operations/project-detail/P170976 |
| | ii- ជំរុញការដាក់ពិន្ទុបដិសណ្ឋារកិច្ចប្រកបដោយចីរភាព(សណ្ឋាគារ/កន្លែងស្នាក់នៅ) វិញ្ញាបនបត្រស្លាកសញ្ញាបៃតង ឬចីរភាពនៃតំបន់ទេសចរណ៍ | រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកវិស័យទេសចរណ៍ថាជា «មាសបៃតង»។ | សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ៧៨ |
| | iii- បង្កើតនិងអនុវត្តកម្មវិធីកាត់បន្ថយការបាត់បង់ក្រោយប្រមូលផល និងសំណល់អាហារក្នុងខ្សែចង្វាក់តម្លៃកសិកម្ម | ពង្រីកផលិតកម្មកសិកម្មដែលធន់នឹងអាកាសធាតុ តាមរយៈការបង្កើនលទ្ធភាពទទួលបានប្រព័ន្ធស្រោចស្រពដើរដោយថាមពលព្រះអាទិត្យ និងការអនុវត្តផ្សេងទៀតដែលធន់នឹងអាកាសធាតុ | សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ១៦ |
| | iv- បង្កើនល្បឿននៃការអនុវត្តស្តង់ដាស្លាកសញ្ញាបៃតង/ចីរភាពសម្ភារៈវេចខ្ចប់/សម្ភារៈសំណង់ | ការបង្កើតកូដអគារជាមួយការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងការរចនាអគារ – លើកកម្ពស់សម្ភារៈដែលមានថ្លៃទាបសម្រាប់អគារនិងលំនៅឋាន | សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ៥៣ |
| **១.៤- ពង្រឹងធនធានទឹកឱ្យមានចីរភាព និងធន់ និងការគ្រប់គ្រងការផ្គត់ផ្គង់ ប្រព័ន្ធគ្រប់គ្រងសំណល់រឹង និងសំណល់រាវ និងហេដ្ឋារចនាសម្ព័ន្ធ** | i- បង្កើតនិងអនុវត្តយុទ្ធសាស្ត្រ/ផែនការមេសំណល់រឹងថ្នាក់ជាតិ(រួមទាំងមណ្ឌលកែច្នៃ - ប្លាស្ទិក អាលុយមីញ៉ូម កញ្ចក់ ក្រដាសជាដើម និងបញ្ចូលវិស័យសំណល់ក្រៅប្រព័ន្ធជាវិស័យផ្លូវការ) | ថ្លៃកែច្នៃប្លាស្ទិក (៤ 000 ដុល្លារអាម៉េរិក/តោន)។<br>សូមអានផងដែរ ធនាគារពិភពលោក - កម្ពុជា : គម្រោងកែលម្អការគ្រប់គ្រងសំណល់រឹងនិងប្លាស្ទិកខាងលើ។ | public-investment-programme-3-year-rolling-2023-2025.pdf<br><br>សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ៨ |

| | | | |
|---|---|---|---|
| | ii- ការសាងសង់ទីលានចាក់សំរាមអនាម័យ និងមណ្ឌល RDF/WTE | ទីលានចាក់សំរាមអនាម័យថ្មីជាមួយនឹងការទាញយកឧស្ម័នពីទីលានចាក់សំរាម(LFG) នៅទីលានចាក់សំរាមខណ្ឌដង្កោ។ សក្តានុពលសម្រាប់ការចូលរួមរបស់វិស័យឯកជនក្នុងការផ្តល់ហិរញ្ញប្បទាន ការសាងសង់ និងប្រតិបត្តិការទីលានចាក់សំរាមអនាម័យ និងប្រព័ន្ធ LFG។<br>ការផលិតឥន្ទនៈដែលបានពីសំណល់ (RDF) ពី ក) MSW ថ្មីៗ ឬ ខ) MSW ចាស់ដែលជីកយកពីទីលានចាក់សំរាមនៅខណ្ឌដង្កោ។ | សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ៥<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ៧ |
| | iii- អនុវត្តវិធីញែកសំណល់នៅតាមប្រភព | ការធ្វើជីកំប៉ុសពីសារធាតុសរីរាង្គដែលបានពី MSW បន្ថែមជាមួយសំណល់សរីរាង្គដែលញែក(**នៅតាមប្រភព**)។<br>*- ១) ថ្លៃការវិនិយោគតែម្តង (CAPEX) : ចាប់ពី៤០ដុល្លារអាម៉េរិកដល់៦០ដុល្លារអាម៉េរិកក្នុងមួយតោន/ឆ្នាំ សម្រាប់ការធ្វើជីកំប៉ុសពីសំរាមឬគំនរ រហូតដល់៣០០-៥០០ ដុល្លារអាម៉េរិក/តោន/ ឆ្នាំ សម្រាប់ការធ្វើជីកំប៉ុសក្នុងធុង។*<br>*- ២) តម្លៃប្រតិបត្តិការ : យ៉ាងតិច ៣២ដុល្លារអាម៉េរិក/តោនសម្រាប់ការធ្វើជីកំប៉ុសជាគំនរ*<br>អនុវត្តយុទ្ធសាស្ត្រជាតិ 4R (សូមមើលផងដែរ | សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ៨<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ១០ |
| | iv- ការអនុវត្តកាន់តែទូលំទូលាយនៃស្តង់ដាសំណល់រាវសម្រាប់វិស័យសេដ្ឋកិច្ចសំខាន់ៗ (កាត់ដេរ និងស្បែកជើង ការកែច្នៃម្ហូបអាហារ កសិកម្ម-បសុសត្វ ។ល។) | ការគ្រប់គ្រងសំណល់រាវឧស្សាហកម្មកាន់តែប្រសើរក្នុងវិស័យអាហារនិងភេសជ្ជៈ។ សរុបមក អាចផ្តោតលើការបង្កើតមធ្យោបាយហិរញ្ញវត្ថុពី៥ ទៅ១០ | សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ១១ |

| | | | |
|---|---|---|---|
| | v- អនុវត្តស្តង់ដាសំណល់ជាកាតព្វកិច្ច សម្រាប់វិស័យកាត់ដេរ កន្លែងប្រព្រឹត្តកម្ម សំណល់រាវ (និងសំណល់រាវ) | លានដុល្លារអាម៉េរិក ដើម្បីជួយដល់រោងចក្រដែលមានថវិកាបដិភាគ។<br><br>កំណត់សម្គាល់ : *ការគ្រប់គ្រងសំណល់រាវឧស្សាហកម្ម ដើម្បីប្រយោជន៍សង្គមនិងបរិស្ថាន តម្រូវឱ្យមានការ**អនុលោមតាមស្តង់ដាប្រព្រឹត្តកម្ម និងការបញ្ចេញចោល**។* | |
| **១.៥- បង្កើនលំហបៃតងក្នុងទីក្រុង និងកម្មវិធីបៃតងក្នុងទីក្រុងដោយប្រើប្រាស់ដំណោះស្រាយផ្អែកលើធម្មជាតិ** | អនុវត្តគោលដៅទីលានបៃតងក្នុងទីក្រុងសម្រាប់មនុស្សម្នាក់ៗ។ | ចំណាំ : *ហេដ្ឋារចនាសម្ព័ន្ធបៃតងគឺជាដំណោះស្រាយផ្អែកលើធម្មជាតិ ដើម្បីកែលម្អទីលានបៃតង ដោះស្រាយភាពតានតឹងក្នុងទីក្រុងនិងកាត់បន្ថយទឹកជំនន់។*<br>ភ្នំពេញ – *"ការចំណាយប្រចាំឆ្នាំសរុបត្រឹមឆ្នាំទី១០ មានប្រហែល៥០លានដុល្លារអាម៉េរិក ហើយការកើនឡើងនៃទ្រព្យសកម្ម GI លើផ្ទៃដីប្រហែល ២៤០០ហិកតា ដែលស្មើនឹងប្រមាណ ៣.៥% នៃផ្ទៃដីរដ្ឋបាលសរុប។ សេណារីយ៉ូនេះរួមបញ្ចូលការវិនិយោគដែលមានតម្លៃខ្ពស់ចម្រុះនៅក្រោមដំបូលបៃតង និងជញ្ជាំងបៃតង ដែលអាចជាលក្ខខណ្ឌតម្រូវបន្ថែមទៀតនៅកណ្តាលទីរួមស្រុក ក៏ដូចជាដើមឈើឧទ្យាននិងសួនច្បារ ដែលអាចសមស្របសម្រាប់ទីក្រុងទាំងមូល" ទំព័រ ៥៦។* | ការសិក្សាវិភាគសេដ្ឋកិច្ចនិងគោលនយោបាយហេដ្ឋារចនាសម្ព័ន្ធបៃតងដែលធន់ក្នុងទីក្រុង (2022) https://ncsd.moe.gov.kh/sites/default/files/2022-09/SV_Cambodia%20GI%20Report%20Final.pdf |
| | បញ្ជ្រាប និងបញ្ចូលដំណោះស្រាយផ្អែកលើធម្មជាតិទៅក្នុងការរៀបចំផែនការទីក្រុង បទប្បញ្ញត្តិ និងកូដអគារ រួមទាំងនៅថ្នាក់ក្រោមជាតិ។ | ឧបករណ៍រៀបចំផែនការទីក្រុងសម្រាប់កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងដំណោះស្រាយផែនការទីក្រុងនៅក្នុងទីក្រុងតូចៗចំនួនបី។ | សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ១<br>• ការបន្សាំ - ៤៩ |

| | | | |
|---|---|---|---|
| | | រៀបចំគំរូស្តង់ដាលំហបៃតងសម្រាប់រៀបចំផែនការទីក្រុង ឬក្រុងរណបថ្មី ដើម្បីដោះស្រាយភាពងាយរងគ្រោះនៃនគរូបនីយកម្ម។ | |
| | ដាក់ចេញគំរូហិរញ្ញប្បទានអាកាសធាតុសម្រាប់ភាពជាដៃគូសាធារណៈ-ឯកជនលើការរចនាអគារបៃតង/ដោយនិរន្តរភាព និងការរចនា សំណង់ និងអចលនទ្រព្យដែលធន់រួមទាំងផ្ទះដែលមានតម្លៃសមរម្យនិងធន់។ | ការសិក្សានេះរួមបញ្ចូលភាពជាដៃគូសាធារណៈ-ឯកជន និងយន្តការហិរញ្ញប្បទានផ្សេងៗ សម្រាប់ការពង្រីកហេដ្ឋារចនាសម្ព័ន្ធបៃតងក្នុងរាជធានីភ្នំពេញ។<br><br>*សូមអានថវិកាសម្រាប់លទ្ធផលយុទ្ធសាស្ត្រ ៣.១ ខាងក្រោម* | ការវិភាគសេដ្ឋកិច្ច និងគោលនយោបាយហេដ្ឋារចនាសម្ព័ន្ធបៃតងដែលធន់នៅក្នុងទីក្រុងរបស់កម្ពុជា |
| | បង្កើនល្បឿននិងពង្រីកយុទ្ធនាការដាំដើមឈើ | ជំរុញយុទ្ធនាការ ទេសចរម្នាក់ ឈើ១ដើម (១ ដុល្លារអាម៉េរិក/កូនឈើ១ដើម)។ | សកម្មភាព NDC៖<br>• ការបន្សាំ - ៤០ |
| | ពង្រឹងការអនុវត្តពេញលេញនូវកូដអគារ លិខិតអនុញ្ញាតសាងសង់ បទប្បញ្ញត្តិរៀបចំផែនការទីក្រុង និងតម្រូវការលំហបៃតង | សូមអាន ១.១ ខាងលើ | សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ១៨<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ២៣ |
| **១.៦- បង្កើនគម្របព្រៃឈើ និងបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ** | i- បង្កើតនិងអនុវត្តផែនការគ្រប់គ្រងធនធានធម្មជាតិតាមបែបចូលរួម<br>ii- យុទ្ធសាស្ត្រចូលរួមដើម្បីបង្កើនការចូលរួមរបស់វិស័យឯកជន និងសហគមន៍ និងការចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការបង្កើនគម្របព្រៃឈើ (ឧ. តាមរយៈរ៉េដបូក) | ចំណាំ : ថវិកាសម្រាប់ i-iv ត្រូវបានយោងពីថវិកាដែលនៅក្នុង LTS4CN។<br><br>ចែកជូនកូនឈើដល់សាធារណជន និងសហគមន៍មូលដ្ឋាន១ដុល្លារអាម៉េរិក/ដើម។ | LTS4CN ទំព័រ ១៦, ២.២.២ ផែនការហិរញ្ញវត្ថុសាធារណៈ<br><br>សកម្មភាព NDC៖ |

| | | | |
|---|---|---|---|
| | iii- បង្កើនការរួមចំណែករបស់សហគមន៍មូលដ្ឋានក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ (ឧ. បង្កើតប្រាក់ចំណូលពីឥណទានកាបូន) | ផែនការវិនិយោគរជេបូក ដែលត្រូវការ ១៦លានដុល្លារអាម៉េរិក/ឆ្នាំ (លើស១០ ឆ្នាំ = ប្រមាណ១៦០លានដុល្លារ អាម៉េរិក) (i-v) | • ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ៣៨ |
| | iv- អនុវត្តវិធីធ្វើកសិកម្មដោយនិរន្តរភាពក្នុងចំណោមសហគមន៍មូលដ្ឋាន ដូចជាបដិសេធការធ្វើកសិកម្មពនេចរ តាមរយៈការពង្រីកកសិរុក្ខកម្ម ដើម្បីលើកកម្ពស់ជីវភាព និងសន្តិសុខស្បៀង។ | | |
| | v- ពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិពេញលេញ ដើម្បីបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ | | |
| | vi- ពិនិត្យនិងបន្សុីគោលនយោបាយឡើងវិញ ដើម្បីបញ្ឈប់ការកាប់បំផ្លាញព្រៃឈើ។ លុបចោលវិធានការលើកទឹកចិត្តដែលជំរុញការកាប់ឈើ | សកម្មភាពលើកកម្ពស់ការរកប្រភពផ្គត់ផ្គង់អុសដែលមាននិរន្តរភាពនៅក្នុងឧស្សាហកម្មកាត់ដេរ | សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ២៥ |
| | vii- បង្កើនការចូលរួមពីភាគីពាក់ព័ន្ធ អង្គការសង្គមស៊ីវិល សហគមន៍ និងវិស័យឯកជនក្នុងយុទ្ធនាការដាំដើមឈើ (១លានដើមក្នុងមួយឆ្នាំៗ) | ចែកកូនឈើជូនសាធារណៈជន និងសហគមន៍មូលដ្ឋាន ផ្សព្វផ្សាយយុទ្ធនាការទេសចរម្នាក់ឈើមួយដើម។ | សកម្មភាព NDC៖<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ៣៨<br>• ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ - ៤០ |

## ពង្រឹងសមត្ថភាពបន្សាំ

*តារាងទី៨ : សកម្មភាពបន្សាំ ប្រភពនៃការប៉ាន់ប្រមាណថវិកា*

| លទ្ធផលយុទ្ធសាស្ត្រ | សកម្មភាព | ថវិកាដែលត្រូវគ្នានៅក្នុងប្រភព | ប្រភព |
|---|---|---|---|
| ២.១- ពង្រឹងវិធានការធន់នៅគ្រប់វិស័យសេដ្ឋកិច្ច និងសេវាសង្គមសំខាន់ៗ (សេវាកម្មទឹកស្អាត អគ្គិសនី អនាម័យ ការថែទាំសុខភាព អាហារូបត្ថម្ភ ការអប់រំ សង្គម និងកិច្ចគាំពារកុមារ ទេសចរណ៍ ប្រព័ន្ធអាហារដែលមាននិរន្តរភាព និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជាWASH ថាមពល ផ្លូវថ្នល់ជាដើម) ដោយផ្ដោតជាពិសេស លើតម្រូវការរបស់កុមារ និងសហគមន៍ដែលងាយរងគ្រោះបំផុត។<br><br>២.២- ពង្រឹងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការត្រៀមបង្ការ និងការស្តារឡើងវិញនៅទូទាំងសហគមន៍(សហគមន៍ឆ្នេរ ទន្លេសាប និងសហគមន៍ទន្លេមេគង្គ) | i- ការវាយតម្លៃភាពងាយរងគ្រោះពេញលេញនៃហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសំខាន់ៗ ទីក្រុង ឆ្នេរសមុទ្រ និងទន្លេ សន្តិសុខទឹក និងថាមពល និងអនុវត្តវិធានការទប់ទល់ (ដូចជាការសង់បង្កើយរបាំងការពាររលកសមុទ្រ ការទប់ស្កាត់ការហូរច្រោះឆ្នេរសមុទ្រ ការគ្រប់គ្រង/ការពារទឹកជំនន់ក្នុងទីក្រុង ការកែលម្អទិន្នន័យសុខភាពមនុស្ស សត្វនិងរុក្ខជាតិ និងភាពខ្វះចន្លោះក្នុងការត្រួតពិនិត្យ) | ការវាយតម្លៃភាពងាយរងគ្រោះឆ្ពោះទៅកសាងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់លើដីធ្លី លំនៅឋាន ការគ្រប់គ្រងឆ្នេរសមុទ្រ និងអគារដោយសារការប្រែប្រួលអាកាសធាតុ | សកម្មភាព NDC៖<br>• ការបន្សាំ - សកម្មភាព ទី១០<br>• ការបន្សាំ - ២៤<br>• ការបន្សាំ -៣៨<br>• ការបន្សាំ - ៥០ |
| | ii- បង្កើតនិងអនុវត្តគោលការណ៍ណែនាំអំពីទីក្រុងបៃតងនិងភាពធន់នៅក្នុងផែនការមេនៃការអភិវឌ្ឍទីក្រុង ដែលរួមបញ្ចូលដំណោះស្រាយផ្អែកលើធម្មជាតិ | ការបញ្ចូលវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុទៅលើការរចនាសំណង់អគារ និងសម្រាប់លំនៅឋានជនបទ (ការប្រើប្រាស់សមាហរណកម្មបច្ចេកវិទ្យាទំនើប) | សកម្មភាព NDC៖<br>• ការបន្សាំ - ៤៤<br>• ការបន្សាំ - ៤៩<br>• ការបន្សាំ - ៤៧ |
| | iii- បង្កើតនិងអនុវត្តស្តង់ដា/លក្ខខណ្ឌតម្រូវសម្រាប់ការរចនាដែលធន់នឹងអាកាសធាតុនិងសម្ភារៈសម្រាប់ការសាងសង់ផ្លូវថ្មីនិងការថែទាំផ្លូវដែលមានស្រាប់ ឆ្លើយតបទៅនឹងហានិភ័យអាកាសធាតុ និងភាពងាយរងគ្រោះ។ | ជួសជុល និងស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដែលមានស្រាប់ និងធានាបាននូវប្រតិបត្តិការ និងប្រព័ន្ធថែទាំប្រកបដោយប្រសិទ្ធភាព ដោយគិតគូរពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ(ការសាងសង់ និងថែទាំផ្លូវ) | កម្មវិធីស្បៀងអាហារពិភពលោក (WFP)<br>• គម្រោងបំពង់បង្ហុរប្រេងធំៗនាពេលបច្ចុប្បន្នផ្តោតលើ EWS មានថវិកាសរុបចំនួន៣០លានដុល្លារអាមេរិក+ (CREWS, GCF-UNDP, SOFF)។<br>• ការព្រមានជាមុនសម្រាប់ផែនទី |

| | | | |
|---|---|---|---|
| | | | *បង្ហាញផ្លូវនៃការអនុវត្តទាំងអស់ (ត្រូវបង្កើយឆាប់ៗនេះ) នឹងផ្តល់ការប៉ាន់ប្រមាណចំណាយលម្អិតជាផ្លូវការបន្ថែមទៀតជាទាក់ទងនឹង EWS។* |
| | iv- បង្កើតនិងអនុវត្តលក្ខខណ្ឌតម្រូវសម្រាប់លំនៅឋានដែលមានតម្លៃសមរម្យ ចំណាយទាប និងធន់នៅក្នុងផែនការមេ និងការអភិវឌ្ឍទីក្រុង/ទីប្រជុំជន | ការបញ្ចូលវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយសម្បទានដីសង្គមកិច្ច (SLC) និងនីតិវិធី។<br><br>ជំរុញការរៀបចំលំនៅឋាន ដែលមានតម្លៃទាបសមរម្យសម្រាប់គ្រួសារដែលមានចំណូលទាបសំដៅលើកកម្ពស់ភាពធន់នឹងការប្រែប្រួលអាកាសធាតុជាក់ស្តែងនៅក្នុងតំបន់សម្បទានដីសង្គមកិច្ច។ | សកម្មភាព NDC៖<br>• ការបន្សាំ - ៤៨<br>• ការបន្សាំ- ៥២ |
| | v- ពិនិត្យនិងកែសម្រួលកន្លែងស្តុកទឹកឡើងវិញ ដើម្បីភាពធន់នឹងអាកាសធាតុ សុវត្ថិភាពធនធានទឹក និងគុណភាព | បង្កើតវិធីសាស្ត្រថ្នាក់កណ្តាលនិងតាមស្តង់ដាសម្រាប់ការគ្រប់គ្រងទឹកដែលធន់នឹងអាកាសធាតុ។<br><br>បង្កើតប្រព័ន្ធអនុវត្តល្អបំផុតតាមស្តង់ដាជាតិសម្រាប់ប្រព័ន្ធស្រោចស្រព | សកម្មភាព NDC៖<br>• ការបន្សាំ - ៥៧<br>• ការបន្សាំ- ៨២<br>• ការបន្សាំ - ៨៦ |
| | vi- ជំរុញការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) | បង្កើតវិធីសាស្ត្រថ្នាក់កណ្តាលនិងស្តង់ដាសម្រាប់គ្រប់គ្រងទឹកនិងដែលធន់នឹងអាកាសធាតុ។<br><br>ការគ្រប់គ្រងទឹកក្រោមដីចម្រុះនៅកម្ពុជា។ | |
| | vii- ពិនិត្យនិងផ្តល់អាទិភាពដល់កិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងតំបន់និងជំនួយក្នុងការគ្រប់គ្រងធនធានទឹកឆ្លងដែន | ប្រព័ន្ធប្រកាសអាសន្នថ្នាក់ជាតិពីដើមដល់ចប់ដោយផ្តោតលើការផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពដល់ប្រជាជនដែលមានហានិភ័យ បានបង្កើតប្រព័ន្ធប្រកាសអាសន្នទឹកជំនន់ឆ្លងដែនជាមួយវៀតណាម និងថៃ | |

| | | | |
|---|---|---|---|
| | viii- ធ្វើផែនទីទឹកក្រោមដី ការត្រួតពិនិត្យ និងយុទ្ធសាស្ត្រគ្រប់គ្រងសម្រាប់សន្តិសុខទឹកនិងធន់នឹងអាកាសធាតុ | បង្កើតវិធីសាស្ត្រថ្នាក់កណ្តាល និងស្តង់ដាសម្រាប់ការគ្រប់គ្រងទឹកដែលធន់នឹងអាកាសធាតុ<br><br>ការគ្រប់គ្រងទឹកក្រោមដីចម្រុះនៅកម្ពុជា - | |
| | ix- ផែនការជានាវ៉ាប់រងនិងការថែទាំសុខភាព កាលវិភាគធ្វើការ-សម្រាកកម្សាន្ត- WRS ដែលត្រូវគ្នាទៅនឹងផលប៉ះពាល់ចំពោះសុខភាពពីការប្រែប្រួលអាកាសធាតុ ដូចជាភាពតានតឹងដោយសារកម្តៅសម្រាប់កម្មករ/ការងារក្រៅផ្ទះ | ពង្រឹងភាពធន់នឹងអាកាសធាតុក្នុងការផ្តល់សេវាសុខាភិបាល | សកម្មភាព NDC៖<br>• ការបន្សាំ - ៣៤<br>• ការបន្សាំ -៣៥<br>• ការបន្សាំ - ៣៨<br>• ការបន្សាំ - ៣៩ |
| | x- សាកល្បងនិងពង្រីកកិច្ចផ្តួចផ្តើមសេវាកម្មសង្គមឆ្លាតវៃ ( ការអប់រំសុខភាព កិច្ចគាំពារកុមារ ) | ការផ្សាយព័ត៌មាននិងការផលិតកម្មវិធីសម្រាប់ការលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់។<br><br>ការធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សា និងវិធីសាស្ត្របណ្តុះបណ្តាល រួមទាំងបណ្ណាល័យ ដើម្បីរួមបញ្ចូលមុខវិជ្ជាប្រែប្រួលអាកាសធាតុសម្រាប់ថ្នាក់បឋមសិក្សា។<br><br>បង្កើតមជ្ឈមណ្ឌលឧត្តមភាពសម្រាប់ការផ្តល់វគ្គសិក្សា និងការស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុក្នុងចំណោមសាកលវិទ្យាល័យ។<br><br>បើកវគ្គបណ្តុះបណ្តាលមន្ត្រីអប់រំស្តីពីការប្រែប្រួលអាកាសធាតុ ឧ. ជាធាតុផ្សំចាំបាច់នៃការបណ្តុះបណ្តាលគរុកោសល្យគ្រូ។ | |
| | xi- ពង្រីកអនុលោមភាពតាមការណែនាំរបស់អង្គការសុខភាពពិភពលោកសម្រាប់មណ្ឌលថែទាំសុខភាពដែលធន់នឹងអាកាសធាតុ និងនិរន្តរភាពបរិស្ថាន និងបន្សីបច្ចេក | បង្កើតប្រព័ន្ធព្រមានអំពីអាកាសធាតុ និងទឹកជំនន់ រួមទាំងមជ្ឈមណ្ឌលសេវាកម្ម និងផែនការឆ្លើយតបគ្រោះទឹកជំនន់ | |

| | | | |
|---|---|---|---|
| | វិទ្យា និងកម្រងទិន្នន័យសុខភាព EWS | | |
| | xii- ពិនិត្យនិងធ្វើការកែលម្អនៅក្នុងគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដោយជំរុញផែនការអនុវត្តការអនុវត្តយុទ្ធសាស្ត្រហិរញ្ញប្បទានហានិភ័យគ្រោះមហន្តរាយ(ឆ្នាំ២០២៣-២០២៨) | ប្រព័ន្ធប្រកាសអាសន្នថ្នាក់ជាតិពីដើមដល់ចប់ ដោយផ្តោតលើការផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពដល់ប្រជាជនដែលមានហានិភ័យ<br><br>បង្កើតនិងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំនូវការវាយតម្លៃពហុហានិភ័យនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងហានិភ័យអាកាសធាតុ រួមទាំងការកំណត់អត្តសញ្ញាណសហគមន៍ដែលងាយរងគ្រោះបំផុត<br><br>អនុវត្តកម្មវិធីគ្រប់គ្រងហានិភ័យអាកាសធាតុ និងគ្រោះមហន្តរាយដោយផ្អែកលើសហគមន៍ | សកម្មភាព NDC៖<br>• ការបន្សាំ - ៦០<br>• ការបន្សាំ - ៦១<br>• ការបន្សាំ - ៦២ |
| **២.៣- ពង្រឹងការអភិរក្សប្រព័ន្ធអេកូឡូស៊ី និងការគ្រប់គ្រងធនធានធម្មជាតិដោយនិរន្តរភាព (រួមទាំងទន្លេមេគង្គ បឹងទន្លេសាប ព្រៃឈើ ជីវចម្រុះ ប្រព័ន្ធអេកូឡូស៊ីទីក្រុង និងការបញ្ជ្រាបដំណោះស្រាយ និងការបន្សាំតាមធម្មជាតិ)** | i- បង្កើនសមត្ថភាពសហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិតាមបែបសហគមន៍(CBNRM)ក្នុងចំណោមសហគមន៍ឆ្នេរ ទន្លេសាប និងសហគមន៍ដងទន្លេមេគង្គ ឆ្នេរសមុទ្រ តំបន់ខ្ពង់រាប និងសហគមន៍ទីក្រុង។ | ការគ្រប់គ្រងធនធានធម្មជាតិចម្រុះ (INRM) នៅក្នុងតំបន់ទេសភាពធម្មជាតិនិងព្រៃឈើនៃតំបន់ភាគខាងជើងនៃប្រទេសកម្ពុជា (UNDP និង GEFសន្យាផ្តល់មូលនិធិ)<br><br>គម្រោងអភិរក្សព្រៃឡង់ (មូលនិធិផ្តល់ដោយរដ្ឋាភិបាលជប៉ុន) | កម្មវិធីវិនិយោគសាធារណៈ(PIP)៣ឆ្នាំរំកិល ឆ្នាំ២០២៣-២០២៥) ទំព័រ ៦៤ |
| | ii- សមត្ថភាពនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីពង្រឹងភាពអង់អាចរបស់សហគមន៍មូលដ្ឋានដើម្បីអភិវឌ្ឍ/ធ្វើឱ្យប្រសើរឡើងនូវទេសចរណ៍ធម្មជាតិដែលផ្អែកលើសហគមន៍ | កាត់បន្ថយភាពងាយរងគ្រោះរបស់សហគមន៍មូលដ្ឋាន តាមរយៈកំណែទម្រង់អភិបាលកិច្ចអាកាសធាតុថ្នាក់ក្រោមជាតិ (ផ្តោតលើគោលនយោបាយ)។<br><br>ការកសាងសមត្ថភាពបន្សាំនិងធន់ សម្រាប់មន្ត្រី MRD នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ជនបទ និងការរចនាបច្ចេកទេស។ | PIP ២០២៣-២០២៥<br>• MoE - តំបន់ទេសភាព និងអេកូទេសចរណ៍កម្ពុជាមាននិរន្តរភាព (CSLEP)<br>• MRD CSLEP<br><br>សកម្មភាព NDC<br>• ការបន្សាំ -៣៣<br>• ការបន្សាំ - ៣២ |

| | | | |
|---|---|---|---|
| **២.៤- ពង្រឹងភាពធន់នៃក្រុមងាយរងគ្រោះ និងបញ្ជ្រាប GEDSI សំខាន់ៗក្នុងសកម្មភាពអាកាសធាតុ និងភាពធន់** | i- អនុវត្តប្រព័ន្ធគាំពារសង្គមទូលំទូលាយដែលបានបន្សាំ( ឧ. ពង្រីកកម្មវិធីផ្ទេរសាច់ប្រាក់ជំនួយសង្គម ដល់គ្រួសារងាយរងគ្រោះ (និងក្រុមនានា ដូចជាកុមារ ជនពិការ និងសហគមន៍មូលដ្ឋាន) | ការបញ្ជ្រាបយេនឌ័រក្នុងវិស័យធនធានទឹក។<br><br>ពង្រឹងប្រព័ន្ធតាមដាននិងវាយតម្លៃរបស់ក្រសួងនានា ដើម្បីតាមដានលទ្ធផលយេនឌ័រក្នុងកិច្ចផ្តួចផ្តើមប្រែប្រួលអាកាសធាតុ ដោយផ្តោតជាពិសេសលើការប្រមូល និងគ្រប់គ្រងទិន្នន័យញែកតាមភេទ សូចនាករយេនឌ័រ និងថវិកា ការរាយការណ៍ផ្អែកលើលទ្ធផល និងការផ្សព្វផ្សាយ និងការបង្កើនការបន្សាំនឹងយេនឌ័រ និងបង្កើតចំណេះដឹងដែលពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ។ | កម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល (ឆ្នាំ២០២៣-២០២៥) ទំព័រ១២១<br><br>សកម្មភាព NDC<br>• ការបន្សាំ - ២៧<br>• ការបន្សាំ - ២៨ |
| | ធ្វើពិពិធកម្មរបរជីវិតក្នុងចំណោមក្រុមដែលងាយរងគ្រោះដោយសារ ផលប៉ះពាល់បន្តិចម្តងៗបណ្តាលពីការប្រែប្រួលអាកាសធាតុ | ខ្សែចង្វាក់ផ្គត់ផ្គង់ទីផ្សារដែលធន់នឹងការប្រែប្រួលអាកាសធាតុ សម្រាប់ស្ត្រីសហគ្រិនតាមជនបទ | សកម្មភាព NDC<br>• ការបន្សាំ - ៣១ |
| | កសាងសមត្ថភាពធន់សម្រាប់សហគមន៍ដែកងាយរងគ្រោះនិងសហគមន៍គ្រប់គ្រងធនធានធម្មជាតិតាមរយៈការវិនិយោគគម្រោងបន្សាំផ្អែកលើធម្មជាតិ ការទទួលបានការផ្តល់ដំណឹងជាមុននិងការត្រៀមនឹងគ្រោះមហន្តរាយ និងជីវភាពធន់នឹងអាកាសធាតុ | ការវិភាជន៍ថវិកាពីយន្តការហិរញ្ញប្បទានអាកាសធាតុនិងការសម្របសម្រួលជំនួយ | សកម្មភាព NDC<br>• ការបន្សាំ - ៣១ |
| | បង្កើតនិងអនុវត្តផែនការអភិវឌ្ឍសមត្ថភាពសម្រាប់ក្រសួងនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីរួមបញ្ចូល GEDSI ទៅក្នុងគោលនយោបាយ ផែនការ និងការបង្កើតកម្មវិធីបន្សុំនឹងការប្រែប្រួលអាកាសធាតុ។ | ពង្រឹងសមត្ថភាពស្ថាប័ននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធ្វើសមាហរណកម្មការឆ្លើយតបខាងយេនឌ័រក្នុងគោលនយោបាយ ផែនការ ការបង្កើតកម្មវិធី។ | សកម្មភាព NDC<br>• ការបន្សុំ - ២៦ |
| | i- ពង្រីកការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តវិធានការឆ្លើយតបខាងយេនឌ័រ (រួមទាំងការដោះស្រាយអំពើហិង្សាផ្អែកលើ | ការអភិវឌ្ឍសមត្ថភាពសម្រាប់សមាជិក GCCC និងក្រសួង លើការវិភាគយេនឌ័រ ការឆ្លើយតបយេនឌ័រ និង NDC។ | សកម្មភាព NDC<br>• ការបន្សុំ - ២៩<br>• ការបន្សុំ - ៣០ |

| | | | |
|---|---|---|---|
| | យេនឌ័រ GBV) ផែនការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ | បង្កើតគោលការណ៍ណែនាំបច្ចេកទេសសម្រាប់ការបញ្ជ្រាបយេនឌ័រនៅក្នុងដំណើរការ NDC។ | |
| | ii- រួមបញ្ចូលការអនុវត្តវិធានការឆ្លើយតបខាងយេនឌ័រដោយផ្អែកលើលទ្ធផល ទៅក្នុង CCCSP ឆ្នាំ ២០២៤-២០៣៣ M&E និងប្រព័ន្ធរាយការណ៍ | ពង្រឹងប្រព័ន្ធតាមដាននិងវាយតម្លៃរបស់ក្រសួង ដើម្បីតាមដានលទ្ធផលយេនឌ័រក្នុងកិច្ចផ្តួចផ្តើមប្រែប្រួលអាកាសធាតុ ដោយផ្តោតជាពិសេសលើការប្រមូលនិងគ្រប់គ្រងទិន្នន័យញែកតាមភេទ សូចនាករយេនឌ័រ និងថវិកា ការរាយការណ៍ផ្អែកលើលទ្ធផល និងការផ្សព្វផ្សាយ និងការបង្កើនចំណេះដឹងដែលបានបង្កើតឡើង អំពីយេនឌ័រ និងដែលទាក់ទងការប្រែប្រួលអាកាសធាតុ។ | សកម្មភាព NDC<br>• ការបន្សាំ - ២៨ |
| **២.៥- ពង្រឹងវិធានការនិរន្តរភាព និងភាពធន់ (រួមទាំងបច្ចេកវិជ្ជាឆ្លាតវៃខាងអាកាសធាតុ កសិកម្មកែលំអគុណភាពដី។ល។) ក្នុងវិស័យកសិកម្មនិងខ្សែចង្វាក់តម្លៃស្បៀងអាហារ។** | ស្រាវជ្រាវនិងអភិវឌ្ឍន៍ និងពង្រីកសេវាផ្សព្វផ្សាយដល់កសិករ លើកកម្ពស់ភាពធន់នឹងអាកាសធាតុ ដំណាំមានតម្លៃខ្ពស់ ការបន្ថែមតម្លៃ និងលទ្ធភាពប្រើប្រាស់ទីផ្សារ។ | ការកែលម្អសេវាកម្មគាំទ្រនិងកសាងសមត្ថភាពដល់ផលិតកម្មដំណាំដែលធន់នឹងការប្រែប្រួលអាកាសធាតុ ដោយលើកកម្ពស់ការស្រាវជ្រាវ ការសាកល្បង និងប្រព័ន្ធកសិកម្មឆ្លាតវៃខាងអាកាសធាតុដែលបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុនិងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ<br><br>ស្រាវជ្រាវដើម្បីអភិវឌ្ឍនិងលើកកម្ពស់ផលិតភាពកសិកម្ម គុណភាព និងការផ្ទេរ តាមរយៈការពង្រឹងការអភិរក្សពូជដំណាំ និងការចេញផ្សាយពូជដំណាំថ្មីៗ ឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ<br><br>ការអភិវឌ្ឍបច្ចេកវិទ្យាថ្មី និងការបង្កើនទិន្នផល ដោយប្រើពូជដំណាំថ្មីៗដែលបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ | សកម្មភាព NDC<br>• ការបន្សាំ - ៥<br>• ការបន្សាំ - ៧<br>• ការបន្សាំ - ៨ |
| | ពង្រីកការអនុវត្តកសិកម្មឆ្លាតវៃខាងអាកាសធាតុ ឧបករណ៍ហិរញ្ញវត្ថុ (រួមទាំងការធានារ៉ាប់រងដំណាំ ការការពារ/ការស្តារឡើងវិញពីគ្រោះមហន្តរាយ)។ | បង្កើតឯកសារណែនាំការបណ្តុះបណ្តាល និងផ្តល់ការបណ្តុះបណ្តាលអំពីវិធីសាស្ត្របង្កើតរបរដែលឆ្លាតវៃចំពោះអាកាសធាតុ និងមាននិរន្តរភាព ដល់ពលរដ្ឋក្រីក្រនៅតាមជនបទ។ | សកម្មភាព NDC<br>• ការបន្សាំ - ១៧<br>គម្រោងធានារ៉ាប់រងគ្រោះមហន្តរាយ<br>(ក្របខ័ណ្ឌហិរញ្ញប្ប |

| | | | |
|---|---|---|---|
| | និងតាមដានការទទួលយកបច្ចេកវិទ្យា/ការអនុវត្ត និងប្រសិទ្ធភាព។ | | ទានការប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤); ធានារ៉ាប់រងកសិកម្មតំបន់អាស៊ានះ កម្ពុជា (២០២២)[30] |
| | បញ្ជ្រាបនិងលើកទឹកចិត្តផ្នែកកសិកម្មដំណោះស្រាយផ្អែកលើធម្មជាតិ និងការអនុវត្តកសិកម្មកែលំអគុណភាពដី | | សកម្មភាព NDC<br>• ការបន្សុំ- ១ |
| | ពង្រីកកិច្ចគាំពារ (រួមទាំងពង្រឹងការអនុវត្តច្បាប់)សម្រាប់ជម្រកសំខាន់ៗសម្រាប់ធនធានជលផល (ព្រៃកោងកាង ស្មៅសមុទ្រ។ល។) | ការគ្រប់គ្រងនិងការពារប្រព័ន្ធអេកូឡូស៊ីនៃតំបន់សមុទ្រ និងតំបន់ឆ្នេរដោយប្រសិទ្ធភាព ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានពីកត្តាផ្សេងៗ កសាងភាពធន់នៃប្រព័ន្ធទាំងនេះ និងស្តារឡើងវិញនូវមុខងារអេកូឡូស៊ីដើម្បីឱ្យសមុទ្រមានផលិតភាពនិងមានសុខភាពល្អ។ | សកម្មភាព NDC<br>• ការបន្សុំ - ១៩ |
| | លើកទឹកចិត្តនៅកម្រិតសហគមន៍ (ថ្នាក់ក្រោមជាតិ) ការវិនិយោគដែលធន់នឹងអាកាសធាតុសម្រាប់កសិករខ្នាតតូច (ការផ្ទុក ការបន្ថែមតម្លៃ ការប្រើប្រាស់ទីផ្សារ ការដំឡើងថាមពលពន្លឺព្រះអាទិត្យ ការប្រមូលទឹកភ្លៀង សន្តិសុខទឹក WASH ជាដើម)។ | ការលើកកម្ពស់ភាពធន់នឹងអាកាសធាតុក្នុងវិស័យជលផល។<br><br>បង្កើតឯកសារណែនាំអំពីការបណ្តុះបណ្តាល និងផ្តល់ការបណ្តុះបណ្តាលពីវិធីសាស្ត្របង្កើតមុខរបរឆ្លាតវៃខាងអាកាសធាតុ និងដែលមាននិរន្តរភាព ដល់ប្រជាពលរដ្ឋក្រីក្រនៅតាមជនបទ។ | សកម្មភាព NDC<br>• ការបន្សុំ - ១៥<br>• ការបន្សុំ - ១៧ |
| | ពិនិត្យនិងពង្រីកការស្តារឡើងវិញ និងការពង្រីកប្រព័ន្ធស្រោចស្រព(ដែលផ្តោតលើភាពធន់នឹងអាកាសធាតុ និងប្រសិទ្ធភាព) ដោយគិតគូរអំពីទំនាក់ទំនងទឹក អាហារ ថាមពល(WFE) | ពង្រីកផលិតកម្មកសិកម្មដែលធន់នឹងអាកាសធាតុ តាមរយៈការបង្កើនលទ្ធភាពទទួលបានប្រព័ន្ធស្រោចស្រពដើរដោយថាមពលព្រះអាទិត្យ និងការអនុវត្តផ្សេងទៀតដែលធន់នឹងអាកាសធាតុ។ | សកម្មភាព NDC<br>• ការបន្សុំ - ១៦ |
| | ធ្វើការវាយតម្លៃតម្រូវការសមត្ថភាព និងបង្កើត និងអនុវត្តកម្មវិធីបរិញ្ចឹមជីវិតដែលឆ្លាតវៃចំពោះអាកាសធាតុ និងមាននិរន្តរភាព។ | | សូមអាន ៣.៥ |
| | បង្កើនការគាំទ្រដល់សហគមន៍ងាយរងគ្រោះ ដើម្បីអនុវត្តកសិកម្មឆ្លាតវៃ បច្ចេកវិទ្យាក្រោយការប្រមូលផល និងជីវភាពរស់ដែលមាននិរន្តរភាព។ | ការអភិវឌ្ឍជំណាំសាកវប្បកម្ម និងដំណាំស្បៀងផ្សេងៗទៀត ដើម្បីបង្កើនផលិតកម្ម បង្កើនសុវត្ថិភាពគុណភាព បច្ចេកទេស | សកម្មភាព NDC<br>• ការបន្សុំ - ៣<br>• ការបន្សុំ - ៤ |

[30] ការធានារ៉ាប់រងគ្រោះមហន្តរាយនិងកសិកម្មនៅដំណាក់កាលដំបូងនៃការអភិវឌ្ឍនៅកម្ពុជា ដឹកនាំដោយវិស័យឯកជន ដូចជាក្រុមហ៊ុនធានារ៉ាប់រង Forte ដោយគ្មានការឧបត្ថម្ភធនសម្រាប់បុព្វលាភពីវិស័យសាធារណៈ។

| | | | |
|---|---|---|---|
| | | ប្រមូលផល និងក្រោយប្រមូលផល និងការលើកកម្ពស់កសិអាជីវកម្ម។<br><br>ការអភិវឌ្ឍជំណាំឧស្សាហកម្មដើម្បីបង្កើនផលិតកម្ម ការកែលម្អគុណភាពសុវត្ថិភាពបច្ចេកទេសប្រមូលផល និងក្រោយប្រមូលផល និងការលើកកម្ពស់អាជីវកម្មកសិកម្ម។ | |
| **២.៦- ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ និងកសាងភាពធន់ និងនិរន្តរភាពបរិស្ថាន (រួមទាំងស្តង់ដាអគារបៃតង គុណភាពខ្យល់ក្នុងអគារ ។ល។)។** | i- ពង្រឹងការអនុវត្តបទប្បញ្ញត្តិស្តីពីស្តង់ដាអគារបៃតង (សេចក្តីណែនាំអំពីអគារបៃតងជាតិ និងកូដអគារ ផែនការសកម្មភាពជាតិប្រព័ន្ធត្រជាក់។ល។ | កូដអគារនិងពង្រឹងការអនុវត្ត។<br><br>ការគ្រប់គ្រងគុណភាពខ្យល់ចេញពីការដ្ឋានសំណង់។ | សកម្មភាព NDC<br>• ការបន្សាំ - ១៤<br>• ការបន្សាំ - ៥០ |
| | ii- បញ្ជ្រាបលក្ខខណ្ឌតម្រូវអំពីភាពធន់នឹងអាកាសធាតុសម្រាប់ការសាងសង់ និងថែទាំផ្លូវថ្មីៗទាំងអស់និងកែលម្អផ្លូវដែលមានស្រាប់ | បន្ស៊ីស្តង់ដារចនាផ្លូវ ជាមួយកម្រិតហានិភ័យអាកាសធាតុនៃទីតាំងដាក់លាក់ បង្កើនស្តង់ដាធន់ទ្រាំសម្រាប់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនថ្មីៗ និងបង្កើនវិភាជន៍ថវិកាសម្រាប់ការថែទាំផ្លូវប្រហែល៩៤លានដុល្លារអាម៉េរិក/ឆ្នាំ ដោយផ្តល់អាទិភាពដល់ការវិនិយោគលើផ្លូវជនបទសំខាន់ៗ ជាពិសេស ក្នុងខេត្តបាត់ដំបង ព្រៃវែង និង កំពង់ចាម។ | ធនាគារពិភពលោក ២០២៣ |
| | iii- ការបញ្ជ្រាបការអនុវត្ត និងអនុលោមភាព ជាមួយកូដអគារបៃតង | ការរួមបញ្ចូលការអភិវឌ្ឍអគារបៃតង។ | សកម្មភាព NDC<br>• ការបន្សាំ - ៤៩<br>សូមអាន ២.៦ ដែរ (i) |



## អភិបាលកិច្ច/បរិវត្តកម្មឌីជីថល(កត្តាជំរុញ)

*តារាងទី៩ : សកម្មភាពជំរុញ ប្រភពនៃការប៉ាន់ប្រមាណថវិកា*

| លទ្ធផលយុទ្ធសាស្ត្រ | សកម្មភាព | ថវិកាដែលត្រូវគ្នានៅក្នុងប្រភព | ប្រភព |
|---|---|---|---|
| **៣.១- ពង្រឹងយន្តការហិរញ្ញវត្ថុអាកាសធាតុ** | បង្កើតចំណាត់ថ្នាក់ហិរញ្ញវត្ថុបៃតង ដើម្បីបង្កើតភាសាវិនិយោគបៃតងទូទៅ និងដែលឆ្លើយតបនឹងយេនឌ័រ និងចាំបាច់សម្រាប់ប្រព័ន្ធហិរញ្ញវត្ថុបៃតង។ | | ការត្រួតពិនិត្យការចំណាយសាធារណៈអាកាសធាតុឆ្នាំ ២០២២ ការផ្តល់មូលនិធិ NDC គឺ ៤៨៣,៧លានដុល្លារអាមេរិក ជារៀងរាល់ឆ្នាំ |
| | គណៈកម្មាធិការជាតិ/ក្រុមការងារយេនឌ័រ និងយន្តការហិរញ្ញវត្ថុបៃតងដែលឆ្លើយតបនឹងអាកាសធាតុ ការគ្រប់គ្រង និងស្តង់ដា។ | | |
| | កៀរគរហិរញ្ញប្បទាន ឧ. តាមរយៈ CCFF ជាមួយប្រភពមូលនិធិថ្លៃប្រឌិត និងវិធីសាស្ត្រដូចជា ការផ្តល់ហិរញ្ញប្បទានចម្រុះ[31]។ | | |
| | ពិនិត្យ និងបន្សុីច្បាប់ គោលនយោបាយ និងការគ្រប់គ្រងហានិភ័យសារពើពន្ធទាក់ទងនឹងគ្រោះមហន្តរាយដែលមានស្រាប់។ | | |
| | គោលនយោបាយដើម្បីជួយសម្រួលដល់ការទទួលបានសេវាធានារ៉ាប់រងឥណទានសម្រាប់ការសង្គ្រោះពីគ្រោះមហន្តរាយ និងភាពធន់ដែលឆ្លើយតបទៅនឹងយេនឌ័រ និងក្រុមជនងាយរងគ្រោះ។ | | |
| | បញ្ចូលហិរញ្ញប្បទានអាកាសធាតុទៅក្នុងថវិកាសាធារណៈ និងការចំណាយ ព្រមទាំងការត្រួតពិនិត្យ និងវាយតម្លៃ។ | | |
| | តាមដានការចំណាយលើអាកាសធាតុនៅកម្រិតជាតិ ទាំងដោយវិស័យសាធារណៈ និងឯកជន | | |

[31] CCFF គួរតែឈានហួសពីការផ្តល់ហិរញ្ញប្បទាន GCF ដោយបញ្ចូលទាំងទម្រង់នៃការផ្តល់មូលនិធិផ្សេងទៀត ដូចជា ការផ្តល់ហិរញ្ញប្បទានចម្រុះ ពីប្រភពសាធារណៈ ឬសប្បុរសជន ដើម្បីបង្កើនការវិនិយោគនៃវិស័យឯកជនលើការអភិវឌ្ឍដោយចីរភាព។ (https://www.convergence.finance/blended-finance)

| | | | |
|---|---|---|---|
| | បង្កើតយុទ្ធសាស្ត្រហិរញ្ញប្បទានអាកាសធាតុជាតិដ៏ទូលំទូលាយមួយ។ | | |
| | ធ្វើការសិក្សាលទ្ធភាពលើឱកាសទីផ្សារកាបូន អនុវត្តវិធានការពង្រឹកប្រព័ន្ធទីផ្សារសម្រាប់កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ រួមទាំងក្របខ័ណ្ឌច្បាប់ និងស្ថាប័ន យោងតាមលក្ខខណ្ឌតម្រូវនៃមាត្រា៦(ស្តីពីទីផ្សារកាបូន) ក្រោមកិច្ចព្រមព្រៀងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ។ | | |
| | ស្វែងយល់ពីការកៀរគរហិរញ្ញវត្ថុអាកាសធាតុតាមរយៈការជួញដូរកាបូន។ | | |
| | អនុវត្ត ETF សម្រាប់របាយការណ៍អាកាសធាតុ (បន្សីជាមួយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ស្តីពីការប្រែប្រួលអាកាសធាតុ)។ | | |
| | ប្រតិបត្តិការហិរញ្ញវត្ថុអាកាសធាតុ ការផ្តល់មូលនិធិ និងកម្រងទិន្នន័យព័ត៌មានឥណទានឥតសំណង (ឧ. ក្នុងកម្មវិធីតាមដាន NDC)។ | | |
| **៣.២- បង្កើនការអប់រំ ព័ត៌មានឱ្យចំគោលដៅ ការលើកកម្ពស់ការយល់ដឹង ការទំនាក់ទំនង និងការបណ្តុះបណ្តាលអំពីការប្រែប្រួលអាកាសធាតុ** | ធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាលើមុខវិជ្ជាប្រែប្រួលអាកាសធាតុនៅតាមថ្នាក់បឋមសិក្សា និងមធ្យមសិក្សា IHL និងការអប់រំក្រៅប្រព័ន្ធ ការសិក្សាពេញមួយជីវិត។ | ការលើកកម្ពស់កម្មវិធីសិក្សាដើម្បីរួមបញ្ចូលការប្រែប្រួលអាកាសធាតុសម្រាប់ការអប់រំក្រៅប្រព័ន្ធ<br><br>បើកវគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីអប់រំអំពីការប្រែប្រួលអាកាសធាតុ ឧ. ជាធាតុផ្សំចាំបាច់នៃការបណ្តុះបណ្តាលគរុកោសល្យគ្រូ | សកម្មភាព NDC<br>• ការបន្សាំ សកម្មភាពទី - ២១<br>• ការបន្សាំ - ២៣ |
| | ពង្រីកការបណ្តុះបណ្តាលដល់ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល អ្នកជំនាញប្រព័ន្ធផ្សព្វផ្សាយ និងសហគមន៍អំពីគោលនយោបាយពាក់ព័ន្ធទាក់ទងនឹងសកម្មភាព | ការកសាងសមត្ថភាពបន្សាំ និងធន់ សម្រាប់មន្ត្រី MRD នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការរៀបចំផែនការ | សកម្មភាព NDC<br>• ការបន្សាំ - ៧២<br>• ការបន្សាំ - ៧៣<br>• ការបន្សាំ - ៧៧ |

| | | | |
|---|---|---|---|
| | អាកាសធាតុ ដូចជា LTS4CN យុទ្ធសាស្ត្រក្រ វិស័យបរិស្ថាន NDC RE, EE ជាដើម។ | អភិវឌ្ឍន៍ជនបទ និងការរចនាបច្ចេកទេស។<br><br>កសាងសមត្ថភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់មេភូមិ(គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ VDCs)<br>ពង្រឹងសមត្ថភាពស្ថាប័នអំពីការប្រែប្រួលអាកាសធាតុ | |
| | យុទ្ធនាការផ្សព្វផ្សាយនិងបង្ហាញបច្ចេកវិទ្យាបញ្ចេញកាបូនតិចនិងប្រសិទ្ធភាពចំណាយ។ | | LTS4CN |
| | រចនានិងអនុវត្តយុទ្ធនាការអប់រំទូទាំងប្រទេសអំពីសកម្មភាពបរិស្ថាននិងអាកាសធាតុ។ | ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមនុស្សអំពីការប្រែប្រួលអាកាសធាតុក្នុងវិស័យព័ត៌មាន | សកម្មភាព NDC<br>• ការបន្សាំ - ១៣<br>• ការបន្សាំ - ៤០<br>• ការបន្សាំ - ៤១ |
| | កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្តីពីការរចនា និងការប្រាស្រ័យទាក់ទងដើម្បីកែប្រែឥរិយាបថសង្គមជាក់លាក់របស់អ្នកពាក់ព័ន្ធ(SBCC)។ | | |
| | ពង្រីកការចូលរួមនៃពហុភាគីពាក់ព័ន្ធនៅក្នុងការរចនា និងការអនុវត្តកម្មវិធី SBCC។ | ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារអភិវឌ្ឍន៍ក្នុងមូលដ្ឋាន និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធសម្រាប់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីអនុវត្តផែនការបន្សាំក្នុងវិស័យប្រព័ន្ធផ្សព្វផ្សាយ។ | សកម្មភាព NDC<br>• ការបន្សាំ - ៦៩ |
| **៣.៣- ពង្រឹងកម្លាំងពលកម្មបច្ចុប្បន្ន និងអនាគតឆ្ពោះទៅរកអន្តរកាលកាបូនតិចនិងធន់** | លើកទឹកចិត្តដល់វិស័យឯកជន/និយោជកឱ្យការវិនិយោគលើកម្លាំងពលកម្មដែលមានជំនាញក្នុងវិស័យបៃតងជាពិសេសការលើកកម្ពស់ជំនាញស្ត្រី។ | | សូមអាន ៣.២ (ការសិក្សាពេញមួយជីវិត) |
| | ពិនិត្យនិងកែសម្រួលកម្មវិធីសិក្សាផ្លូវការសម្រាប់កម្លាំងពលកម្មបៃតង/កាបូនតិច (STEM ថាមពលស្អាត បច្ចេកវិទ្យាឆ្លាតវៃអាកាសធាតុ) ។ | ពង្រឹងកម្មវិធីសិក្សានិងវិធីសាស្ត្របណ្តុះបណ្តាល រួមទាំងបណ្ណាល័យ ដើម្បីរួមបញ្ចូលមុខ | សកម្មភាព NDC<br>• ការបន្សាំ - ២០ |

| | | | |
|---|---|---|---|
| | | វិជ្ជាប្រែប្រួលអាកាសធាតុសម្រាប់ថ្នាក់បឋមសិក្សា | |
| | បង្កើនកិច្ចប្រឹងប្រែងR&D អំពីនវានុវត្តន៍បច្ចេកវិទ្យាបៃតង ដើម្បីជំរុញប្រព័ន្ធបច្ចេកវិទ្យាស្អាត និងបង្កើនល្បឿនការទទួលយកបច្ចេកវិទ្យាបៃតងដែលឆ្លើយតបនឹងយេនឌ័រ។ | បង្កើតមជ្ឈមណ្ឌលឧត្តមភាពសម្រាប់ការផ្តល់វគ្គសិក្សា និងការស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុក្នុងចំណោមសាកលវិទ្យាល័យ | សកម្មភាព NDC<br>• ការបន្សាំ - ២២ |
| ៣.៤- ពង្រឹងការចូលរួមនៃពហុភាគីពាក់ព័ន្ធ និងការពាក់ព័ន្ធក្នុងការអនុវត្តយុទ្ធសាស្ត្រ | បង្កើនការចូលរួមនៃក្រុមការងារបច្ចេកទេសបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ជាមួយស្ថាប័នហិរញ្ញវត្ថុ IHL ស្ថាប័នស្រាវជ្រាវ អ្នកជំនាញទំនាក់ទំនង/ប្រព័ន្ធផ្សព្វផ្សាយ។ | ធ្វើបច្ចុប្បន្នភាពនិងអនុវត្តផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា (CCCSP) | សកម្មភាព NDC<br>• ការបន្សាំ - ៧៥ |
| | ពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រតាមវិស័យ និងបង្កើត និងអនុវត្តផែនការអនុវត្ត/សកម្មភាព CCCSP ឆ្នាំ២០២៤-២០៣៣។ | បញ្ចូលវិធានការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយនិងយុទ្ធសាស្ត្រជាតិ និងយុទ្ធសាស្ត្រ និងផែនការតាមវិស័យ<br><br>ពង្រឹងសមត្ថភាពស្ថាប័នអំពីការប្រែប្រួលអាកាសធាតុ (ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការបន្សាំ គោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងហិរញ្ញវត្ថុ) តាមរយៈការលើកកម្ពស់ការយល់ដឹង ការបណ្តុះបណ្តាល និងការតស៊ូមតិ | សកម្មភាព NDC<br>• ការបន្សាំ - ៧៦<br>• ការបន្សាំ - ៧៧ |
| | បន្សុី M&E របស់ក្រសួងនានា ជាមួយ CCCSP ឆ្នាំ២០២៤-២០៣៣/ NDC/ LTS4CN MRV។ | | |
| | បញ្ចូល CCCSP ឆ្នាំ២០២៤-៣៣ ទៅក្នុងយុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃក្រសួង និងស្ថាប័នរៀងៗខ្លួន។ | | |
| ៣.៥- ពង្រឹងលទ្ធភាពទទួលបានជំនួយបច្ចេកទេសសម្រាប់ការកសាងសមត្ថភាពពហុភាគី | ពិនិត្យនិងធ្វើការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងវាយតម្លៃបច្ចេកវិទ្យាបន្សាំ និងតម្រូវការសមត្ថភាព និងផ្តល់អនុសាសន៍។ | ពង្រឹងភាពធន់និងសមត្ថភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងខេត្ត/ស្រុក/ឃុំដែលងាយរងគ្រោះបំផុត (ផលិតផែនទីសន្ទស្សន៍ភាពងាយរងគ្រោះនៅថ្នាក់ឃុំ បញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងផែនការវិនិយោគ និងអភិវឌ្ឍន៍ បង្ហាញពី | សកម្មភាព NDC<br>• ការបន្សាំ - ៧៤<br>• ការបន្សាំ - ៧៨ |
| ៣.៦- ដោះស្រាយគម្លាតទិន្នន័យ និងព័ត៌មានសម្រាប់ការ | ពិនិត្យនិងកែលម្អវិទ្យាស្ថានជាតិស្ថិតិ ដើម្បីបិទកាត់បន្ថយគម្លាតទិន្នន័យក្នុងការកាត់បន្ថយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ | | |

| | | | |
|---|---|---|---|
| ត្រួតពិនិត្យ និងការវាយតម្លៃដោយប្រសិទ្ធភាព | | សកម្មភាពដែលបានកំណត់នៅកន្លែងសាកល្បង)<br><br>ផ្តល់ការកសាងសមត្ថភាព និងការគាំទ្រដើម្បីនវានុវត្តន៍ការប្រែប្រួលអាកាសធាតុនៅខេត្តតាមដងទន្លេសាប។ | |
| | ស្វែងរកលទ្ធភាពនៃការបង្កើតកម្រងទិន្នន័យថ្នាក់កណ្តាលមួយអំពីការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (ផ្អែកលើកម្រងទិន្នន័យដែលមានស្រាប់និងដែលរក្សាដោយ CCCA/NCSD ធនាគារពិភពលោក។ល។) ដែលបានបន្សីជាមួយ ETF។ | ប្រព័ន្ធប្រកាសអាសន្នថ្នាក់ជាតិពីដើមដល់ចប់ ដោយផ្តោតលើការផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពដល់ពលរដ្ឋមានហានិភ័យ<br><br>បង្កើតបណ្តាញត្រួតពិនិត្យឧតុនិយមដោយស្វ័យប្រវត្តនៅទូទាំងប្រទេស និងកម្មវិធីបញ្ជូនទិន្នន័យ រួមទាំង ការប្រមូលទិន្នន័យអាកាសធាតុ និងជលសាស្ត្រ។ | សកម្មភាព NDC<br>• ការបន្សាំ - ៦១<br>• ការបន្សាំ - ៨១ |
| | ស្វែងរកកិច្ចសហការជាមួយរាជបណ្ឌិត្យសភា ស្ថាប័នស្រាវជ្រាវ និងដៃគូអភិវឌ្ឍ ដើម្បីកំណត់អត្តសញ្ញាណទំនាក់ទំនងនៃការប្រែប្រួលអាកាសធាតុដែលគេមិនសូវស្គាល់(ចំណាកស្រុក ហានិភ័យកុមារ សុខភាព ផលិតភាព ការបាត់បង់សេដ្ឋកិច្ច) ដែលត្រូវគាំទ្រ ដើម្បីបង្កើតទិន្នន័យផ្អែកលើភស្តុតាង។ | | សូមអាន ៣.២ (v) |
| ៣.៧- ពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូក្នុងតំបន់ និងអន្តរជាតិ (រួមទាំង អាស៊ាន គណៈកម្មការទន្លេមេគង្គ (MRC) កិច្ចផ្តួចផ្តើមកិច្ចសហប្រតិបត្តិការមេគង្គ ទីភ្នាក់ងារអង្គការសហ | ពង្រឹងកម្មវិធីសហប្រតិបត្តិការអន្តរជាតិរបស់ស្ថាប័នពាក់ព័ន្ធ ដើម្បីជួយសម្រួលដល់ការផ្ទេរបច្ចេកវិទ្យានិងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស | | |
| | ពង្រឹងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធ និងជំនាញចរចាក្នុងវេទិកាអាកាសធាតុអន្តរជាតិ និង | | ១លានដុល្លារអាមេរិក (MoH, ប្រចាំឆ្នាំ; ផ្អែកលើការស្មាន) |

| | | | |
|---|---|---|---|
| ប្រជាជាតិ មូលនិធិហិរញ្ញវត្ថុអាកាសធាតុ ធនាគារអភិវឌ្ឍន៍ និងទីភ្នាក់ងារអភិវឌ្ឍន៍) | តំបន់ ដោយរួមបញ្ចូល ផលប្រយោជន៍ និងកង្វល់របស់ជាតិ។ | | |
| **៣.៨- ការរៀបចំផែនទីបង្ហាញផ្លូវអំពីបរិវត្តកម្មឌីជីថលសម្រាប់ការងារបរិស្ថាននិងការប្រែប្រួលអាកាសធាតុ** | ការសិក្សាឯកសារដែលមានស្រាប់ និងការពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ<br>ការសិក្សាតម្រូវការបច្ចេកវិទ្យា និងការចំណាយ និងចំណេញលើការអភិវឌ្ឍថ្នាលឌីជីថលចាំបាច់ជាតំណាក់កាល<br>ការរៀបចំផែនទីបង្ហាញផ្លូវនិងវិភាគតម្រូវការថវិកានិងធនធានមនុស្ស។ | | ១,៧លានដុល្លារអាម៉េរិក |